អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

**អង្គបុរេជំនុំជម្រះ**
Pre-Trial Chamber
Chambre Préliminaire

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ

លេខ: ០០៤/១/០៧-០៩-២០០៩/អវតក/កសចស(អបជ៥០)

**អសាធារណៈ**

**ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧**

**ម៉ោង ១០:០១ នាទី**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 21-Dec-2017, 11:45
CMS/CFO: Sann Rada

**ចៅក្រមជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គីមសាន (ប្រធានអង្គបុរេ)

ចៅក្រម អូលីវីយេ បូវ៉ាឡេត៍
*(Judge Olivier BEAUVALLET)*

ចៅក្រម ន័យ ថុល

ចៅក្រម កាំង ជីន បាក់
*(Judge Kang Jin BAIK)*

ចៅក្រម ហួត វុទ្ធី

**ក្រឡាបញ្ជី៖**

លោកស្រី រស់ បូផាណា

លោកស្រី អែលសា ឡេវ៉ាវ៉ាស័រ
*(Mr. Elsa LEVAVASSEUR)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicholas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក កូមេន ខេននី *(Mr. Coman KENNY)*

**ជនត្រូវចោទ៖**

លោកស្រី អ៊ឹម ចែម

**មេធាវីការពារជនត្រូវចោទ៖**

លោក ប៊ិត ស៊ាងលឹម

លោក វេញ ហ្សកដាហ្ស *(Mr.Wayne JORDASH)*

កញ្ញា ហ្សូល្យាន រ៉ូមី *(Ms. Julianne ROMY)*

កញ្ញា អាស្ត្រីដ ប៉ុងស៊ូលេ
*(Ms. Astrid PONSOLLE)*

លោក លៀម ម៉ាក អានឌ្រូ
*(Mr. Liam MacAndrews)*

លោកស្រី រី ណូយ៉ែល

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក សំ សុគង់

លោកស្រី លីម៉ា ង្វៀន *(Lyma NGUYEN)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី សួ សុទ្ធាវី

សាធារណៈ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ប្រាក់ គឹមសាន (ប្រធានអង្គបុរេ) | ខ្មែរ |
| លោក ប៊ិត ស៊ាងលឹម | ខ្មែរ |
| លោក វេញ ហ្សកដាហ្ស | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[១០:០១:១៥]

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះ!

ខ្ញុំសូមប្រកាសបើកសវនាការ។ ជាបន្តទៅនេះ យើងបន្តសវនាការតាមកម្មវិធីដែលបានគ្រោងទុក។ អ៊ីចឹងសូមអញ្ជើញមេធាវីការពារឲ្យជនជាប់ចោទជាតិ និងអន្តរជាតិ ឡើងថ្លែងពីសេចក្តីសន្និដ្ឋានរបស់ខ្លួន។ សូមអញ្ជើញបាទ!

**លោក ប៊ិត ស៊ាងលឹម៖**

សូមគោរពឯកឧត្តមប្រធាន សូមគោរពក្រុមប្រឹក្សាអង្គចៅក្រម។ សួស្តីលោក លោកស្រី អ្នកនាង កញ្ញាទាំងអស់ដែលមានវត្តមានក្នុងសវនាការនេះ។ ខ្ញុំ ប៊ិត ស៊ាងលឹម ជាសហមេធាវីជាតិតំណាងឲ្យអ្នកស្រី អ៊ឹម ចែម។ ខ្ញុំបានចូលជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៧ និងជាមេធាវីជាតិតំណាងឲ្យអ្នកស្រី អ៊ឹម ចែម កាលពីខែធ្នូ ឆ្នាំ២០១៣។ នេះគឺជាសហមេធាវីអន្តរជាតិរបស់ខ្ញុំ ឈ្មោះ វេញ ហ្សកដាហ្ស។ លោក ហ្សកដាហ្ស ត្រូវបានអនុញ្ញាតឲ្យអនុវត្តវិជ្ជាជីវៈមេធាវីនៅចក្រភពអង់គ្លេស និងនៅប្រទេសវែល ក្នុងឆ្នាំ១៩៩៥ និងបានទទួលជាមេធាវី *ឃ្វីនខោនស៊ុល* តាំងពីឆ្នាំ២០១៣។ គាត់ជាមេធាវីតំណាងឲ្យអ្នកស្រី អ៊ឹម ចែម ពីខែកក្កដា ឆ្នាំ២០១៦។

[១០:០៤:០៨]

មុននឹងផ្តើម ខ្ញុំសូមជម្រាបជូនដល់អង្គបុរេជំនុំជម្រះ ព្រមទាំងភាគីទាំងអស់មេត្តាជ្រាបថា អ្នកស្រី អ៊ឹម ចែម បានសម្រេចជ្រើសយកការមិនបង្ហាញខ្លួនក្នុងសវនាការនេះ ហើយក៏មិនបានរៀបចំសេចក្តីថ្លែងការណ៍ណាមួយឲ្យយើងខ្ញុំអានជំនួសអ្នកស្រីដែរ។ ការធ្វើដូច្នេះ មិនមែនមានន័យថា អ្នកស្រីគ្មានការគោរពចំពោះតុលាការឡើយ។ ដោយសារតែការចាប់អារម្មណ៍ពីសំណាក់សារព័ត៌មាននានា និងដោយគិតទៅដល់បញ្ហាសន្តិសុខផង ទើបអ្នកស្រីសម្រេចថា ឲ្យមេធាវីការពារក្តីអ្នកស្រី។ អ្នកស្រីនៅតែបន្តទទូចពីការគ្មានទោសកំហុស ចំពោះរាល់ការចោទប្រកាន់ទាំងនោះលើរូបអ្នកស្រី។ ដូច្នេះ ថ្ងៃនេះខ្ញុំនឹងធ្វើការឆ្លើយតបចំពោះមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងទឡ្ហីករណ៍នានា ដែលពួកគាត់បានលើកឡើងទាក់ទងនឹងជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់

កម្ពុជា។ ខ្ញុំត្រូវការពេលប្រហែលជាង១ម៉ោង ដើម្បីបង្ហាញនូវសេចក្តីឆ្លើយតបនេះ។ សុំអនុញ្ញាតមេធាវីសហមេធាវីអន្តរជាតិរបស់ខ្ញុំប្រើប្រាស់ពេលវេលានៅសល់ ដើម្បីនឹងធ្វើការឆ្លើយចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ។

តទៅនេះ អនុញ្ញាតឲ្យខ្ញុំត្រឡប់មករកសំអាងហេតុមួយចំនួនដែលបានលើកឡើងដោយមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងទឡ្ហីករណ៍នានារបស់ពួកគាត់លើជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា។ និយាយឲ្យខ្លីទៅ ទាំងនៅក្នុងសារណាលាយ-លក្ខណ៍អក្សរដែលពួកគាត់បានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះ (សូមទោស) ឯកសារ D308/319 និងសារណាផ្ទាល់មាត់លើបញ្ហានេះកាលពីម្សិលមិញ មេធាវីតំណាងអតីតអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានតវ៉ាលើចំណុចពីរធំៗ។ មួយ ទី១ថា សហចៅក្រមស៊ើបអង្កេតមិនគួរធ្វើការសង្កេតទាក់ទងនឹងជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាក្នុងដីកាដំណោះស្រាយរបស់ពួកគាត់នោះទេ។ និងទី២ថា ការសង្កេតរបស់សហចៅក្រមស៊ើបអង្កេតចំពោះបញ្ហាដែលថាតុលាការជាតិរបស់កម្ពុជាខ្វះយុត្តាធិការលើជនដែលដល់ខ្មែរក្រហម គឺជាការភ័ន្តច្រឡំ។

[១០:០៨:១៨]

ផ្អែកលើមូលដ្ឋាននៃចំណុចទាំងពីរនេះ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានសន្និដ្ឋាននៅត្រង់កថាខណ្ឌ៣២ នៃសារណាលាយលក្ខណ៍អក្សររបស់ពួកគាត់ដែលមានខ្លឹមសារដូច្នេះ ខ្ញុំសូមដកស្រង់ដូចតទៅ៖ "កម្រិតដែលតុលាការកម្ពុជាសាមញ្ញមានសមត្ថភាពលើផ្លូវច្បាប់ និងស្ថាប័នក្នុងការដោះស្រាយឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម គឺជាបញ្ហាមួយដែលត្រូវប្រគល់ដល់តុលាការទាំងនោះឲ្យសម្រេចដោយខ្លួនឯង" ចប់ការដកស្រង់។ ការសន្និដ្ឋាននេះ គឺជាសំណួរមួយដែលត្រូវសួរតាំងពីដំបូងមក។ បើសិនជាជំហររបស់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីពិតជាថា តុលាការជាតិរបស់កម្ពុជាតែឯង គួរតែអាចកំណត់ពីវិសាលភាពនៃដែនសមត្ថកិច្ចផ្ទាល់ខ្លួន លើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនោះមែន ហេតុអ្វីបានជាពួកគាត់ចាំបាច់ត្រូវស្នើសុំអង្គបុរេជំនុំជម្រះឲ្យផ្តល់ជាដំណោះស្រាយក្នុងរឿងនេះ? តើវាមិនមែនសម្រេច (សូមទោស) តើវាមិនមែនសម្រាប់តុលាការសាមញ្ញរបស់កម្ពុជាទេឬ ដែលត្រូវធ្វើការសម្រេចដោយខ្លួនឯងនេះ?

ជំហររបស់យើងខ្ញុំ នឹងលម្អិតជូន គឺមានដូចខាងក្រោម។ អង្គបុរេជំនុំជម្រះមិនមែនជាអង្គភាព

សមស្របដើម្បីធ្វើការកំណត់ដាច់ណាត់តែឯកឯង (សូមទោស) លើបញ្ហាថាតើតុលាការសាមញ្ញរបស់កម្ពុជាមាន ឬមិនមានសមត្ថកិច្ចក្នុងការកាត់សេចក្តីលើសំណុំរឿងព្រហ្មទណ្ឌដែលបានប្រព្រឹត្តនៅក្នុងសម័យខ្មែរក្រហមនោះទេ។ ដូច្នេះមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបកស្រាយខុសនូវគោលបំណងរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការដែលពួកគាត់ធ្វើការវិភាគលើបញ្ហាយុត្តាធិការរបស់តុលាការសាមញ្ញរបស់កម្ពុជា ចំពោះឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។ គោលបំណងរបស់សហចៅក្រមស៊ើបអង្កេត គឺមិនមែនជាការចងកាតព្វកិច្ចអ្វីដល់តុលាការកម្ពុជានោះទេ ប៉ុន្តែដើម្បីឲ្យយល់ និងគូសបញ្ជាក់ឲ្យឃើញនូវភាពសមហេតុសមផលនៃឆន្ទានុសិទ្ធិរបស់ពួកគាត់។ បញ្ហានេះមានរឿងតែប៉ុណ្ណឹង ហើយដែលគួរតែជាប្រធានបទនៃការប្តឹងឧទ្ធរណ៍ ឬសុំធ្វើការកែប្រែ។

[១០:១២:២០]

ទោះក្នុងកាលៈទេសៈណាក៏ដោយ បើតាមធម្មតា មិនថាតាមមធ្យោបាយណាក៏ដោយ ប្រសិនបើត្រូវការចាំបាច់មធ្យោបាយទាំងនោះ គប្បីត្រូវពិចារណាដោយភាពប្រយ័ត្នប្រយែងទៅលើចេតនាដែលបានថ្លែងឡើងយ៉ាងច្បាស់ពីសំណាក់ស្ថាប័ននៃ -- ពីសំណាក់ស្ថាប័នមួយចំនួនរបស់កម្ពុជា។ ការជ្រើសយកការកាត់ទោសលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមតែនៅចំពោះមុខ អ.វ.ត.ក ប៉ុណ្ណោះ។ អង្គបុរេជំនុំជម្រះមិនមែនជាអង្គភាពសមស្រប ដើម្បីផ្តល់ជាដំណោះស្រាយដែលបានស្នើសុំដោយមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះទេ។

អនុញ្ញាតឲ្យខ្ញុំត្រឡប់ទៅចំណុចទី១។ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអង្គបុរេជំនុំជម្រះឲ្យលុបចោលទស្សនៈរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងបញ្ហាយុត្តាធិការតុលាការសាមញ្ញរបស់កម្ពុជា លើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។ ក្រៅពីកម្មវត្ថុ និងគោលបំណងនៃការយល់ឃើញផ្សេងៗ ដែលសហចៅក្រមស៊ើបអង្កេតបានបង្ហាញឲ្យឃើញមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានចាត់ទុកថា អង្គបុរេជំនុំជម្រះគួរចងកាតព្វកិច្ច អ.វ.ត.ក និងធ្វើការប្រកាសថា មានតែតុលាការកម្ពុជាខ្លួនឯងប៉ុណ្ណោះ ដែលមិនត្រឹមតែជាអ្នកកំណត់វិសាលភាពនៃយុត្តាធិការលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនោះទេ ប៉ុន្តែថែមទាំងអាចបង្ហាញពីទស្សនៈអ្វីក៏ដោយលើបញ្ហាយុត្តាធិការ ជារួមនៅកថាខណ្ឌ៣១នៃឯកសារ D308/3/1/9 មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា សេចក្តីសង្កេតរបស់ចៅក្រមស៊ើបអង្កេតរាំង ខ្ញុំសូមដកស្រង់៖ “តុលាការកម្ពុជាធម្មតាយ៉ាងច្បាស់លាស់មិនឲ្យដោះ

ស្រាយដោយខ្លួនឯង មិនថាតុលាការទាំងនេះ អាចអនុវត្តយុត្តាធិការក្នុងរយៈពេលនេះ បានដែរឬអត់នោះទេ” ចប់ការដកស្រង់។

ទោះជាយ៉ាងណាក្តី វាច្បាស់ណាស់ថា ការស្នើសុំនេះ ឥតប្រយោជន៍ទេ។ មុខងាររបស់អង្គបុរេជំនុំជម្រះមិនមែនដើម្បីធ្វើការសម្រេចលើបញ្ហា ថាតើតុលាការសាមញ្ញរបស់តុលាការកម្ពុជាមាន ឬមិនមានសមត្ថកិច្ចលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមឡើយ។ ការប៉ុនប៉ងណាមួយដើម្បីកម្រិតព្រំដែនសមត្ថកិច្ចរបស់តុលាការកម្ពុជា តាមរបៀបដែលមេធាវីតំណាងអតីតអ្នកដាក់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឡើង និងមិនត្រឹមតែហួសហេតុប៉ុណ្ណោះទេ ថែមទាំងការរំលោភលើសិទ្ធិអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាលើការកំណត់យុត្តាធិការច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន រាប់បញ្ចូលទាំងសិទ្ធិរបស់តុលាការជាតិ ក្នុងការកំណត់ខ្លួនឯង ថាតើពួកគេមាន ឬមិនមានសមត្ថកិច្ចលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។

[១០:១៧:១៩]

សហចៅក្រមស៊ើបអង្កេតមិនបានប៉ុនប៉ងដកតុលាការសាមញ្ញរបស់តុលាការកម្ពុជាចេញពីយុត្តាធិការបំពេញបន្ថែមណាមួយឡើយ ប្រសិនជាមានយុត្តាធិការបែបនោះមែន។ ទី១ ជាការយល់ច្រឡំទាំងស្រុងក្នុងការអះអាងថា សហចៅក្រមស៊ើបអង្កេតបានប៉ុនប៉ងដកតុលាការកម្ពុជាចេញពីយុត្តាធិការបំពេញបន្ថែមណាមួយ ដែលតុលាការទាំងនេះអាចនឹងមានទៅលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម (សូមទោស)។ ដោយពិចារណាទៅលើទិដ្ឋភាពសមរម្យនានា ការសង្កេតរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា គឺមិនមានលក្ខណៈជាសេចក្តីប្រកាស ឬសេចក្តីសម្រេចនោះទេ។ ការសង្កេតទាំងនោះ ជាផ្នែកនៃការវាយតម្លៃពីសមត្ថកិច្ចផ្ទាល់ខ្លួនរបស់ពួកគាត់។ មិនមានអ្វីនៅក្នុងកំណត់សម្គាល់ទាំងនោះ ឬក៏មានការបញ្ជាក់ហេតុផលណាមួយ ដែលបង្ហាញឲ្យឃើញថា ពួកគាត់មានបំណងចងកាតព្វកិច្ចតុលាការសាមញ្ញរបស់កម្ពុជា និងធ្វើការរារាំងតុលាការទាំងនោះ មិនឲ្យប្រើប្រាស់បុព្វសិទ្ធិរបស់ខ្លួនក្នុងការសម្រេច ឬក៏កំណត់វង្វង់ដែនយុត្តាធិការរបស់ពួកគាត់លើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមឡើយ។

ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ៧ និងកថាខណ្ឌ៨ នៃសារណាជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំ ឯកសារ D308/3/1/18 ការវិភាគរបស់សហចៅក្រមស៊ើបអង្កេតចំពោះជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា មិនបានសរសេរក្នុងរបៀបដែលឲ្យយកទៅអនុវត្តបានលើបញ្ហាណា

មួយក្រៅតែអំពីវិសាលភាពនៃយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ឡើយ។ មិនមានអ្វីនៅក្នុងសេចក្តីសំអាងហេតុ ឬក៏ផ្នែកផ្សេងទៀតនៃដីកាដំណោះស្រាយដែលអនុញ្ញាតឱ្យមានការសន្និដ្ឋានថា ចៅក្រម សហចៅក្រមស៊ើបអង្កេតមានគោលបំណងយកទៅអនុវត្តក្រៅពីបញ្ហាវិសាលភាព យុត្តាធិការបុគ្គលតាមន័យដ៏តូចចង្អៀតនោះទេ។ នេះមិនមែនជំទាស់ថាអាចនឹងមិនមានពាក់ព័ន្ធជាមួយបញ្ហាផ្សេងៗទៀត ប្លុករួមទាំងបញ្ហាទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការនៃតុលាការសាមញ្ញរបស់កម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ទ្រឹស្តី ឬការរំពឹងទុកនូវស្ថានការណ៍អនាគត មិនប្រាកដប្រជា មួយមិនអាចបង្កឱ្យមានបញ្ហាចោទមួយដែលគួរតែត្រូវបានធ្វើការពិនិត្យឡើងវិញ ឬដោះស្រាយដោយអង្គបុរេជំនុំជម្រះឡើយ កុំថាដល់ទៅការបង្កឱ្យមានការសន្និដ្ឋានថា នេះគឺជាចេតនារបស់សហចៅក្រមស៊ើបអង្កេតនោះ។

[១០:២២:១៣]

សហចៅក្រមស៊ើបអង្កេតមិនបានរារាំងតុលាការសាមញ្ញរបស់កម្ពុជាមិនឱ្យដោះស្រាយលើសំណុំ -- លើសំណួរចោទស្តីពីយុត្តាធិការបំពេញបន្ថែមរបស់តុលាការទាំងនោះទេ។ ទី២ គឺជាការភ័ន្តច្រឡំផងដែរក្នុងការអះអាងថា ការសង្កេតរបស់សហចៅក្រមស៊ើបអង្កេតតាមពិតរារាំងតុលាការសាមញ្ញរបស់កម្ពុជាមិនឱ្យធ្វើការវិនិច្ឆ័យលើសំណួរចោទ ស្តីពីបញ្ហាយុត្តាធិការបំពេញបន្ថែមរបស់តុលាការទាំងនេះ។ តាមធម្មតា ប្រសិនបើតុលាការសាមញ្ញរបស់កម្ពុជាសម្រេចថា ខ្លួនមានសមត្ថកិច្ចក្នុងការកាត់ក្តីលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមដែលស្ថិតនៅក្រៅយុត្តាធិការរបស់ អ.វ.ត.ក មែនតុលាការទាំងនោះនឹងគ្មានចំណងកាតព្វកិច្ចភ្ជាប់ ដោយសារតែការវិភាគរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយទេ ហើយក៏គ្មានកាតព្វកិច្ចភ្ជាប់នឹងសេចក្តីសម្រេចក្រោយៗមកទៀត ឬដោយសារតែសេចក្តីប្រកាសហាមឃាត់ដោយអង្គបុរេជំនុំជម្រះស្តីពីបញ្ហានេះដែរ។

កាលពីពេលកន្លងទៅ អង្គជំនុំជម្រះមួយចំនួននៅក្នុង អ.វ.ត.ក មានឱកាសបានចេញសេចក្តីសម្រេចលើបញ្ហាទំនាក់ទំនងរវាង អ.វ.ត.ក និងតុលាការសាមញ្ញរបស់កម្ពុជា។ ដូចយើងខ្ញុំបានកត់សម្គាល់នៅត្រង់កថាខណ្ឌ៦នៃសារណាលាយលក្ខណ៍អក្សរ ឯកសារលេខ D308/3/1/18 នៅក្នុងសំណុំរឿង០០១ ទាំងអង្គបុរេជំនុំជម្រះ និង អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា គ្មានទំនាក់ទំនងអំណាចណាមួយរវាងតុលាការទាំងពីរ ពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការនោះទេ។ ជាពិសេស អង្គបុរេជំនុំជម្រះបានសម្រេចនៅក្នុងសំណុំរឿង០០១ ខ្ញុំសំដៅលើឯកសារលេខ C5/45 ត្រង់កថាខណ្ឌ១៧ ខ្ញុំដក

ស្រង់៖ “យើងមិនឃើញមានបទប្បញ្ញត្តិណាមួយដែលចែងអំពីទំនាក់ទំនងរវាង អ.វ.ត.ក ជាស្ថាប័នតុលាការជាមួយនឹងស្ថាប័នតុលាការដទៃទៀតក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាឡើយ” ចប់ការដកស្រង់។ ស្រដៀងគ្នានេះដែរ គ្មានបទប្បញ្ញត្តិច្បាប់ណាមួយនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឬក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាចែងថា តុលាការកម្ពុជាត្រូវមានចំណងកាតព្វកិច្ចជាប់ដោយសេចក្ដីសម្រេចនានារបស់ អ.វ.ត.ក នោះទេ។

គួរឱ្យកត់សម្គាល់ផងដែរថា ការបង្ហាញនេះត្រូវបានទទួលស្គាល់រួចហើយពីសំណាក់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយពួកគាត់បានយោងជាសំអាងនៅក្នុងកថាខណ្ឌ៤ នៃសារណាលាយលក្ខណ៍អក្សររបស់ខ្លួន ឯកសារលេខ D308/3/1/9។ យើងខ្ញុំមិនដឹងទេថាតើហេតុអ្វីឥឡូវនេះ ស្រាប់តែពួកគេជ្រើសយកជម្រើសធ្វើជាមិនដឹងនូវអ្វីដែលពួកគាត់បានទទួលស្គាល់ហើយ ហើយបែរជាដកខ្លួនចេញវិញដើម្បីស្វះស្វែងសុំការអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះ។

[១០:២៧:៣៩]

អាស្រ័យហេតុនេះ ស្របតាមការអះអាងរបស់យើងខ្ញុំក្នុងកថាខណ្ឌ៥ នៃសារណាជាលាយលក្ខណ៍អក្សរ ឯកសារ D308/3/1/18។ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយបញ្ច្រាស់គ្នា ម្យ៉ាងទៀត ពួកគាត់តវ៉ាថា ការសង្កេតរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹង (សូមទោស) ទាក់ទងនឹងសមត្ថកិច្ចរបស់ខ្លួន មានអានុភាពចងកាតព្វកិច្ចតុលាការសាមញ្ញរបស់កម្ពុជា ក្នុងលក្ខណៈមួយដែលអាចរារាំងតុលាការទាំងនោះ មិនឱ្យដោះស្រាយលើសំណួរចោទស្ដីពីបញ្ញាយុត្តាធិការបំពេញបន្ថែមរបស់ខ្លួន។ តែម្យ៉ាងវិញទៀត មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានធ្វើការដកស្រង់ឱ្យស្របគ្នានឹងករណីយុត្តិសាស្ត្រដែលថា ការចង្អុលបង្ហាញជាចំណុចជាក់លាក់ និងប្រាកដប្រជាថា អ.វ.ត.ក និងតុលាការសាមញ្ញរបស់កម្ពុជា គឺជាអង្គភាពដាច់ដោយឡែកពីគ្នា ដែលសេចក្ដីសម្រេចនៃតុលាការទាំងពីរនេះ មិនត្រូវបានចងកាតព្វកិច្ចរវាងគ្នានឹងគ្នាឡើយ។ ការស្នើសុំបែបនេះ គឺជាការជាន់ដានខ្លួនឯង ដោយនិយាយផ្ទុយគ្នា ហើយមិនអាចទទួលបានការអនុញ្ញាតឱ្យបញ្ចុះបញ្ចូលតាមរបៀបដូច្នេះបានទេ។ អង្គបុរេជំនុំជម្រះមិនមានកាតព្វកិច្ចត្រូវធ្វើការពិចារណាលើសេណារីយ៉ូមិនប្រាកដប្រជា ដូចជាមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានបង្ហាញនោះទេ។

ទី៣ ដូចបានតវ៉ានៅក្នុងកថាខណ្ឌ៩នៃសារណាជាលាយលក្ខណ៍អក្សរ ឯកសារD308/3/1/18

អង្គបុរេជំនុំជម្រះបានសម្រេចតាំងពីយូរយារណាស់មកហើយថា មិនមានការតម្រូវឲ្យអង្គបុរេជំនុំជម្រះត្រូវធ្វើការពិចារណា ឬផ្តល់មតិយោបល់ណែនាំជាពិសេសណាមួយលើសេណារីយ៉ូបែបស្មានៗដូច្នេះទេ។ ការពិត មិនមែនមុខងាររបស់អង្គបុរេជំនុំជម្រះនោះទេ ដែលត្រូវធ្វើការវែកញែកតាមរយៈសេណារីយ៉ូមិនប្រាកដប្រជាផ្តល់ឲ្យដល់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះករណីដែលថា កម្ពុជាអាចនឹងសម្រេចពីការអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម នាពេលអនាគតឡើយ។ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានស្វះស្វែងសុំឲ្យមានមធ្យោបាយមួយ គឺពេលគឺអង្គបុរេជំនុំជម្រះធ្វើការប្រកាសថា បញ្ជោយុត្តាធិការបំពេញបន្ថែមរបស់តុលាការសាមញ្ញកម្ពុជា ទុកឲ្យតុលាការទាំងនេះដោះស្រាយខ្លួនឯង ដោយផ្អែកលើ (សូមទោស) ដោយផ្អែកលើសេណារីយ៉ូ មិនប្រាកដប្រជា និងប្រថុយប្រថានសុទ្ធសាធ។

[១០:៣២:៣៥]

មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានអះអាងនៅក្នុងកថាខណ្ឌ៣១ នៃសារណាលាយលក្ខណ៍អក្សររបស់ពួកគាត់ដូច្នេះថា ខ្ញុំដកស្រង់៖ “តុលាការកម្ពុជាអាចសម្រេចថា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឲ្យ ឬក៏សឹងតែតម្រូវឲ្យមានការកាត់ទោសដោយផ្ទាល់នូវបទល្មើសដែលត្រូវបានទទួលស្គាល់ក្រោមច្បាប់ព្រហ្មទណ្ឌ ទំនៀមទម្លាប់អន្តរជាតិសម្រាប់ឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម” ចប់ការដកស្រង់។ ពួកគាត់ថា តុលាការកម្ពុជា ខ្ញុំដកស្រង់៖ “អាចសម្រេចអនុញ្ញាតឲ្យមានការកាត់ទោសចំពោះឧក្រិដ្ឋកម្មដោយផ្អែកលើបទប្បញ្ញត្តិនានាដែលត្រូវបានអនុវត្ត (សូមទោស) ដែលត្រូវបានអនុម័តបន្ទាប់ពីការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ” ចប់ការដកស្រង់។ ឬថា សូមដកស្រង់៖ “តទៅថ្ងៃមុខ កម្ពុជាសឹងតែអាចអនុម័តច្បាប់បន្ថែមដើម្បីផ្តល់យុត្តាធិការកាន់តែច្បាស់លាស់បន្ថែមទៀត ដល់តុលាការជាតិរបស់ (សូមទោស) ដល់តុលាការជាតិរបស់ខ្លួនលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម” ចប់ការដកស្រង់។

ជាក់ស្តែង ទាំងនៅក្នុងសារណាលាយលក្ខណ៍អក្សរ និងសារណាផ្ទាល់មាត់របស់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខកខានមិនបានធ្វើការចង្អុល (សូមទោស) ខកខានមិនបានធ្វើការបង្អុលបង្ហាញឲ្យឃើញថា សេណារីយ៉ូដែលពួកគាត់បានលើកឡើងនេះ គឺជាសេណារីយ៉ូដែលមានភាពច្បាស់លាស់ ហើយបច្ចុប្បន្នកំពុងបង្កហានីភ័យលើសិទ្ធិអធិបតេយ្យភាពណាមួយរបស់កម្ពុជា ឬសិទ្ធិណាមួយ ក្នុងចំណោមសិទ្ធិនានាដែលមានភ្ជាប់ជាមួយអតីតអ្នកដាក់ពាក្យ

សុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ មានរឿងជាច្រើនអាចនឹងកើតឡើងនាពេលអនាគត តើអង្គបុរេជំនុំជម្រះត្រូវតែព្យាកររឿងរ៉ាវ ទាំងអស់នេះ ហើយបង្កើតដំណោះស្រាយស្របច្បាប់សិប្បនិម្មិតដើម្បីការពារលើការភ័យខ្លាចទុកជាមុន ដែលមានពេលណាមួយនោះ រឿងរ៉ាវទាំងនេះអាចនឹងកើតមានឡើងនៅពេលអនាគតដែរឬយ៉ាងណា។

មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី បានបកស្រាយខុសពីគោលបំណងនៃការវិភាគរបស់សហចៅក្រមស៊ើបអង្កេតលើជំហររបស់ អ.វ.ត.ក ក្នុងប្រព័ន្ធច្បាប់កម្ពុជា។ ខណៈដែលជំហររបស់យើងខ្ញុំ គឺថាអង្គបុរេជំនុំជម្រះមិនមែនជាអង្គភាពសមស្របដើម្បីផ្ដល់តាមនូវអ្វីដែលភាគីបានស្នើសុំ។ ខ្ញុំសុំត្រឡប់ទៅកាន់ចំណុចទី២ ដែលខ្ញុំបានលើកឡើងមុននេះ។ និយាយឲ្យចំគឺថាមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី បានធ្វើការបកស្រាយខុសពីបំណងរបស់សហចៅក្រមស៊ើបអង្កេតលើជំហរ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា។ ពួកគាត់អះអាងថា សេចក្ដីសង្កេតរបស់សហចៅក្រមស៊ើបអង្កេតមិនត្រឹមត្រូវ ហើយថាសហចៅក្រមស៊ើបអង្កេតបានព្យាយាមដកយកយុត្តាធិការចេញពីតុលាការសាមញ្ញរបស់កម្ពុជា សម្រាប់ធ្វើការវិនិច្ឆ័យទោសលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។ ប្រាកដណាស់ គឺគ្មានរឿងដូច្នេះកើតឡើងឡើយ និយាយឲ្យខ្លីទៅប្រសិនបើមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទទួលស្គាល់ថា សហចៅក្រមស៊ើបអង្កេតមានភារកិច្ចធានាថា ជនត្រូវចោទត្រូវស្ថិតនៅក្នុងដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក នោះ ពួកគាត់ត្រូវតែទទួលស្គាល់ថា បញ្ហាយុត្តាធិការនៃតុលាការសាមញ្ញរបស់កម្ពុជា គឺជាបញ្ហាពាក់ព័ន្ធដែលសហចៅក្រមស៊ើបអង្កេតត្រូវតែធ្វើការវាយតម្លៃដើម្បីឲ្យយល់ពីឆន្ទានុសិទ្ធិរបស់ខ្លួន។

[១០:៣៩:២៤]

ជាការពិតណាស់ និងជាការប្រកែកមិនបានឡើយថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចក្នុងការធានាឲ្យបានថា អ្នកស្រី អ៊ឹម ចែម ពិតជាស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទើបអ្នកស្រីក្លាយជាបុគ្គលដែលសហចៅក្រមស៊ើបអង្កេតអាចបញ្ជូនសំណុំរឿងរបស់អ្នកស្រីទៅកាត់ទោសបាន។ មាត្រា៥.៣ នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក ចែងថា៖ “វិសាលភាពនៃការស៊ើបអង្កេត គឺត្រូវបានកំណត់ត្រឹមតែទៅលើមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យខ្មែរក្រហម។” ស្រដៀងគ្នានេះ មាត្រា៦.៣ នៃកិច្ចព្រមព្រៀងរបស់ អ.វ.ត.ក បានចែងថា វិសាលភាពនៃការចោទប្រកាន់ គឺត្រូវបានកំណត់ត្រឹមតែចំពោះប្រភេទមនុស្សដូចគ្នា។” ប្រសិន

បើសហចៅក្រមស៊ើបអង្កេតយល់ថា ជនត្រូវចោទមិនស្ថិតនៅក្នុងប្រភេទបុគ្គលទាំងពីរខាងលើនោះទេ នោះការចោទប្រកាន់ទាំងអស់ត្រូវតែទម្លាក់ចោល។

ក្នុងបរិបទនៃសំណុំរឿង០០៤/១ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងនៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនថា អ្នកស្រី អ៊ឹម ចែម គឺជាបុគ្គលម្នាក់ស្ថិតក្នុងប្រភេទអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តទៅក្នុងសម័យខ្មែរក្រហម។ បានសេចក្តីថា សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឲ្យធ្វើការកំណត់នូវវាក្យសព្ទនៃពាក្យ “ទទួលខុសខ្ពស់បំផុត” ដើម្បីធ្វើការវាយតម្លៃថាតើអ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្នុងដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬយ៉ាងណា? មុននឹងធ្វើការសម្រេចសេចក្តីណាមួយ លើធាតុសំខាន់នៃសំណុំរឿងរបស់អ្នកស្រី ជាពិសេសគឺមុនពេលពួកគាត់ត្រូវសម្រេចចិត្តថាតើត្រូវបន្ត ឬមិនបន្តដំណើរការជំនុំជម្រះលើសំណុំរឿងនេះ។

[១០:៤៣:០៧]

ឥឡូវនេះ គ្រប់គ្នានៅ អ.វ.ត.ក សុទ្ធតែបានយល់ថា ការវាយតម្លៃលើពាក្យ “ការទទួលខុសត្រូវខ្ពស់បំផុត” គឺជាបញ្ហាឆន្ទានុសិទ្ធិមួយរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីពួកគាត់សម្រេចមុននឹងធ្វើការកំណត់លើបញ្ហាផ្សេងទៀត។ នៅក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចនៅក្នុងសាលដីកាលើបណ្តឹងសាទុក្ខដូច្នេះថា ឯកសារ F28 ត្រង់កថាខណ្ឌ៦២ ខ្ញុំដកស្រង់៖ “ទាំងជនសង្ស័យ និងអ.វ.ត.ក មិនអាចបង្ហាញថាតើជនសង្ស័យ គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុត ឬមិនមែនដោយសារអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យច្បាស់លាស់ អរូបិយ និងស្វ័យភាពបានឡើយ” ចប់ការដកស្រង់។ និយាយម្យ៉ាងទៀត លក្ខខណ្ឌដ៏សាមញ្ញនៃប្រភេទអ្នកទទួលខុសត្រូវខ្ពស់បំផុត គឺវាតម្រូវឲ្យមានការប្រើឆន្ទានុសិទ្ធិយ៉ាងច្រើន។ ក្នុងសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូលក៏បានរំឭកឡើងវិញផងដែរ នៅក្នុងកថាខណ្ឌ៨០ នៃសាលដីកាលើបណ្តឹងសាទុក្ខដូច្នេះថា ឯកសារ F28 ការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត និងការវាយតម្លៃលើពាក្យ “ការទទួលខុសត្រូវខ្ពស់បំផុត” ត្រូវតែធ្វើឡើងដោយសុទ្ធចិត្ត ផ្អែកតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈត្រឹមត្រូវ។ នេះគឺជាអ្វីដែលសហចៅក្រមស៊ើបអង្កេតបានធ្វើយ៉ាងត្រឹមត្រូវ ការយល់ឃើញនេះ មិនដែលត្រូវបានជំទាស់ម្តងណាឡើយពីភាគីនៃសំណុំរឿង ០០៤/១ បូករួមទាំងសហព្រះរាជអាជ្ញាអន្តរជាតិ និងមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

នៅក្នុងកថាខណ្ឌមួយចំនួនតាំងពីដំបូងទីនៃដីកាដំណោះស្រាយរបស់គាត់ សហចៅក្រមស៊ើប

អង្កេតបានចងក្រងនូវការវិភាគផ្លូវច្បាប់ជាធរមាន អនុវត្តលើយុត្តាធិការបុគ្គលនៅ អ.វ.ត.ក និងបាន ដោះស្រាយលើកគ្គាមួយចំនួនទាក់ទងនឹងការកំណត់ពីព្រំដែននៃពាក្យ "ការទទួលខុសត្រូវខ្ពស់បំផុត"។ ក្នុងន័យនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើការវិភាគយ៉ាងហ្មត់ចត់ក្នុងច្បាប់ អ.វ.ត.ក និងការបក ស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១។ ពួកគាត់បានវិភាគលើគោលការណ៍ វិមតិសង្ស័យដែលបានប្រយោជន៍ដល់ជនជាប់ចោទ។ ពួកគាត់បានវិភាគលើរបៀបធ្វើសេចក្តីសម្រេច នៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ និងវិភាគពីជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់ កម្ពុជា។ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចជំទាស់តាម របៀបសមហេតុផលណាមួយថា ការពិចារណាមលើជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា មិនមែនជាការពិចារណាដែលមានភាពពាក់ព័ន្ធ ឬក៏ថាសហចៅក្រមស៊ើបអង្កេតធ្វើឡើងដោយមិនបាន ពិនិត្យពិច័យឲ្យបានត្រឹមត្រូវ នៅពេលពួកគាត់បានសម្រេចថា វាមានឥទ្ធិពលលើសេចក្តីសម្រេចជារួម របស់ខ្លួនលើបញ្ហាយុត្តាធិការ។

[១០:៤៨:៤៩]

ការអះអាងថា វាជារឿងមិនសមរម្យ និងថាវាជាការព្យាយាមដកយុត្តាធិការបន្ថែមបំពេញពី តុលាការសាមញ្ញរបស់កម្ពុជាលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម ជាការបោះជំហានហួសឆ្ងាយជ្រុល ពេក។ វាហាក់ដូចជាយកពាក្យពេចន៍យ៉ាងធម្មតា ព្រមទាំងកម្មវត្ថុនិងគោលបំណងនៃវិធីសាស្ត្ររបស់ សហចៅក្រមស៊ើបអង្កេត ហើយបង្វិលដាំចុះក្រោមអ៊ីចឹង។

ដូចយើងខ្ញុំបានលើកឡើងក្នុងកថាខណ្ឌ៧ និងកថាខណ្ឌ៨ នៃសារណាជាលាយលក្ខណ៍អក្សរ ការសង្កេតរបស់សហចៅក្រមស៊ើបអង្កេតលើជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា មិនមាន អ្វីលើសពីការបង្ហាញឲ្យឃើញនូវវិធីសាស្ត្រមធ្យ័ត និងប្រកបដោយភាពប្រយ័ត្នប្រយែង ចំពោះបញ្ហា យុត្តាធិការឡើយ។ ការសង្កេតទាំងនេះ បានអនុញ្ញាតឲ្យសហចៅក្រមស៊ើបអង្កេតត្រិះរិះពិចារណាលើ យុត្តាធិការរបស់ អ.វ.ត.ក ក្នុងបរិវេណពាក់ព័ន្ធ និងកំណត់សម្គាល់ខ្ពស់ ហើយបន្ទាប់មកសម្រេចថា ការសង្កេតទាំងនេះ មានផលប៉ះពាល់លើដែនសមត្ថកិច្ចពួកគាត់ទេ។ គឺជាការពិចារណាដែលមានការ សមស្របដើម្បីឈានដល់ការពិចារណាសម្រេច និងធ្វើការច្រានចោលបទចោទ។

សហចៅក្រមស៊ើបអង្កេតបាន បញ្ជាក់យ៉ាងច្បាស់នៅក្នុងដីកាដំណោះស្រាយរបស់ពួកគាត់ថា ការវិភាគចំពោះបញ្ហាយុត្តាធិការតុលាការសាមញ្ញរបស់កម្ពុជា លើបទឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម

ត្រូវបានធ្វើឡើងដើម្បីវាយតម្លៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក និងទាញជាកំណត់នៃប្រភេទការទទួលខុសត្រូវខ្ពស់ប៉ុណ្ណោះ។ នៅក្នុងកថាខណ្ឌ២៥ នៃដីកាដំណោះស្រាយរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ថា សំណួរចោទគឺនៅត្រង់ថាតើអវត្តមាននៃយុត្តាធិការបំពេញបន្ថែមរបស់តុលាការសាមញ្ញកម្ពុជាលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម សុំដកស្រង់ "មានឥទ្ធិពលមកលើការអនុវត្តធន្ទានុសិទ្ធិរបស់យើងពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលទេ" ចប់ការដកស្រង់។ ការវែកញែកពិភាក្សារបស់សហចៅក្រមស៊ើបអង្កេតទៅលើបញ្ហាកង្វះយុត្តាធិការនៃតុលាការសាមញ្ញរបស់កម្ពុជា គឺប្រាកដណាស់ថា វាជាការចង្អុលបង្ហាញចាំបាច់មួយដែលឆ្លុះបញ្ចាំងឲ្យឃើញពីហេតុផលនៃសេចក្ដីសម្រេចរបស់ពួកគាត់ដែលថាអ្នកស្រី អ៊ឹម ចែម ស្ថិតនៅក្រៅដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ បើទោះបីជាមានការពិតដូចបានកត់សម្គាល់នៅក្នុងកថាខណ្ឌ២៥ នៃដីកាដំណោះស្រាយរបស់គាត់ ដកស្រង់៖ "វាថាអាចនឹងមានគម្លាតនិទណ្ឌភាពជាខ្លាំង" ចប់ការដកស្រង់។ វាជាការសម្រេចជាមូលដ្ឋានដែលមិនអាចទើបតែនឹងខុសឥឡូវ ដោយគ្រាន់តែមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចង់បានទិដ្ឋភាពខុសគ្នាឡើយ។ នេះគឺជាច្បាប់ មិនមែនបញ្ជីជម្រើសសម្រាប់ជ្រើសបានតាមចិត្តនោះទេ។

[១០:៥៤:០១]

តាមពិតប្រសិនបើសហចៅក្រមស៊ើបអង្កេត មិនបានពិចារណាលើបញ្ហាថាតើតុលាការសាមញ្ញរបស់កម្ពុជាអាចមាន ឬមិនមានយុត្តាធិការនោះទេ ហើយថាតើឥទ្ធិពលអ្វីខ្លះអាចកើតចេញពីរបៀបដែលសហចៅក្រមស៊ើបអង្កេតខ្លួនឯងបានប្រើជាមធ្យោបាយសម្រាប់ធ្វើការវាយតម្លៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ ដូចនេះវាអាចត្រូវបានផ្ដល់លទ្ធភាពដល់ភាគីនានាធ្វើការជំទាស់តវ៉ាលើការដែលសហចៅក្រមស៊ើបអង្កេតមិនបានយកលទ្ធផលនៃគម្លាតនិទណ្ឌភាព ទៅធ្វើការពិចារណានៅក្នុងការសម្រេចចិត្តរបស់ពួកគាត់ទេ។ និយាយម្យ៉ាងទៀត វាអាចត្រូវបានបើកចំហឲ្យភាគីទាំងអស់ធ្វើការទាមទារថាការសម្រេចច្រានចោលនូវបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ដោយសារតែបញ្ហានៃការខ្វះយុត្ត-- (សូមទោស) ដោយសារតែបញ្ហានៃការខ្វះយុត្តាធិការបុគ្គល ត្រូវបានរងផលប៉ះពាល់ដោយការខកខានមិនបានយកចិត្តទុកដាក់លើបញ្ហាពាក់ព័ន្ធ ហើយតពីនេះ អាចទទួលការវិនិច្ឆ័យ មានសំអាងហេតុជាលាយលក្ខណ៍អក្សរមួយបាន។

ដោយការយកចិត្តទុកដាក់ និងប្រយ័ត្នប្រយែងខ្ពស់បែបនេះ ត្រូវបានសហចៅក្រមស៊ើបអង្កេត

បំពេញហើយនោះ វាលែងមានទៀតហើយនូវការបើកចំហសម្រាប់ភាគីណាមួយក្នុងការដែលពួកគេគ្រាន់តែបង្ហាញពីចំណង់ចង់បាននូវអាការៈខាងក្រៅ ដោយប្រើមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ដូច្នោះបានទេ។ មិនបានថាការចង់បាននោះជាអ្វីនោះទេ វាច្បាស់ណាស់ថា គោលបំណងរបស់សហចៅក្រមស៊ើបអង្កេត គឺគ្រាន់តែធ្វើការវាយតម្លៃ ហើយនៅទីបំផុត គឺធ្វើការកំណត់នូវចរិតលក្ខណៈនៃឆន្ទានុសិទ្ធិរបស់ពួកគាត់។ វាមិនបានគាំទ្រអ្វីផ្សេងពីនេះ កុំថាឡើយនិយាយទៅដល់ការដកហូតនូវបុព្វសិទ្ធិរបស់តុលាការសាមញ្ញកម្ពុជា។ បើទោះណាជាសហចៅក្រមស៊ើបអង្កេតបានធ្វើខុសក្នុងការសន្និដ្ឋានថា តុលាការកម្ពុ-ជា តុលាការសាមញ្ញរបស់កម្ពុជាខ្វះយុត្តាធិការក៏ដោយ ក៏បន្ទុកធ្ងន់នៃការរកឃើញរបស់ពួកគាត់ គឺនៅត្រង់តែថា តើតុលាការសាមញ្ញរបស់កម្ពុជាមាន ឬគ្មានយុត្តាធិការ មិនបានជះឥទ្ធិពលដល់ការអនុវត្តនៃឆន្ទានុសិទ្ធិរបស់ខ្លួនដូចម៉េចខ្លះ ទាក់ទងនឹងបញ្ហាយុត្តាធិការបុគ្គល?

[១០:៥៨:២២]

មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហាក់ដូចជាមិនបង្ហាញពីការជំទាស់នឹងការរកឃើញនេះ ឬបើមិនដូច្នោះទេ ក៏ធ្វើការស្នើឲ្យឃើញថា ការរកឃើញទាក់ទងនឹងការអនុវត្តនូវសិទ្ធិអធិបតេយ្យភាពរបស់កម្ពុជា នាំឲ្យសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការទម្លាក់ការចោទប្រកាន់លើអ្នកស្រី អ៊ឹម ចែម។ ស្ថាប័ននានារបស់កម្ពុជាបានកំណត់រួចហើយ ពីការគ្មានយុត្តាធិការបំពេញបន្ថែមសម្រាប់ឧក្រិដ្ឋជនក្នុងសម័យខ្មែរក្រហម។

ឥឡូវនេះខ្ញុំសូមចំណុចទី៣ និងជាចំណុចចុងក្រោយ។ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានអះអាងនៅក្នុងសារណាជាលាយលក្ខណ៍អក្សរដូច្នេះថា៖ “សហចៅក្រមស៊ើបអង្កេតបានខំខ្នះខ្នែងធ្វើយ៉ាងណាឲ្យមានការដាក់ជំនួស នូវការយល់ឃើញរបស់តុលាការសាមញ្ញកម្ពុជាលើបញ្ហាយុត្តាធិការរបស់ពួកគេ ជាមួយនឹងការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេតវិញ។ ដូចដែលបានលើកឡើងក្នុងកថាខណ្ឌ១៤ ដល់កថាខណ្ឌ៣៥ នៃសារណាជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំ ការអះអាងរបស់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមិនបានបង្ហាញដោយភស្តុតាងដែលអាចរកបាននោះទេ។ ការវិភាគលើការអនុវត្តពីមុន និងនាពេលបច្ចុប្បន្ន គឺជាការចង្អុលបង្ហាញឲ្យឃើញថា ការពិតទៅស្ថាប័នរបស់ប្រទេសកម្ពុជាបានពិចារណាទុកជាយូរមកហើយ ថាមិនមានយុត្តាធិការ (សូមទោស) នឹងមិនមានយុត្តាធិការបំពេញបន្ថែមលើបញ្ហានេះទេ។ ជាក់ស្ដែងស្ថាប័នកម្ពុជាមួយចំនួនបានខិតខំអនុវត្តនូវសិទ្ធិអធិបតេយ្យភាពរបស់ខ្លួនក្នុងការកាត់

ទោសអតីតខ្មែរក្រហម ដោយបានពិចារណាលើកត្តានានា រួមមានដូចជា ការផ្សះផ្សាជាតិ ស្ថិរភាពនយោបាយ ឬដើម្បីផលប្រយោជន៍យុត្តិធម៌។ នេះគឺជាទស្សនៈនៅក្នុងអំឡុងពេលនៃកិច្ចចរចារបស់ អ.វ.ត.ក ហើយវានៅតែជាទស្សនៈមួយរក្សាដល់សព្វថ្ងៃនេះ។

របបខ្មែរក្រហមបានកើតឡើងជាង៤០ឆ្នាំកន្លងមកហើយ ស្ថាប័នកម្ពុជាជាច្រើនបានបង្ហាញពីភាពស្ទាក់ស្ទើររបស់ខ្លួនលើគំនិតនៃការចង់ផ្តន្ទាទោសបន្ថែម ក្រៅតែពីបុគ្គលមួយចំនួនដែលមានសំណុំរឿងនៅចំពោះមុខ អ.វ.ត.ក រួចហើយ។ ស្ថាប័នទាំងនេះបានផ្តល់ទម្ងន់ទៅលើភាពចាំបាច់នៃការផ្សះផ្សាជាតិសម្រាប់ប្រទេសមួយ ក្រោយពេលមានជម្លោះ ដូចជាកម្ពុជានេះ។ នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាដូចជាបានអំពាវនាវទៅកាន់អគ្គលេខាអង្គសហប្រជាជាតិថា នឹងគ្មានការកាត់ទោសបន្ថែមទៀតនោះទេ លើអតីតខ្មែរក្រហម។ ផ្ទុយពីជំហររបស់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងកថាខណ្ឌ១៧ ដល់២៥ នៃសារណាជាលាយលក្ខណ៍អក្សររបស់ពួកគាត់ ជំហរនេះត្រូវបានទទួលយករួចហើយ ពីសំណាក់នៃកិច្ចចរចារបស់ អ.វ.ត.ក ដូចដែលបានរៀបរាប់នៅក្នុងចម្លើយតបជាលាយលក្ខណ៍អក្សររបស់យើងខ្ញុំ ទៅកាន់មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី (ឯកសារ D308/3/1/18 នៅកថាខណ្ឌ១៦ ដល់២២)។

[១១:០៤:១៩]

ក្រុមអ្នកជំនាញត្រូវបានតែងតាំងដោយអង្គការសហប្រជាជាតិ ដើម្បីវាយតម្លៃនូវលទ្ធភាពដែលអាចនាំយកខ្មែរក្រហមមកកាត់ក្តីបានសន្និដ្ឋានថា ការកាត់សេចក្តីលើជនដែលខ្មែរក្រហមភាគច្រើននឹងមិនអាចរ៉ាប់រងទៅរួច ទាំងផ្នែកហិរញ្ញវត្ថុ និងសម្ភារៈ ដែលវាអាចជាការរាំងស្ទះដល់ការផ្សះផ្សាជាតិ ហៅថា ការទទួលខុសត្រូវរបស់ជនដែលថ្នាក់ក្រោម គឺជាបញ្ហាច្បាប់ដ៏ស្មុគស្មាញមួយ។ ក្រុមអ្នកជំនាញបានបន្ថែមទៀតថា សុំដកស្រង់៖ “ការជំនុំជម្រះថ្នាក់ជាតិដើម្បីរៀបចំក្រោមច្បាប់កម្ពុជា គឺមិនអាចធ្វើទៅបានទេ” ចប់ការដកស្រង់។ ភាគីនៃកិច្ចចរចា អ.វ.ត.ក ដែលជារាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានលុបចោលនូវការបង្កើតយន្តការបញ្ជូនទៅកាន់តុលាការសាមញ្ញរបស់កម្ពុជា បើទោះណាជាតុលាការទាំងនោះ មានចំណេះដឹងពីយន្តការទាំងឡាយដែលមាននៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ សម្រាប់អតីតយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាក៏ដោយ។

មានសំណួរសួរចោទឡើង ថាតើភស្តុតាងអ្វីខ្លះនាំឱ្យមេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំង

ខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំអាងលើ ដើម្បីកាត់យល់នូវការចង្អុលបង្ហាញ ឬក៏ភាពមិនច្បាស់ណាស់ណាមួយនៅក្នុងការអនុវត្តពេលបច្ចុប្បន្នដែលត្រូវបានអនុវត្តដោយប្រទេសកម្ពុជា ក្នុងកថាខណ្ឌ២៦ ដល់កថាខណ្ឌ២៨ នៃសារណាលាយលក្ខណ៍អក្សររបស់ពួកគាត់ ពួកគាត់បានអះអាងថា ខ្ញុំសុំដកស្រង់៖ “រាជរដ្ឋាភិបាលកម្ពុជាបានបន្តលើកឡើងពីការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព ដែលរឿងសំខាន់សម្រាប់ការដោះស្រាយមរតករបស់ខ្មែរក្រហម” ចប់ការដកស្រង់។ មកធ្វើជាភស្តុតាងដើម្បីបញ្ជាក់ថា ការកាត់ទោសនៅកម្រិតថ្នាក់ជាតិ គឺអាចធ្វើទៅបាន ហើយថា សុំដកស្រង់៖ “រហូតមកដល់ពេលនេះ ការពិតជាក់ស្តែងដែលថាគ្មានការស៊ើបអង្កេត ឬការកាត់ទោស មិនមែនមានន័យថា ការស៊ើបអង្កេត ឬការកាត់ទោសទាំងនោះមិនអាចធ្វើទៅរួចជាលក្ខណៈផ្លូវច្បាប់នោះទេ” ចប់ការដកស្រង់។ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមថា ត្រង់កថាខណ្ឌ២៨ដល់៣១ នៃសារណាលាយលក្ខណ៍អក្សរ ថាការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត គឺផ្ទុយនឹងច្បាប់កម្ពុជា ពីព្រោះតុលាការកម្ពុជាអាចសម្រេចនៅពេលអនាគត ដើម្បីអនុញ្ញាតឲ្យមានការកាត់ទោសលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។

[១១:០៨:៥៣]

សំអាងហេតុទាំងនេះ ជាសំអាងហេតុដែលមានភាពស្រពេចស្រពិល ហើយនៅទីបញ្ចប់ទៅគឺមិនអាចអន្ទងឲ្យជឿជាក់បានទេ ដូចដែលយើងខ្ញុំបានលើកឡើងក្នុងសារណាជាលាយលក្ខណ៍អក្សរត្រង់កថាខណ្ឌ២៣ ដល់៣៥ “នៅបន្ទាប់ពីការធ្វើសេចក្តីព្រាងកិច្ចព្រមព្រៀងដែលនាំឲ្យមានការកកើត អ.វ.ត.កមក ស្ថាប័នរដ្ឋពាក់ព័ន្ធទាំងអស់បានប្រតិបត្តិតាមព្រមៗគ្នា ដោយឥតស្រពេចស្រពិលឡើយ។” ចំណុចជាក់លាក់ ភាពអសកម្មនៃនីតិបញ្ញត្តិនៅកម្ពុជា ទាក់ទងទៅនឹងតុលាការសាមញ្ញរបស់ខ្លួន ដើម្បីអនុញ្ញាតឲ្យមានការកាត់ទោសលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនៅកម្រិតជាតិជាមេរៀនមួយ។ ជាឧទាហរណ៍ ខណៈដែលអាជ្ញាយុកាលសម្រាប់ការកាត់ទោសលើឧក្រិដ្ឋកម្មថ្នាក់ជាតិបានពង្រីកទៅ៣០ឆ្នាំតាមរយៈកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងដើម្បីធ្វើការកាត់ទោសអតីតខ្មែរក្រហមនៅចំពោះមុខ អ.វ.ត.ក មិនមានការឈានដល់កិច្ចព្រមព្រៀងដូច្នេះណាមួយបានធ្វើឡើងទាក់ទងនឹងមាត្រា៦១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះទេ។ និយាយម្យ៉ាងទៀត តុលាការសាមញ្ញថ្នាក់ជាតិរបស់កម្ពុជានៅតែប្រកាន់យកអាជ្ញាយុកាលកំណត់ត្រឹមរយៈពេល១០ឆ្នាំ សម្រាប់ការកាត់ទោសលើបទឧក្រិដ្ឋនានា។ ដូច្នេះនេះគឺជាភស្តុតាងដ៏ស៊ីសង្វាក់ និងយ៉ាង

ច្បាស់លាស់ ដែលបង្ហាញឲ្យឃើញថា កម្ពុជាមិនមានបំណងផ្តល់ឲ្យតុលាការសាមញ្ញរបស់ខ្លួននូវយុត្តាធិការដែលតម្រូវឲ្យធ្វើការកាត់ទោសលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនោះឡើយ។

អមជាមួយនឹងអសកម្មនេះ អវត្តមាននៃយុត្តាធិការបំពេញបន្ថែម ក៏ត្រូវបានបញ្ជាក់បន្ថែមលើការអនុវត្តរបស់តុលាការកម្ពុជាអស់រយៈពេល៣០ឆ្នាំកន្លងទៅ។ គ្មានការកាត់ទោសលើអតីតខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងអំឡុងពេលពាក់ព័ន្ធនេះទេ។ ក្នុងចំណោមសំណុំរឿងដែលរកបានជាសាធារណៈចំនួន២៥៥ករណី ដែលបានជំនុំជម្រះហើយដោយតុលាការកំពូលរបស់កម្ពុជា គឺមិនមានសំណុំរឿងណាមួយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមនោះទេ។

[១១:១២:៥៧]

នៅក្នុងអំណះអំណាងផ្ទាល់មាត់កាលពីម្សិលមិញ មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បានស្នើសុំឲ្យអង្គបុរេជំនុំជម្រះបញ្ជាក់ថា ជំហររបស់សហចៅក្រមស៊ើបអង្កេត គឺមានកំហុសដោយសារថា អង្គការសហប្រជាជាតិនឹងមិនធ្វើការដាក់ទណ្ឌកម្ម ឬក៏ផ្តល់ការអនុញ្ញាតឲ្យមានលើការលើកលែងទោសចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរនោះទេ។ ចំណុចសំខាន់នៃអំណះអំណាងនេះ គឺថាការលើកលែងទោសតាមព្រឹត្តិហេតុបែបនេះ ផ្ទុយនឹងកាតព្វកិច្ចរបស់កម្ពុជា ក្រោមច្បាប់អន្តរជាតិ។ ការលើកឡើងដូច្នេះ គឺជាការបង្ហាញនូវភាពងាយស្រួលជ្រុលចំពោះការឆ្លើយតបរបស់សហគមន៍អន្តរជាតិទៅលើស្ថានការណ៍ក្រោយជម្លោះ ដែលមានទម្រង់ជាសមីការជាគូៗ ឬគ្មានលទ្ធភាព ឬចំណុចកណ្តាលណាមួយសម្រាប់ពិចារណាបាន ពោលគឺឲ្យតែមានការចោទប្រកាន់ គឺសុទ្ធតែគ្មានអាណត្តិ ហើយការលើកលែងទោស គឺជារឿងមិនស្របច្បាប់។ ទោះជាយ៉ាងណាក្តី ការពិតគឺមិនមែនមានតែសឬខ្មៅនោះទេ ដូចបានលើកឡើងនៅក្នុងចម្លើយតបរបស់យើងខ្ញុំ ត្រង់កថាខណ្ឌ១៧ (សូមទោស) កថាខណ្ឌ១៤ និង១៥ ការអនុវត្តរបស់រដ្ឋបានឆ្លុះបញ្ចាំងឲ្យឃើញថា ការលើកលែងទោសដោយភាពត្រឹមត្រូវ គឺជាករណីស្របច្បាប់នៃដំណើរការស្តារនីតិសម្បទានៅក្នុងស្ថានការក្រោយជម្លោះ។ តាមពិតបញ្ហានេះ ត្រូវបានទទួលយកដោយការពិចារណាតាមផ្លូវតុលាការ។ នៅក្នុងសេចក្តីសម្រេច ឆ្នាំ១៩៩៨ របស់តុលាការយុត្តិធម៌នៃចក្រភពអង់គ្លេស និងប្រទេសវែល នៅក្នុងសំណុំរឿង ពីណូសេ ៣០៨/៣/១/១៨.១.៤ ERN អង់គ្លេស 01540854 ដល់ 55 ត្រង់កថាខណ្ឌ១៥ នៃចម្លើយរបស់យើងខ្ញុំ។ ចៅក្រម ឡូយដ៍ បានកត់សម្គាល់ពី ខ្ញុំដកស្រង់៖ “ការអនុវត្តយ៉ាងទូលំទូលាយនៃការលើកលែងទោស ចំពោះជនដែលបានប្រព្រឹត្តប្រឆាំងមនុស្សជាតិ” ចប់ដកស្រង់។ សេចក្តីសម្រេចរបស់ចៅក្រម

ដែលបន្តសង្កេតឃើញយ៉ាងច្បាស់ថា ខ្ញុំដកស្រង់៖ “មានខ្លះបានទាំងទទួលការអនុគ្រោះទោសពីអង្គការសហប្រជាជាតិតាមមធ្យោបាយដើម្បីស្តារសន្តិភាព និងស្តាររដ្ឋាភិបាលលំនាំប្រជាធិបតេយ្យ។ សំខាន់បំផុត ចៅក្រម ឡួយដ៍ បានសង្កេតឃើញថា វាមិនមែនជាការថ្លែងថា ការលើកលែងទោសទាំងនេះ គឺជាការធ្វើផ្ទុយនឹងច្បាប់អន្តរជាតិ ក្នុងការខកខានមិនបានកាត់ទោសជនដែលដល់នោះទេ និងថាការអនុវត្តរបស់រដ្ឋបច្ចុប្បន្ននេះ មិនគាំទ្រកាតព្វកិច្ចក្នុងការកាត់ទោសរាល់សំណុំរឿងទេ។” ចប់ការដកស្រង់។ ប្រាកដណាស់ ការអះអាងរបស់មេធាវីអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការលើកលែងទោស មិនទទួលបានការគាំទ្រទាំងនៅក្នុងការអនុវត្តរបស់រដ្ឋ ឬច្បាប់អន្តរជាតិឡើយ។ ទោះជាយ៉ាងណាក៏ដោយ ក៏មេធាវីតំណាងអតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគួរចងចាំថា អវត្តមាននៃយុត្តាធិការបន្ថែមបំពេញ ដូចដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ និងការអនុវត្តរបស់ស្ថាប័ននានារបស់កម្ពុជាប៉ុន្មានឆ្នាំមកនេះ មិនមែនមានន័យថា ជនរងគ្រោះនៃរបបខ្មែរក្រហម គឺត្រូវបានបំភ្លេចចោលនោះឡើយ។ ការចោទប្រកាន់តាមបទព្រហ្មទណ្ឌ គឺជាផ្នែកមួយនៃដំណើរការផ្សះផ្សាជាតិ។

[១១:១៩:៣៣]

ស្ថាប័នកម្ពុជាបានអនុវត្តយ៉ាងសកម្មក្នុងការប្រគល់ការងារតាមរូបភាពខុសៗគ្នា រួមមានដូចជារបៀបមិនមែនជាការកាត់ទោស និងមិនមែនតាមលក្ខណៈច្បាប់ ព្រមទាំងមធ្យោបាយផ្សេងៗទៀត ដើម្បីធ្វើយ៉ាងណាឲ្យបានទទួលបានយុត្តិធម៌សម្រាប់ជនរងគ្រោះ។ ឧទាហរណ៍ គឺមានកម្មវិធីមួយចំនួនត្រូវបានបង្កើតឡើងដើម្បីផ្តល់ការអប់រំ និងការគាំទ្រជនរងគ្រោះ ដែលមធ្យោបាយសម្រាប់ធ្វើការស្តារនីតិសម្បទា ទាក់ទងនឹងព្រឹត្តិការណ៍នានាដែលបានកើតឡើងអំឡុងសម័យខ្មែរក្រហម។ ក្នុងចំណោមកម្មវិធីទាំងនោះ ក្រសួងទេសចរណ៍បានសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងការបើកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងដើម្បីឧទ្ទិសដល់ការចងចាំ ការផ្សះផ្សា និងការកសាងសន្តិភាពនៅក្នុងតំបន់ការពារចុងក្រោយមួយក្នុងចំណោមតំបន់ការពារផ្សេងទៀតរបស់ខ្មែរក្រហម និងជាតំបន់របស់តាម៉ុក។

មានគំនិតផ្តួចផ្តើមមួយចំនួនផ្សេងទៀត រួមមានការកែទម្រង់នៅក្នុងកម្មវិធីសិក្សាចាប់តាំងពីឆ្នាំ២០០៨មក ក្រសួងអប់រំយុវជន និងកីឡា ព្រមទាំងមជ្ឈមណ្ឌលឯកសារកម្ពុជាបានអនុវត្តគម្រោងដ៏ធំៗនៅទូទាំងប្រទេសដើម្បីកែទម្រង់កម្មវិធីសិក្សារបស់សាលា ហើយបានបន្ថែមវគ្គសិក្សាលើប្រវត្តិសាស្ត្រ

ខ្មែរក្រហមនៅកម្រិតមធ្យមសិក្សា និងនៅសាកលវិទ្យាល័យ ព្រមទាំងបានផ្តល់ការហ្វឹកហ្វឺនដល់គ្រូបង្រៀនមធ្យមសិក្សា និងសាស្ត្រាចារ្យជាច្រើននាក់ទៀត។ ថ្មីៗនេះអនុស្សរណៈនៃការយោគយល់គ្នាមួយបានត្រូវចុះហត្ថលេខារវាងក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់គម្រោងឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ដើម្បីផ្តល់ការណែនាំពីរ ខ្ញុំសុំដកស្រង់៖ "វិធីសាស្ត្របង្រៀនប្រវត្តិសាស្ត្រតាមបែបទំនើប និងមានប្រសិទ្ធភាពក្នុងការបង្រៀន និងរៀនពីប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ" ចប់ការដកស្រង់ សម្រាប់ជូន (សូមទោស) ផ្តល់ជូនដល់គ្រូបង្រៀនមធ្យមសិក្សា និងសាស្ត្រាចារ្យនៅទូទាំងប្រទេស។ គោលដៅនៃគម្រោងនេះ គឺដើម្បី ខ្ញុំដកស្រង់៖ "ធានាឲ្យសិស្សនិងនិស្សិតទូទាំងប្រទេសទទួលបានចំណេះដឹង និងការយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឲ្យកាន់តែសុក្រឹតនៅ (សូមទោស) ក៏ដូចជាអប់រំបណ្តុះបណ្តាលតវិយាបទនៃការអត់ឱន ការយោគយល់គ្នាអធ្យាស្រ័យគ្នា និងការផ្សះផ្សា" ចប់ការដកស្រង់។

[១១:២៣:៣៦]

សរុបមក ជនរងគ្រោះពីរបបខ្មែរក្រហមមិនត្រូវបានបំភ្លេចចោលនោះទេ ខណៈប្រជាពលរដ្ឋដែលមានការគិតសមហេតុសមផល និងមានយុត្តិធម៌អាចនឹងមិនយល់ស្របចំពោះប្រសិទ្ធភាពនៃការយកចិត្តទុកដាក់នេះ និងវិធីសាស្ត្រនេះក៏ដោយ ក៏គេមិនអាចលើកឡើងថាកម្ពុជាគ្មានសិទ្ធិធ្វើការសម្រេចទាំងនោះដែរ។ សំខាន់ជាងនេះទៅទៀត សម្រាប់គោលបំណងបច្ចុប្បន្ន វាមិនមែនជាការសំអាងសមហេតុសមផលក្នុងការដែលថា ការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេតលើការអនុវត្តអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាគឺមិនត្រឹមត្រូវ កុំថាឡើយថាការលើកឡើងនេះ វានាំឲ្យដីកាដំណោះស្រាយគ្មានសុពលភាព ប្រាសចាកពីបទដ្ឋានដែលបានរំពឹងទុក។

សេចក្តីសន្និដ្ឋាន សរុបសេចក្តីមក សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត គ្មានភាពឥតសមហេតុផលឡើយ ហើយការសង្កេតរបស់ពួកគាត់ទាក់ទងនឹងជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាសោតទៀត ក៏មិនបានធ្វើទៅដោយឥតសុចរិតភាពដែរ។ ពួកគាត់គ្រាន់តែបានថ្លែងឡើងនូវការពិតពីភាពចាំបាច់ដែលតម្រូវឲ្យមានចំពោះនិយមន័យនៃយុត្តាធិការបុគ្គលនៅ អ.វ.ត.ក ហើយជាលទ្ធផលក៏បានសម្រេចធ្វើការច្រានចោលបទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម ដោយសារតែខ្វះយុត្តាធិការបុគ្គល។

អង្គបុរេជំនុំជម្រះមិនមានមុខងារសម្រាប់ផ្តល់ជាមធ្យោបាយ ដែលបានស្នើដោយមេធាវីតំណាង

អតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំឲ្យអង្គបុរេជំនុំជម្រះប្រកាសថា តុលាការសាមញ្ញរបស់កម្ពុជាអាចធ្វើការដោះស្រាយបាននូវបញ្ហាចោទ ស្តីពីយុត្តាធិការបំពេញបន្ថែមលើឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហម។ នេះជាការបកស្រាយខុសលើតួនាទីរបស់អង្គបុរេជំនុំជម្រះ និងលក្ខខណ្ឌនៃសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត។ ការសង្កេតរបស់សហចៅក្រមស៊ើបអង្កេតមិនបានបណ្តាលឲ្យមានព្យសនកម្មអ្វីដល់អតីតអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឡើយ ហើយក៏គ្មានខ្លឹមសារព្យសនកម្មអ្វីមួយ ដែលធានា ដែលអាចធានាឲ្យមានការធ្វើអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះឡើយ។

ខ្ញុំសូមអរគុណអង្គបុរេជំនុំជម្រះ។ ឥឡូវនេះខ្ញុំសូមអនុញ្ញាតប្រគល់តួនាទីបន្តដល់សហមេធាវីអន្តរជាតិរបស់ខ្ញុំ ដើម្បីធ្វើការឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ។

[១១:២៨:០៨]

**ប្រធានអង្គបុរេ៖**

សូមអរគុណលោកមេធាវី ហើយសូមអញ្ជើញមេធាវីការពារឲ្យជនជាប់ចោទអន្តរជាតិឡើងថ្លែងសេចក្តីសន្និដ្ឋានរបស់ខ្លួន។ សូមអញ្ជើញ!

**លោក វេញ ហ្សកដាហ្ស៖**

ជម្រាបសួរលោកប្រធាន លោកចៅក្រម ក៏ដូចជាអស់លោក លោកស្រីទាំងអស់នៅក្នុងបន្ទប់សវនាការ។ ពេលដែលនៅសេសសល់នេះ ខ្ញុំនឹងលើកយកចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ ជាពិសេសខ្ញុំលើកយកសំអាងហេតុតែម្តង ជាពិសេសផ្នែកខាងអង្គសេចក្តី--

**ប្រធានអង្គបុរេ៖**

សូមផ្អាកមួយនាទី ឬពីរនាទីដើម្បីដូរស៊ីឌី។ បាទ សូមផ្អាកសិន!

**លោក វេញ ហ្សកដាហ្ស៖**

*(គ្មានការបកប្រែ)*

*(សម្រាករយៈពេលខ្លី)*

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញបន្តទៀតបាទ!

**លោក វេញ ហ្សកដាហ្ស៖**

សូមអរគុណលោកប្រធាន។ សេចក្តីសម្រេច អង្គសេចក្តីផ្នែកបណ្តឹងឧទ្ធរណ៍នេះគឺថា សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញលើបទដ្ឋាននៃការពិនិត្យឡើងវិញ ជំនួសឲ្យការអនុវត្តនូវបទដ្ឋានពិនិត្យឡើងវិញ សហព្រះរាជអាជ្ញាបានស្នើសុំឲ្យអង្គបុរេជំនុំជម្រះដាក់ជំនួសមកវិញ ដាក់ជំនួសទៅដោយការវិនិច្ឆ័យរបស់សហចៅក្រមស៊ើបអង្កេត។ យើងខ្ញុំមានសំអាងហេតុចំនួនប្រាំមួយ។ ទី១ ខ្ញុំសូមលើកយកនូវបទដ្ឋាននៃការពិនិត្យឡើងវិញ មុននឹងចូលទៅដល់សំអាងហេតុទី១។ គោលការណ៍ពាក់ព័ន្ធទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញនេះ គឺមាននៅក្នុងកថាខណ្ឌ១០នៃបណ្តឹងឧទ្ធរណ៍។ កថាខណ្ឌ១០នេះ សូមដកស្រង់៖ “អង្គបុរេជំនុំជម្រះបានរកឃើញថា មានយុទ្ធសាស្ត្រតុលាការអន្តរជាតិស្តីអំពីបណ្តឹងឧទ្ធរណ៍គឺថាបើមានកំហុសអង្គច្បាប់ត្រូវតែយកមកពិនិត្យសាជាថ្មីដើម្បីពិចារណា ថាតើសេចក្តីសម្រេចអង្គច្បាប់ត្រឹមត្រូវដែរ ឬក៏អត់។ ហើយក៏ដូចជាកំហុសអង្គហេតុដែលត្រូវយកពិនិត្យឡើងវិញ ថាតើវាអាចឈានទៅដល់ការសម្រេចទៅលើអង្គហេតុចំពោះមុខដែរ ឬក៏អត់។”

[១១:៣០:៥៥]

ក្នុងការឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិនេះ ហើយក៏បានលើកយកលក្ខខណ្ឌស្មុគស្មាញមួយចំនួននៅក្នុងកថាខណ្ឌ៤ នៃការឆ្លើយតប។ សហព្រះរាជអាជ្ញាបានលើកឡើងថា នៅពេលដែលតុលាការជាន់ខ្ពស់អនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន ដែលសំអាងទៅលើកំហុស ហើយនិងការបកប្រែច្បាប់ដែលមិនបានត្រឹមត្រូវ ក៏ដូចជាការឈានទៅដល់ការសម្រេចទៅលើអង្គហេតុ។ ចំណុចនេះ គឺថាមិនត្រឹមត្រូវទេ។ មិនអាចជួយអ្វីបានទេ ដោយសារថាមិនបានលើកឡើងនូវប្រភេទនៃកំហុសអង្គច្បាប់ ឬប្រភេទនៃកំហុសអង្គហេតុ ដែលប៉ះពាល់ទៅដល់សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិនោះទេ។ ហើយសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា រាល់កំហុសអង្គច្បាប់ ឬអង្គហេតុ ទោះបីជាវាធ្ងន់ធ្ងរ ឬមិនធ្ងន់ធ្ងរក៏ដោយ ក៏ត្រូវតែបញ្ជូនសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិនេះ ឲ្យសម្រេចឡើងវិញ។ ហើយនៅក្នុងករណីនេះ គឺសេចក្តីសម្រេចពាក់ព័ន្ធថា អ៊ឹម ចែម មិនស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ។

យោងទៅតាមសហព្រះរាជអាជ្ញាអន្តរជាតិ ទាំងអស់នេះតម្រូវឲ្យមានការបញ្ជាក់អំពីកំហុសអង្គច្បាប់ ឬក៏អង្គហេតុ ហើយអង្គបុរេជំនុំជម្រះត្រូវតែធ្វើអន្តរាគមន៍ ហើយដូចដែលបានបញ្ជាក់នៅក្នុងកថាខណ្ឌ៣ នៃបណ្តឹងឧទ្ធរណ៍ សូមដកស្រង់៖ “កំហុសអង្គច្បាប់ ឬអង្គហេតុដែលត្រឹមត្រូវនោះ បើវា

មាននោះ គឺត្រូវបញ្ជូនសំណុំនោះ ត្រឡប់ទៅសហចៅក្រមស៊ើបអង្កេត ឬក៏អង្គបុរេជំនុំជម្រះ គឺថាអាចនឹងវាយតម្លៃឡើងវិញទៅលើករណីនេះតែម្ដង។" នៅក្នុងសារណារបស់យើង គឺវាមិនមានវិធីសាស្ត្រអ្វីធ្ងន់ធ្ងរពាក់ព័ន្ធទៅនឹងច្បាប់ ឬក៏ថាបទដ្ឋាននៃបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ។ ការខកខានមិនបានបង្ហាញអំពីកំហុសអង្គច្បាប់ ឬក៏អង្គហេតុ និងការពន្យល់ថាតើវាប៉ះពាល់ទៅដល់សេចក្ដីសម្រេចទាំងអស់យ៉ាងណានោះ នោះគឺជាកំហុសតែផ្នែកខាងសម្ភារៈដែលមិនអាចបំភ្លេចបាននោះឡើយ។

សរុបមក មិនមានតុលាការអន្តរជាតិ ឬតុលាការកូនកាត់ណាមួយ ឬដំណើរការបណ្ដឹងឧទ្ធរណ៍ធ្វើការបែបនេះនោះទេ។ ដូចខ្ញុំបានលើកឡើងនៅក្នុងចម្លើយតបរបស់យើងខ្ញុំ កថាខណ្ឌ១០១។ តុលាការជាន់ខ្ពស់ប្រហែលជាអាចមានការច្រានចោល ហើយប្រហែលជានឹងមិនយកមកពិចារណាទៅលើការជំទាស់តវ៉ា ឬក៏វាយតម្លៃថាភស្តុតាងពាក់ព័ន្ធទាំងនេះ គឺថាមិនមានទម្ងន់ត្រឹមត្រូវ ឬមិនបានវាយតម្លៃឲ្យបានត្រឹមត្រូវ ឬក៏មិនអាចត្រូវបានបកស្រាយតាមលក្ខណៈពិសេសណាមួយនោះទេ។

[១១:៣៤:៣៤]

អ.ប.ជ ដូចដែល អ.ប.ជ បានសម្រេចពីមុនរួចមកហើយ ទទ្បីករណ៍ សូមដកស្រង់៖ "ដែលមិនសក្ដានុពលបណ្ដាលឲ្យមានការប៉ះពាល់ទៅដល់សេចក្ដីសម្រេចដែលរងការជំទាស់ ដែលត្រូវធ្វើការពិនិត្យឡើងវិញ ឬធ្វើការកែប្រែនេះ អាចត្រូវបានបដិសេធចោលភ្លាមៗ ឬក៏មិនត្រូវបានយកមកពិចារណាទៅលើអង្គសេចក្ដីរបស់វាទេ។" លក្ខខណ្ឌដែលត្រឹមត្រូវពាក់ព័ន្ធនៅក្នុងចម្លើយតបរបស់យើងត្រង់កថាខណ្ឌ១០ យើងបានរំឭកឡើងវិញ អំពីសេចក្ដីសម្រេច ក.ស.ច.ស នៅកថាខណ្ឌ៩ ដែលថាការវាយតម្លៃទៅលើលក្ខខណ្ឌនៃអ្នកទទួលខុសត្រូវជាន់ខ្ពស់ទៅលើផ្នែកយុត្តាធិការបុគ្គលនៅ អ.វ.ត.ក គឺជាសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិដ៏ទូលំទូលាយ។ ប៉ុន្តែមិនមានការវាយតម្លៃទាំងស្រុងនោះទេ អង្គជំនុំជម្រះតុលាការកំពូល ក៏បានសម្រេចតម្កល់វិធីសាស្ត្រនេះដែរ។

យោងទៅតាមមូលដ្ឋាននេះ មេធាវីការពារក្ដីជំទាស់តវ៉ាថា អ.ប.ជ អាចសម្រេចទៅលើឆន្ទានុសិទ្ធិ គឺត្រូវតែសម្រេចតែឲ្យបានត្រឹមត្រូវទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួនតែប៉ុណ្ណោះ។ មេធាវីការពារក្ដីបានលើកឡើងថា នៅក្នុងសំណុំរឿង០០២ សេចក្ដីសម្រេចស្ដីពីបណ្ដឹងឧទ្ធរណ៍ដែលស្នើសុំឲ្យស្វែងរកភស្តុ-តាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម គឺឯកសារ D164/3/6 កថាខណ្ឌ២៦ "សុំឲ្យពិនិត្យសេចក្ដីសម្រេចតាមឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែមិនឲ្យសម្រេចជំនួសសហចៅក្រមស៊ើប

អង្កេតនោះទេ។" បញ្ចប់ការដកស្រង់។

ចំណុចចាប់ផ្តើមនេះ ជាចំណុចមួយដែលត្រូវចាប់ផ្តើមពិនិត្យមើលនូវអ្វីដែលតុលាការកំពូលបាន លើកឡើងអំពីឆន្ទានុសិទ្ធិពាក់ព័ន្ធទៅនឹងជនជាប់ចោទនៅតុលាការនេះ។ ក្នុងសំណុំរឿង០០១ ឯកសារ F28 កថាខណ្ឌ៧០ សុំដកស្រង់៖ "ដូចដែលតុលាការ អាយ.ស៊ី.ធី.វ៉ាយ និង អាយ.ស៊ី.ធី.អ័រ ជនជាប់ចោទនៅចំពោះមុខ អ.វ.ត.ក មិនអាចបដិសេធចំពោះយុត្តាធិការរបស់សាលាដំបូងដោយសារ សហចៅក្រមស៊ើបអង្កេតមិនបានកម្រិតអំពីការចោទប្រកាន់ចំពោះមេដឹកនាំជាន់ខ្ពស់ ឬអ្នកទទួលខុសត្រូវជាន់ខ្ពស់ ដោយមិនបានបង្ហាញឲ្យឃើញថា សហចៅក្រមស៊ើបអង្កេតហ្នឹងគឺថាបានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួននោះទេ"។ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ៨០ នៃសេចក្តីសម្រេចដដែលនេះ សុំដកស្រង់៖ "ព្រះរាជអាជ្ញាតទល់នឹងព្រីម៉ា សាលាឧទ្ធរណ៍របស់តុលាការ អេស.ស៊ី.អេស.អិល បានកត់សម្គាល់ថា មានករណីមួយចំនួននោះគឺត្រូវបានសម្រេចតាមឆន្ទានុសិទ្ធិ" សុំដកស្រង់ "ដោយការធ្វើសម្រេចត្រឹមត្រូវ និងប្រកបដោយវិជ្ជាជីវៈ" ឬក៏អាចនិយាយម្យ៉ាងទៀតបានថា ដូចដែលបានលើកឡើងនៅក្នុងចម្លើយតប របស់យើងនៅកថាខណ្ឌ១៤ ហើយដូចបានសម្រេចនៅក្នុងសំណុំរឿង០០២ គឺសេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ស្នើសុំឲ្យធ្វើការស៊ើបអង្កេតទៅលើអ្នកស្រីអៀង ធីរិទ្ធ គឺឯកសារ D353/2/3 កថាខណ្ឌ៨ ស្តីអំពីការអនុវត្តឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត។

[១១:៣៨:៣៣]

នៅក្នុងកថាខណ្ឌ១១ មេធាវីការពារក្តីក៏បានចង្អុលបង្ហាញនូវយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះដែលលើកឡើងថា តាមការពិនិត្យមើលរបស់តុលាការជាន់ខ្ពស់ទៅលើសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិគឺថា ឃើញថាម្ចាស់បណ្តឹងឧទ្ធរណ៍បានបង្ហាញថាមានកំហុសមួយក្នុងចំណោមកំហុសបីប្រភេទ គឺកំហុសអង្គច្បាប់ដែលធ្វើឲ្យសេចក្តីសម្រេចនោះ គឺថាពុំមានសុពលភាព ហើយសេចក្តីសម្រេចហ្នឹងគឺជាការអនុវត្តនូវ ជាការបំពេញយុត្តិធម៌មួយមិនបានត្រឹមត្រូវ ឬថាសេចក្តីសម្រេចនោះមិនសមហេតុផលដែល ក.ស.ច.ស ខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួននោះទេ។ អ៊ីចឹងកំហុសអង្គច្បាប់ ឬកំហុសអង្គហេតុគឺជាករណីមួយចាំបាច់បំផុត ហើយដែលសេចក្តីសម្រេចនេះអាចនឹងត្រូវចាត់ទុកថា ពុំមានសុពលភាព។ អាចនិយាយម្យ៉ាងទៀតបាន កំហុសតែមួយមុខ ឬក៏រួមគ្នានេះ ត្រូវតែមានសេចក្តីសម្រេច ដែលសម្រេចឡើងដោយមិនបានត្រឹមត្រូវ មិនមានសុចរិតភាពនោះ ឬក៏ថាដោយការរំលោភ

ទៅលើឆន្ទានុសិទ្ធិរបស់ខ្លួន។ ដូច ក.ស.ព បាទឥឡូវដកស្រង់៖ “វាតម្រូវឱ្យមានលក្ខខណ្ឌត្រួតគ្នាពីរ” នេះគឺជាបទដ្ឋានតុលាការជាន់ខ្ពស់ដែលអនុញ្ញាតឱ្យ អ.ប.ជ ធ្វើអន្តរាគមន៍ដោយមានកម្រិត។

លើសពីនេះទៅទៀត សហព្រះរាជអាជ្ញាអន្តរជាតិគឺថា បានជំទាស់តវ៉ាថា សហចៅក្រមស៊ើបអង្កេតគឺថាបានបកស្រាយច្បាប់មិនបានត្រឹមត្រូវនោះទេ។ ពួកគេបានជំទាស់តវ៉ាតាមរយៈភាពសមហេតុផលរបស់មេធាវីការពារក្តី ទោះបីជាមានមូលដ្ឋានច្បាប់ សេចក្តីសម្រេចទៅលើមូលដ្ឋានច្បាប់ក្តី គឺថាមិនមានលទ្ធភាពសម្រាប់ឱ្យភាគីប្តឹងឧទ្ធរណ៍ ឬក៏ អ.ប.ជ ហ្នឹងពិនិត្យមើលឡើងវិញនោះទេ លើកលែងតែបង្ហាញច្បាស់ថា សេចក្តីសម្រេចនោះគឺធ្វើឡើងដោយការរំលោភឆន្ទានុសិទ្ធិ។ បទដ្ឋាននេះ លុះណាតែអង្គជំនុំជម្រះជាន់ខ្ពស់នេះ រកឃើញថាមានការរំលោភឆន្ទានុសិទ្ធិ ឬក៏ថាវាអាចប៉ះពាល់ដោយសារតែការសម្រេចប្រកបដោយមានកំហុសនោះ។ វាតម្រូវឱ្យភាគីក្តាប់បញ្ហានេះឱ្យបាន ហើយបង្ហាញនូវសេចក្តីសម្រេចឱ្យបានច្បាស់ ថាតើកំហុសទាំងអស់នោះវាមានដោយរបៀបណា។

[១១:៤១:៤៦]

យើងគឺថាមានចំណុចផ្ទុយពីចំណុចនេះ។ ទោះបីជាមូលដ្ឋានអង្គច្បាប់នៃសេចក្តីសម្រេចនេះមានទម្ងន់យ៉ាងណាក៏ដោយ គឺថាមិនមានលទ្ធភាពណាដែលឱ្យភាគីអាចជំទាស់តវ៉ាទៅនឹងបណ្តឹងឧទ្ធរណ៍ ឬក៏ អ.ប.ជ គឺថាជំទាស់ទៅនឹងការពិនិត្យឡើងវិញនោះទេ លើកលែងតែមានការបង្ហាញថា មិនមានកំហុសអង្គច្បាប់ ឬសេចក្តីសម្រេចដែលមានកំហុសទៅលើអង្គច្បាប់ ឬអង្គហេតុណាមួយ។

សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងអំពីបទដ្ឋាននៃការពិនិត្យឡើងវិញ ដែលមានចែងនៅក្នុងកថាខណ្ឌ១១ នៃការឆ្លើយតប។ នៅកថាខណ្ឌ៩ នៃការឆ្លើយតបនោះ គឺថាវាមិនស្របទៅនឹងការអនុវត្តរបស់តុលាការអន្តរជាតិនោះទេ។ ជាលទ្ធផលសហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់តវ៉ាថា ទី១ រាល់កំហុសអង្គច្បាប់ គឺអនុញ្ញាតឱ្យអង្គបុរេជំនុំជម្រះអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនជំនួសទៅបាន ហើយជាជម្រើសមួយទៀត សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា អ.ប.ជ “មានអំណាចមកជាមួយស្រាប់ដើម្បីបញ្ជូនដីកាដំណោះស្រាយត្រឡប់ទៅ ក.ស.ច.ស វិញ ដើម្បីឱ្យធ្វើការវាយតម្លៃទៅលើកំហុសអង្គច្បាប់ និងកំហុសអង្គហេតុនេះ។” បញ្ចប់ការដកស្រង់។

ពួកគាត់ សហព្រះរាជអាជ្ញាអន្តរជាតិនេះ បានជំទាស់តវ៉ាថា វាប៉ះពាល់ទៅដល់កំហុសអង្គច្បាប់ គឺថាអាចកម្រិតចំពោះសេចក្តីសម្រេចដើម។ ហើយសរុបមក វាអាចកើតមានឡើងដោយសារតែការបកស្រាយច្បាប់មិនត្រឹមត្រូវ ជាពិសេសសេចក្តីសន្និដ្ឋានពាក់ព័ន្ធទៅនឹងអង្គហេតុ ឬក៏ការអនុវត្តនូវ

ឆន្ទានុសិទ្ធិរបស់ខ្លួន។ យើងយល់ស្របជាមួយសារណានេះ វាច្បាស់ហើយគឺថា នៅកម្រិតអន្តរជាតិទាមទារឲ្យមានកត្តាសត្យានុម័ត ដើម្បីឲ្យអង្គបុរេជំនុំជម្រះសម្រេចថា វាមានលក្ខណៈសមស្របដើម្បីពិនិត្យមើលសេចក្ដីសម្រេចនេះ។ ហើយយុត្តិសាស្ត្រអន្តរជាតិបានបង្ហាញឲ្យឃើញថា កំហុសអង្គច្បាប់ត្រូវតែធ្វើឲ្យសេចក្ដីសម្រេចនោះ គឺថាពុំមានសុពលភាព។ បើពុំដូច្នេះទេ វាគឺជាការរំលោភទៅលើឆន្ទានុសិទ្ធិហើយ។ ដូចដែលយើងបានឃើញកាលពីម្សិលមិញ រាល់កំហុសអង្គច្បាប់ ឬក៏អង្គហេតុ គឺអាចឈានទៅដល់ការកែប្រែ ឬក៏ការវាយតម្លៃឡើងវិញទៅលើសេចក្ដីសម្រេចនោះបាន។ ពីម្សិលមិញសហព្រះរាជអាជ្ញាអន្តរជាតិ បានគេចវេះមិនបានលើកឡើងអំពីបទដ្ឋានរបស់តុលាការជាន់ខ្ពស់នេះ។ តាមរយៈបណ្ដឹងឧទ្ធរណ៍នេះ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញ ថាតើមានកំហុសណាខ្លះដែលមាននៅក្នុងសំអាងទី១ ទៅដល់ទី៦ ប្រសិនណាវាមានការរំលោភទៅលើឆន្ទានុសិទ្ធិបែបនេះ មែននោះ។

[១១:៤៥:៤៦]

យោងទៅតាមសហព្រះរាជអាជ្ញាអន្តរជាតិ ប្រសិនណាជាសហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យមានកំហុសអង្គច្បាប់ ទាក់ទងទៅនឹងការកំណត់និយមន័យ ការសម្លាប់រង្គាល ឬក៏ការបាត់ខ្លួនដោយបង្ខំនៅក្នុងមូលដ្ឋានទី៤ គឺថាវាមានផលប៉ះពាល់ទៅលើសេចក្ដីសម្រេចនេះ។ អ៊ីចឹងយើងអាចចាប់ផ្ដើមពិនិត្យមើលឡើងវិញ។ មិនមែនថាត្រូវពិនិត្យមើលថា ការអនុវត្តឲ្យបានត្រឹមត្រូវតែច្បាប់នោះទេ គឺថាត្រូវពិនិត្យមើលទៅលើយុត្តាធិការនេះទាំងស្រុងឡើងវិញតែម្ដង។ យោងទៅតាមសហព្រះរាជអាជ្ញាអន្តរជាតិ បើសិនជាមានការរកឃើញនូវអង្គហេតុ បង្ហាញថាមានជនរងគ្រោះរាប់ពាន់នាក់ ចំពោះបទល្មើសជាក់លាក់ណាមួយ មិនមែនគ្រាន់តែមួយពាន់មួយនាក់នោះទេ។ ពេលហ្នឹងយើងត្រូវតែពិនិត្យមើលទៅលើសេចក្ដីសម្រេចនោះទាំងមូលឡើងវិញ។ ហើយផលវិបាកនៃសេចក្ដីសម្រេច ស្ត្រីដែលមានវ័យជិត៨០ឆ្នាំហើយ ប្រឈមមុខទៅនឹងភាពប្រទូស្តរាយណាមួយ គឺគាត់អាចមានសិទ្ធិមកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ហើយដែលសេចក្ដីសម្រេចនេះ វាមិនប៉ះពាល់ទៅដល់សេចក្ដីសម្រេចជាចុងក្រោយនោះទេ ពាក់ព័ន្ធទៅនឹងបញ្ហាយុត្តាធិការបុគ្គលនេះ។

ដូច្នេះ នៅក្នុងមូលដ្ឋានទី១ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញអំពីបទដ្ឋាននៃការពិនិត្យឡើងវិញរបស់តុលាការជាន់ខ្ពស់ទេ។ ហើយទាក់ទងទៅនឹងមូលដ្ឋានទី២ សូមដកស្រង់៖ "គឺសហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានលើកឡើងអំពីការចោទប្រកាន់មួយចំនួន ដែលមាននៅក្នុងដីកា

សន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ" បញ្ចប់ការដកស្រង់។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានទៅលើមូលដ្ឋានសំអាងហេតុទី២ មិនមែនតែត្រឹមតែបទដ្ឋាននៃការពិនិត្យឡើងវិញដោយសាលាឧទ្ធរណ៍ទេ។ សូមដកស្រង់៖ "សេចក្តីសម្រេចរបស់ ក.ស.ច.ស ទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម គឺថាមិនត្រឹមត្រូវទេ ទាក់ទងទៅនឹងការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ។ សំអាងហេតុទី៣ និងទី៤ នោះគឺថា ថាតើសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តកំហុសអង្គច្បាប់មែនដែរ ឬក៏យ៉ាងណា។" ហើយទាក់ទង -- ដូចគ្នានេះដែរ នៅក្នុងសំអាងហេតុទី៥ និងទី៦ ក៏ដូចគ្នាដែរ។ នៅក្នុងបណ្តឹងឧទ្ធរណ៍ គឺថាបានជ្រើសរើសយកកំហុសមួយចំនួនមកលើកឡើងយកមកនិយាយនៅក្នុងបណ្តឹងឧទ្ធរណ៍។ ហើយនៅក្នុងនោះ មានការបង្ហាញថាសេចក្តីសម្រេចរបស់ ក.ស.ច.ស នោះគឺថាជាការសម្រេចខុសតែម្តង។ ដូចដែលខ្ញុំបានលើកឡើងខាងដើមនោះ គឺថានេះគឺជាគោលបំណងមួយដែលសហព្រះរាជអាជ្ញាអន្តរជាតិ គាត់ចង់ជំទាស់តវ៉ាទៅនឹងករណីនេះតែម្តង។

[១១:៤៩:២៥]

សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងករណីនេះ មាននៅក្នុងកថាខណ្ឌ៣៨ និង ៣៩ នៃដីកាដំណោះស្រាយ។ បណ្តឹងឧទ្ធរណ៍នេះ បានលើកឡើងថា តើមានបុគ្គលណាម្នាក់បានចូលរួមចំណែកប្រព្រឹត្តការសម្លាប់រង្គាលដែរឬក៏អត់។ ភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់បុគ្គលនោះ ការប៉ះពាល់ទៅដល់តួនាទីផ្លូវការរបស់បុគ្គលណាម្នាក់នៅក្នុងឋានានុក្រមរបស់ខ្មែរក្រហម ក៏ដូចជាកម្រិតដែលជនល្មើសបានចូលរួមចំណែកដើម្បីសម្រេចទៅលើគោលនយោបាយ និង/ឬ ការអនុវត្តជាក់ស្តែងតែម្តង។

សហចៅក្រមស៊ើបអង្កេតបានឈានដល់ការធ្វើសេចក្តីសម្រេច ដោយសំអាងទៅលើចំណុចបួនសំខាន់។ មួយ ទី១ គឺសកម្មភាពដែលត្រូវបានយកមកចោទប្រកាន់ចំពោះ អ៊ឹម ចែម ឬក៏ថាដោយកម្រិតត្រឹមតែ ស្រុកមួយ។ ទី២ គឺមានការលើកឡើងថាគាត់គឺជាលេខាស្រុក ជាសមាជិកគណៈតំបន់ ក៏ប៉ុន្តែនៅក្នុងប្រទេសនេះមានលេខាស្រុកហ្នឹងដល់ទៅរាប់ពាន់នាក់ឯណោះ។ ទី៤ ចំនួនជនរងគ្រោះដែលពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មដែលចោទប្រកាន់មកលើរូបគាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺមិនគ្រប់គ្រាន់ដើម្បីបំពេញលក្ខខណ្ឌស្តីអំពីយុត្តាធិការបុគ្គលនេះទេ។ គោលបំណងណាមួយ ចង់យកមកដាក់ជំនួសនូវការអនុវត្តនូវឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ត្រូវតែបង្ហាញឲ្យឃើញឲ្យបានច្បាស់អំពីកំហុសទាំងអស់នេះជាមុនសិន។

នៅក្នុងសារណាការរបស់យើងខ្ញុំ បណ្តឹងឧទ្ធរណ៍នេះមិនបានជំទាស់តវ៉ាទៅនឹងចំណុចដែលខ្ញុំលើកឡើងទាំងអស់នេះទេ មិនបានបំពេញលក្ខខណ្ឌដូចខ្ញុំលើកឡើងទេ។ ឥឡូវខ្ញុំសុំចូលទៅមូលដ្ឋានសំអាងហេតុទី១នេះ សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់តវ៉ាពិសេសពាក់ព័ន្ធទៅនឹង នៅក្នុងកថាខណ្ឌ១២ និងកថាខណ្ឌ១៣នៃបណ្តឹងឧទ្ធរណ៍។ កថាខណ្ឌ១២ នៃបណ្តឹងឧទ្ធរណ៍ដែលបានអះអាងថា សុំដកស្រង់៖ "ក.ស.ច.ស ខកខានមិនបានពិចារណាទៅដល់ការចោទប្រកាន់ទៅលើអង្គហេតុដែលសហចៅក្រមស៊ើបអង្កេតបានទទួល ឬក៏ទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ថាតើមានភស្តុតាង វាគាំទ្រទៅដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនេះដែរឬក៏អត់។ ក.ស.ច.ស នេះបានអះអាងថា ពួកគាត់មិនចាំបាច់ផ្តល់នូវសំអាងហេតុណាមួយចំពោះការទទួលខុសត្រូវរបស់ អ៊ឹម ចែម ទេ ដោយសារថាសហចៅក្រមស៊ើបអង្កេតខ្លួនឯងនេះ មិនបានចោទប្រកាន់ អ៊ឹម ចែម ចំពោះបទល្មើសទាំងអស់នេះ ឬជាមួយនឹងទម្រង់នៃការទទួលខុសត្រូវណាមួយនោះទេ។"

[១១:៥៣:២០]

ហើយដើម្បីពិនិត្យទៅលើការលើកឡើងទាំងអស់នេះ នៅក្នុងកថាខណ្ឌ២៤៤ ដល់២៤៦ នៃដីកាដំណោះស្រាយ ហើយអ្វីដែល ក.ស.ច.ស បានធ្វើ និងអ្វីដែល ក.ស.ច.ស ខកខានមិនបានធ្វើ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើង។ កថាខណ្ឌ២៤៤ ដល់២៤៦ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងច្បាស់ហើយ ទី១ គឺថា ក.ស.ច.ស បានសន្និដ្ឋានថា គឺមិនអនុញ្ញាតឲ្យចោទប្រកាន់ អ៊ឹម ចែម ចំពោះឧក្រិដ្ឋកម្មទូលំទូលាយដែលបានប្រព្រឹត្តលើសពីទម្រង់នៃការទទួលខុសត្រូវដូចដែលបានចោទប្រកាន់នោះទេ។ ប៉ុន្តែ ក.ស.ច.ស នៅក្នុងកថាខណ្ឌ២៤៦ បានលើកឡើងច្បាស់ហើយថា ក.ស.ច .ស មិនបានធ្វើមិនដឹងមិនឮចំពោះការចោទប្រកាន់ទាំងនេះទេ។ ដូចដែល ក.ស.ច.ស បានលើកឡើងសុំដកស្រង់៖ "ទោះបីជា អ៊ឹម ចែម ត្រូវបានចោទប្រកាន់ចំពោះការចោទប្រកាន់ទាំងអស់នេះ ដោយពីសំណាក់សហព្រះរាជអាជ្ញាអន្តរជាតិក៏ដោយ តើវានៅតែស្ថិតនៅខាងក្រៅយុត្តាធិការរបស់ អ.វ.ត.ក ឬយ៉ាងណា។ គឺថាយើងត្រូវតែផ្តល់តែភស្តុតាងពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនៅក្នុងតំបន់៥ ដែលមិនត្រូវបានយកមកចោទប្រកាន់ចំពោះ អ៊ឹម ចែម នោះទេ។" បញ្ចប់ការដកស្រង់។ កថាខណ្ឌ២៤៧នៃដីកាដំណោះស្រាយ ក.ស.ច.ស បានបញ្ជាក់ច្បាស់ហើយអំពីការវិភាគរបស់គាត់ជាលម្អិត។ សរុបមកនៅក្នុងកថាខណ្ឌ២៤៥ បញ្ហាអង្គច្បាប់ គឺថាមិនអាចចោទប្រកាន់ អ៊ឹម ចែម នូវអ្វីដែលមិន -- មិនអាច

បញ្ជូន អ៊ឹម ចែម ទៅជំនុំជម្រះដោយមិនមានបទល្មើសបទចោទប្រកាន់មកលើរូបគាត់នោះទេ។ ទី១ ថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬក៏អត់? កថាខណ្ឌ២៤៧ គឺថាបញ្ជាក់ច្បាស់ ហើយ សហចៅក្រមស៊ើបអង្កេតបានសម្រេចយ៉ាងច្បាស់ថា ប្រសិនបើ អ៊ឹម ចែម ត្រូវបានចោទប្រកាន់ គឺថាចោទប្រកាន់ដោយយោងទៅលើអង្គហេតុ។ នេះគឺមាននៅក្នុងសេចក្ដីសម្រេចជាចុងក្រោយរបស់សហចៅក្រមស៊ើបអង្កេត។

[១១:៥៦:១៦]

ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មពីរនៅស្រុកកោះអណ្ដែត ក្នុងតំបន់១៣ វត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន គឺថាគេបានរកឃើញថា នៅក្នុងស្រុកហ្នឹង អ៊ឹម ចែម មិនមានសិទ្ធិអំណាចអ្វីដោយផ្ទាល់នោះទេ ហើយក៏មិនពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះដែរ។ ហើយទី២ ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មពីរនៅភូមិភាគពាយ័ព្យ គឺនៅវត្តចំការខ្ពុរ និងការដ្ឋានត្រពាំងថ្ម មានទីតាំងនៅស៊ីសុផុន និងនៅ -- នៅស្រុកស៊ីសុផុន និងនៅភ្នំស្រុក ក្នុងតំបន់៥ គឺការពាក់ព័ន្ធរបស់ អ៊ឹម ចែម នោះគឺមានលក្ខណៈមិនច្បាស់លាស់ទេ។ ហើយសហចៅក្រមស៊ើបអង្កេតបានបកស្រាយចំណុចនេះយ៉ាងល្អិតនៅក្នុងកថាខណ្ឌ២៤៧ ដល់២៨០។ សរុបមក ក.ស.ព ការអះអាងរបស់ ក.ស.ព នៅក្នុងកថាខណ្ឌ១២នៃបណ្ដឹងឧទ្ធរណ៍ សូមដកស្រង់៖ “គឺ ក.ស.ច.ស ខកខានមិនបានពិចារណាទៅលើការចោទប្រកាន់ផ្នែកអង្គហេតុទាំងអស់នោះ” គឺមិនត្រឹមត្រូវនោះទេ។ បើសិនណាជាគេបានអានដីកាដំណោះស្រាយឱ្យបានពេញលេញទៅគឺថា គឺក.ស.ច.ស បានពិចារណាយ៉ាងច្បាស់ ហើយក៏បានបដិសេធនូវការចោទប្រកាន់ផ្នែកអង្គហេតុមួយចំនួនផងដែរ ដើម្បីឈានទៅដល់ការវាយតម្លៃអំពីបញ្ហាយុត្តាធិការបុគ្គល។ ហើយជាពិសេសគឺ ក.ស.ច.ស បានរកឃើញថា វាមានទំនាក់ទំនងមិនគ្រប់គ្រាន់ទេ រវាងអ្នកទាំងនោះរវាងបទល្មើសទាំងអស់នោះជាមួយនឹង អ៊ឹម ចែម ដោយយោងទៅលើការជាប់ទាក់ទងនឹង។ ហើយ ក.ស.ច.ស ក៏បានពិនិត្យមើលឡើងវិញទៅលើភស្តុតាង ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្ម គឺទីតាំងឧក្រិដ្ឋកម្មនៅក្នុងតំបន់១៣ នៃភូមិភាគនិរតី នៅក្នុងតំបន់៥នៃភូមិភាគពាយ័ព្យ ដែលទីតាំងឧក្រិដ្ឋកម្មទាំងនេះមិនត្រូវបានយកមកចោទប្រកាន់ប្រឆាំងនឹង អ៊ឹម ចែម ទេ។” បញ្ចប់ការដកស្រង់។ សហចៅក្រមស៊ើបអង្កេត គឺថាបានបកស្រាយយ៉ាងវែងឆ្ងាយ ប៉ុន្តែបានឈានដល់ការធ្វើសេចក្ដីសន្និដ្ឋាននេះ ដោយសារតែកង្វះទំនាក់ទំនងរវាងឧក្រិដ្ឋកម្មទាំងអស់នេះ ជាមួយនឹងការទទួលខុសត្រូវរបស់គាត់។

អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ មិនមែនតែបកស្រាយដីកាដំណោះស្រាយនេះ

ខុសទេ ប៉ុន្តែខកខានមិនបានបង្ហាញកំហុសអង្គច្បាប់ ឬខកខានមិនបានបង្ហាញអំពីការរំលោភឆន្ទានុសិទ្ធិនោះទេ។ ការអានដីកាដំណោះស្រាយមិនបានត្រឹមត្រូវនេះ គឺក៏បានបែងចែកសំអាងហេតុទី១ ហ្នឹងទៅជាបីផ្នែកតូចៗទៀត គឺការចោទប្រកាន់នេះ គឺត្រូវបានរកឃើញថាមិនជាប់ពាក់ព័ន្ធនោះដែរ មិនបានជាប់ពាក់ព័ន្ធនោះទេ។ ហើយក៏មិនបានរកឃើញអ្វីឲ្យលើសពីនេះនោះដែរ។

ទោះជាយ៉ាងណាក៏ដោយ ដើម្បីផលប្រយោជន៍នៃភាពពេញលេញ យើងសូមពិនិត្យមើលទៅលើការលើកឡើងអំពីគោលការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងកថាខណ្ឌ១១ ដល់២២នៃបណ្តឹងឧទ្ធរណ៍ មានន័យថា ក.ស.ច.ស នេះមានកំហុសក្នុងការសម្រេចថា ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋមនោះ ត្រូវតែចោទប្រកាន់លើកយកមកបង្ហាញនៅក្នុងដីកាដំណោះស្រាយ។

លោកប្រធាន ខ្ញុំរៀបនឹងចូលទៅផ្នែកបន្តទៅទៀតហើយ ប៉ុន្តែខ្ញុំមើលម៉ោងទៅឃើញថាដល់ម៉ោងហើយ តើខ្ញុំគួរបន្តទៅទៀត ឬក៏យ៉ាងណា?

**ប្រធានអង្គបុរេ៖**

លោក សេចក្តីសន្និដ្ឋានរបស់លោកនៅវែងឆ្ងាយតទៅ?

**លោក វេញ ហ្សុកដាហ្ស៖**

បាទ លោកប្រធាននៅវែងឆ្ងាយ។

**ប្រធានអង្គជំនុំ៖**

ដូច្នេះខ្ញុំសូមប្រកាសផ្អាកសវនាការ ហើយយើងបន្តទៅទៀតនៅម៉ោងមួយសាមសិបនាទី។ បាទ សូមបិទផ្អាក។

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣៣:៤៨]

**ប្រធានអង្គបុរេ៖**

សូមអញ្ជើញអង្គុយចុះ បាទ!

សូមអញ្ជើញលោកមេធាវីការពារឲ្យជនជាប់ចោទ អន្តរជាតិឡើងធ្វើសេចក្តីសន្និដ្ឋានបន្ត សូមអញ្ជើញបាទ។

**លោក វេញ ហ្សកដាហ្ស៖**

សូមគោរពលោកប្រធាន លោកចៅក្រមជាទីគោរព ដើម្បីបញ្ចប់សេចក្តីសន្និដ្ឋានទាក់ទងអំពីមូលដ្ឋានទី១ ដែលឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ ដែលនិយាយថាសហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងក្នុងការរកឃើញថា ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបឋមហ្នឹង គឺថាមិនបានជាផ្នែកមួយនៃដីកាដំណោះស្រាយ ហើយយើងបានបញ្ជាក់ ហើយលម្អិតនៅក្នុងចម្លើយតបរបស់យើងហើយ ខ្ញុំមិនលម្អិតទីនេះទេ។ ប៉ុន្តែគួរកត់សម្គាល់ថា សហព្រះរាជអាជ្ញាអន្តរជាតិ គឺថាគាំទ្រសំណួរមួយ គឺថា ហើយជាពិសេសគឺនិយាយអំពីការជូនដំណឹងពីបទចោទប្រកាន់ គឺសហព្រះរាជអាជ្ញាអន្តរជាតិលើកបែបនេះ គឺមិនត្រឹមត្រូវទេ។ គឺផ្អែកទៅលើ តាមតថកម្មរបស់គាត់នោះ គឺថាការជូនដំណឹងពីបទចោទនោះ គឺមិនមានតម្លៃជានីតិវិធី ហើយមិនត្រូវតាមទម្រង់បែបបទនីតិវិធីក្នុងការប្តឹងនោះទេ។ ពីម្សិលមិញ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា ការជូនដំណឹងពីការចោទប្រកាន់ គឺមិនមែនជាសេចក្តីសម្រេចមានសំអាងហេតុទេ។ ហើយនៅក្នុងឯកសារនេះ គឺថាវាទាក់ទងទៅនឹងលក្ខណៈពិសេសនៃនីតិវិធី ប៉ុន្តែទោះយ៉ាងណាក្តី គឺថា អ.វ.ត.ក បានសម្រេចលើសំណើបែបនេះនៅក្នុងរឿងក្តី០០២។ ដូចដែលបានកត់សម្គាល់នៅក្នុងរឿងក្តី០០២ គឺថាដីកាដែលច្រានចោលសំណើនោះគឺ D298/2 កថាខណ្ឌ១៣។ ការជូនដំណឹងពីការចោទប្រកាន់ គឺមិនមែនជាបញ្ហានីតិវិធីទម្រង់បែបបទនេះទេ ប៉ុន្តែវាជាសេចក្តីសម្រេចតុលាការដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត។ នៅពេលដែលខ្លួនបានរកឃើញថា ភស្តុតាងដែលមិនស្របគ្នាទាក់ទងទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលណាម្នាក់។ ចប់សេចក្តីដកស្រង់។

[១៣:៣៦:៣១]

ដូចដែលអង្គបុរេជំនុំជម្រះសម្រេចនៅក្នុងបណ្តឹងឧទ្ធរណ៍ដើម្បីស្នើសុំនូវ គឺឯកសារ D14/13 កថាខណ្ឌ៣៦ គឺការស៊ើបអង្កេតរបស់តុលាការ គឺត្រូវបានបញ្ចប់នៅពេលសហចៅក្រមស៊ើបអង្កេតសូមដកស្រង់៖ "គឺបានបញ្ចប់អំពើដែលមានភាពចាំបាច់ ដើម្បីបញ្ជាក់នូវការពិតទាក់ទងទៅនឹងអង្គហេតុដែលបានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបឋម ឬបន្ថែម មុននឹងវាយតម្លៃថាតើគ្រប់គ្រាន់ដើម្បីបញ្ជូនជនជាប់ចោទសង្ស័យទៅជំនុំជម្រះនោះ ឬក៏មិនគ្រប់គ្រាន់នោះទេ។" ចប់សេចក្តីដកស្រង់នោះ។

នៅក្នុងរឿងក្តី០០២ នៅក្នុង D447 គឺថាកថាខណ្ឌ សហចៅក្រមស៊ើបអង្កេតគឺបានសម្រេច គឺ

ថាបានឆ្លើយតបទៅ ថាភស្តុតាង សូមដកស្រង់៖ "គឺគ្រប់គ្រាន់ ហើយនិងមានភាពស៊ីសង្វាក់ ទាក់ទងនឹងកម្រិតមួយ អំពីតម្លៃជាភស្តុតាង" ចប់សេចក្តីដកស្រង់។ អនុលោមតាមវិធាន៣៧(១) អង្គជំនុំជម្រះសាលាដំបូងត្រូវតែពីទទួលសំណុំរឿងពីសហចៅក្រមស៊ើបអង្កេត គឺងនៅក្នុងសេចក្តីសម្រេច គឺថាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង គឺD29/29 គឺកថាខណ្ឌ១០៤, ១០៧ គឺដីកាដំណោះស្រាយបាននិយាយអំពីការចោទប្រកាន់ លើកលែងតែអង្គបុរេជំនុំជម្រះបានពិនិត្យមើលការកំណត់នូវបទចោទដែលមានចែងនៅក្នុងដីកាដំណោះស្រាយ។ ដូច្នេះនៅពេលដែលការស៊ើបអង្កេតហ្នឹងបានបញ្ចប់នៅក្នុងរឿងដែលចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតបានអនុវត្តនូវ មើលអំពើទាំងអស់ដែលចាំបាច់ ដើម្បីបញ្ជាក់នូវការពិតទាក់ទងទៅនឹងអង្គហេតុដែលមានចែងដោយសហព្រះរាជអាជ្ញា ហើយនិងនៅក្នុងដីកាសន្និដ្ឋានបន្ថែមរបស់ខ្លួន។

[១៣:៣៨:៥៦]

អង្គហេតុដែលថា អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់នូវបទល្មើសដែលបានចោទ ក្រៅពីនៅក្នុងករណី អ.វ.ត.ក នោះ គឺចង្អុលបង្ហាញថា សហចៅក្រមស៊ើបអង្កេតមិនបានយល់ព្រម ហើយរកមិនឃើញថា ភស្តុតាងគ្រប់គ្រាន់បង្ហាញថា គួរតែចោទប្រកាន់ទៅលើគាត់ ឬក៏គាត់មានការទទួលខុសត្រូវទៅលើព្រហ្មទណ្ឌ ទៅលើការចោទប្រកាន់ ឬក៏សេចក្តីជូនដំណឹងអំពីបទចោទ។ នេះហើយគឺជាករណីច្បាស់លាស់ឆ្លើយត្រូវទៅតាមច្បាប់។ នៅក្នុងកថាខណ្ឌ១៤ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា សូមដកស្រង់៖ "ការកំណត់បទចោទឡើងវិញ អង្គបុរេជំនុំជម្រះបានឃើញថា គឺបទឧក្រិដ្ឋមិនត្រូវបានចោទពីមុនទេ គឺមិនបានបញ្ចូលទៅក្នុងដីកាដំណោះស្រាយ ត្រូវបន្ថែមទៅក្នុងដីកាដំណោះស្រាយនូវបណ្តឹងសាទុក្ខ។ ដោយហេតុថា ការចោទប្រកាន់ពីអង្គហេតុត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីសន្និដ្ឋានបឋមរបស់សហព្រះរាជអាជ្ញា។

សហព្រះរាជអាជ្ញាក៏បានពឹងផ្អែកទៅលើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងរឿងក្តី ឌុច។ សូមដកស្រង់ គឺថានេះគឺជាឧទាហរណ៍ដ៏ល្អបំផុត គឺជនសង្ស័យអាចនឹងត្រូវបានបញ្ជូនទៅជំនុំជម្រះអំពីបទល្មើសដែលមិនត្រូវបានចោទប្រកាន់។ ទោះជាយ៉ាងណាក្តី ការពឹងផ្អែកទៅលើមតិនេះ គឺមិនចំសាច់រឿងទេ នៅក្នុងរឿងក្តី០០១ គឺអង្គបុរេជំនុំជម្រះបានបន្ថែមទៅលើបទល្មើសថ្នាក់ជាតិអំពីអំពើទារុណកម្ម ការសម្លាប់ ក្នុងករណី ឌុច។ ប៉ុន្តែក្នុងករណីនេះ គឺថា គឺជាទម្រង់នៃបទល្មើសមួយ ដែលថាអង្គហេតុហ្នឹងត្រូវបានពិចារណា ហើយបទល្មើសត្រូវបានច្រានចោល គឺដោយសារកង្វះភស្តុតាង និង

ភាពច្បាស់លាស់។ នៅក្នុងករណីនេះ បើមិនដូច្នេះទេ សហព្រះរាជអាជ្ញាបានស្នើទៅអង្គបុរេជំនុំជម្រះ ដើម្បីឲ្យពិនិត្យមើលឲ្យមានការស៊ើបអង្កេតសាជាថ្មីឡើងវិញនោះ។ នេះគឺតម្រូវឲ្យមានការវាយតម្លៃល្អិតល្អន់វែងឆ្ងាយទៀត គឺការវាយតម្លៃឡើងវិញដ៏លម្អិតនូវការងារដែលជាការងារមិនតម្រូវឲ្យធ្វើដោយអង្គបុរេជំនុំជម្រះមិនបានអនុញ្ញាតឲ្យធ្វើបែបនោះទេ និយាយពីការកំណត់បទល្មើសឡើងវិញនោះ។

[១៣:៤១:៣៧]

ឥឡូវនេះ ខ្ញុំចូលទៅមូលដ្ឋានទី២។ សហព្រះរាជអាជ្ញាអន្តរជាតិបាននិយាយថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងក្នុងអង្គច្បាប់ក្នុងការអង្គហេតុផងដែរ ដែលថាមិនចោទប្រកាន់ អ៊ឹម ចែម នោះ ហើយនិងផ្អែកទៅលើអង្គហេតុដែលមិនបានចោទប្រកាន់នោះ។ ការអានដ៏ត្រឹមត្រូវនូវដីកាដំណោះស្រាយនោះ គឺថាចៅក្រមស៊ើបអង្កេតមិនបានមានកំហុសឆ្គងបែបនោះទេ គឺគាត់មិនបានទុកចោលអង្គហេតុទាំងអស់នោះទេ។ ពួកគាត់បានពិចារណា ហើយបានរកឃើញថា ហើយមិនបានតម្រូវឲ្យពួកគាត់កែសេចក្តីសម្រេចរបស់គាត់នោះទេ។ ដូច្នេះ នេះជាជំហរមួយច្បាស់របស់សហចៅក្រមស៊ើបអង្កេត ជាជំហរផ្លូវច្បាប់ ដែលថា អ៊ឹម ចែម មិនអាចត្រូវបានចោទប្រកាន់ផ្អែកលើអង្គហេតុនោះទេ។ គឺមិនអាចមានការតវ៉ាណាមួយទាក់ទងទៅថាសហចៅក្រមស៊ើបអង្កេតផ្តល់តែការពិនិត្យត្រួសៗលើភស្តុតាង លើអង្គហេតុនោះ។

និយាយអំពីការមិនមានភាពប្រសិទ្ធភាពអំពីការចូលរួមរបស់ អ៊ឹម ចែម ហើយនិងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋនៅក្នុងតំបន់៥ ដែលមិនត្រូវបានចោទប្រកាន់ អ៊ឹម ចែម ទេ។ គឺការដែលចៅក្រមស៊ើបអង្កេតសម្រេចបែបនេះ គឺត្រឹមត្រូវទៅតាមនីតិវិធីច្បាប់ ហើយពួកគាត់មានសិទ្ធិត្រឹមត្រូវក្នុងការប្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញានោះ។ ប៉ុន្តែការអះអាងបែបនេះ គឺមិនចំសាច់រឿងដែរ។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ពួកគាត់បានពិចារណាលើអង្គហេតុដែលមិនបានចោទប្រកាន់ ហើយតាមពិតសហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា នៅក្នុងកាលៈទេសៈបែបនេះ ទាល់តែមានការតវ៉ាដែលសហចៅក្រមស៊ើបអង្កេតមិនបានផ្តល់សំអាងហេតុសមរម្យ។

ដូចដែលយើងបានឃើញច្បាស់លាស់នៅក្នុងការតវ៉ានៅក្នុងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ គាត់បានច្រានចោលមួយ ដោយបង្ហាញថាសហចៅក្រមស៊ើបអង្កេតមិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ ហើយគឺជាការខកខានមិនបានផ្តល់សំអាងហេតុ គឺជាកត្តាសម្រេចផ្តាច់មុខទៅលើអំណាចឆន្ទានុសិទ្ធិរបស់គាត់។ ទោះជាយ៉ាងនេះក៏ដោយ សហចៅក្រមស៊ើបអង្កេតត្រូវឲ្យបង្ហាញអំពីសេចក្តី

សម្រេចមានសំអាងហេតុនោះ ដូចជានៅក្នុងវិធាន៦៦(៤) ជាដើមនោះ។ វិធាននោះ បានចែងថា នៅពេលដែលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេត គឺមិនត្រូវចងកាតព្វកិច្ចទៅតាមសំណើរបស់សហព្រះរាជអាជ្ញាទេ។ ម្យ៉ាងវិញទេ សហចៅក្រមស៊ើបអង្កេតមិនចងកាតព្វកិច្ចត្រូវជាប់ទៅលើ -- ចងកាតព្វកិច្ចទៅលើដីកាដំណោះស្រាយ ផ្អែកទៅសំណើ ឬដីកាសន្និដ្ឋាននោះទេ។

[១៣:៤៤:៥៦]

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលរបស់ អ.វ.ត.ក នោះ គឺបានពិនិត្យឃើញថា សេចក្តីសម្រេចទាក់ទងទៅនឹងច្បាប់សិទ្ធិមនុស្សប្រចាំតំបន់ ឬក៏អន្តរជាតិ ទាក់ទងទៅនឹងតុលាការសិទ្ធិមនុស្សអន្តរជាតិ ដូច្នេះការដែលមិនបានបំពេញនូវសំអាងហេតុនោះ គឺមិនមែនជាមូលហេតុសម្រាប់ប្តឹងឧទ្ធរណ៍នោះទេ។ សេចក្តីសម្រេចនេះគឺយកមកពីរឿងក្តី០២ នៅក្នុងបណ្តឹងសាទុក្ខ គឺ F36 ដែលយើងយកជាបង្អែក។ លើសពីនេះទៅទៀត មូលហេតុទី២ ក៏ដូចជាមូលហេតុផ្សេងទៀតដែរ នៅក្នុងករណីដែលបានលើកឡើងនៅក្នុងការអះអាង ការទាមទារនោះ សហចៅក្រមស៊ើបអង្កេតក៏បាន ដែលថា សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់សំអាងហេតុ គឺថាសូមឲ្យ ថាតើកំហុសឆ្គងអង្គហេតុ និងអង្គច្បាប់នោះ គឺវាមូលដ្ឋានជាការសម្រេចដាច់ណាត់នូវវធន្មានុសិទ្ធិដែរឬទេ។ នេះមិនមែនជាតួនាទីរបស់អង្គបុរេជំនុំជម្រះដើម្បីធ្វើអ្វីដែលជាការងាររបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះទេ។

ដើម្បីពិចារណាលម្អិតអំពីអង្គហេតុដែលសហចៅក្រមស៊ើបអង្កេត ត្រូវបានចោទប្រកាន់ថាខកខានមិនបានពិចារណា នោះសហព្រះរាជអាជ្ញាអន្តរជាតិកំណត់នូវប្រភេទ៥។ ទី១ គឺការបោសសម្អាតភូមិភាគពាយ័ព្យ។ ២) អាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់១៣ និងតំបន់៥។ ៣) ការធ្វើទុក្ខបុកម្នេញប្រឆាំងជនជាតិវៀតណាមនៅក្នុងតំបន់៥។ ៤) បទឧក្រិដ្ឋប្រឆាំងនឹងខ្មែរក្រោមនៅក្នុងតំបន់១៣ ហើយ និង៥) បទឧក្រិដ្ឋដទៃជាច្រើនទៀត ដែលសហចៅក្រមស៊ើបអង្កេតបានទទួល។

[១៣:៤៧:០៦]

ទី១ យើងនិយាយអំពីការចោទប្រកាន់នៅក្នុងភូមិភាគនិរតី។ កថាខណ្ឌ១៤៣ ដល់កថាខណ្ឌ១៤៥ គឺនិយាយពីតួនាទីរបស់ អ៊ឹម ចែម នៅក្នុងតំបន់ភូមិភាគពាយ័ព្យ។ សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃ ហើយនិងបានវាយតម្លៃ ដូចដែលការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ហើយក៏បានសន្និដ្ឋានថា តួនាទីរបស់ អ៊ឹម ចែម គឺគាត់គ្រាន់តែជាប្រធានសមាគមនារីតំបន់១៣។ ដូច្នេះសុំដកស្រង់៖ “គាត់ទទួលខុសត្រូវការអប់រំនយោបាយដល់នារីនៅក្នុងស្រុកនានា នៅក្នុងតំបន់១៣។” ផ្អែកលើការរក

ឃើញនេះ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានដោយមានសំអាងហេតុ ដូចដែលខ្ញុំបានលើកឡើងនៅមូលដ្ឋាន ៤ និង៥ ថា អ៊ឹម ចែម មិនបានចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចនៅស្រុកកោះអណ្តែតនោះទេ។ ហើយយើងសូមជម្រាបថា គឺមិនមានភស្តុតាងដែលថាអ្នកស្រី អ៊ឹម ចែម ពាក់ព័ន្ធទៅនឹងការងារនឹងវត្តអង្គសិរីមាលី ហើយនិងព្រៃសុខុននោះទេ នៅក្នុងភូមិភាគនិរតី។ ទាក់ទងទៅនឹងការរកឃើញនេះ គឺថាការរកឃើញដែលថា អ៊ឹម ចែម មិនបានពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសម្រេចនៅភូមិភាគនិរតីនោះ។ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានតម្រូវឱ្យវាយតម្លៃជាលម្អិត និងភស្តុតាងនានាដែលទាក់ទងទៅនឹងបទឧក្រិដ្ឋដែលរងការចោទប្រកាន់នៅភូមិភាគនិរតី ហើយនិងទាក់ទងទៅនឹងអ្វីដែល អ៊ឹម ចែម មិនត្រូវបានចោទប្រកាន់នោះដែរ។

[១៣:៤៩:០៤]

ទី២ យើងនិយាយអំពីការចោទប្រកាន់មួយចំនួននៅភូមិភាគពាយ័ព្យ។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតគឺមានកំហុសឆ្គងអង្គច្បាប់ដែលមិនបានលើកឡើងពីការអះអាងថា ទី១ គឺការបោសសម្អាតភូមិភាគពាយ័ព្យ។ ទី២ គឺការរៀបការដោយបង្ខំនៅតំបន់៥។ ទី៣ គឺអំពើធ្វើទុក្ខបុកម្នេញជនជាតិវៀតណាមនៅតំបន់៥។ ហើយ៤) គឺបទឧក្រិដ្ឋផ្សេងទៀត នៅក្នុងភូមិភាគពាយ័ព្យ។ ម្តងទៀត គឺសហចៅក្រមស៊ើបអង្កេត គឺមិនបានទទួលនូវអង្គហេតុទាំងនេះទេ នៅក្នុងសំណុំរឿង។

និយាយអំពីតម្លៃភស្តុតាងទាក់ទងទៅនឹងយុត្តាធិការបុគ្គលវិញ គឺសហចៅក្រមស៊ើបអង្កេតបានពិនិត្យមើលអំពីតួនាទី និងអំណាចរបស់គាត់នៅភូមិភាគនេះ។ សុំដកស្រង់៖ “អំណាចរបស់នាងទាក់ទងទៅនឹងតំបន់នេះ អ្វីដែលកើតឡើងនៅវត្តចំការខ្នុរ ការដ្ឋានត្រពាំងថ្ម ទាក់ទងទៅនឹងការមនុស្សស្លាប់ ហើយនិងនៅការដ្ឋានព្រះនេត្រព្រះជាដើម។” ហើយយើងបានផ្តល់ចម្លើយតបលម្អិតទាក់ទងទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញានេះ។

ឥឡូវនេះ យើងនឹងឆ្លើយតបទាក់ទងទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិពីម្សិលមិញ ទាក់ទងទៅនឹងការបោសសម្អាតភូមិភាគពាយ័ព្យនោះ។ ទាក់ទងទៅនឹងការបោសសម្អាតភូមិភាគពាយ័ព្យ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា នៅក្នុងដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានធ្វើការរកឃើញដ៏មិនត្រឹមត្រូវ គឺគ្រាន់តែជាការរៀបរាប់ មិនមែនជាការរកឃើញបែបវិភាគនៅលើបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនោះទេ។ ទី១ គឺនិយាយអំពីការពិនិត្យលើដីកាដំណោះ

ស្រាយបង្ហាញថា សហចៅក្រមស៊ើបអង្កេតបានពិនិត្យមើលភស្តុតាងទាក់ទងទៅនឹងការពាក់ព័ន្ធរបស់ អ៊ឹម ចែម ទៅនឹងការបោសសម្អាតភូមិភាគពាយ័ព្យយ៉ាងលម្អិត ហើយការវាយតម្លៃនេះ គឺមានការពិចារណា គឺការទំនាក់ទំនងរបស់គាត់ជាមួយ តាម៉ុក និងតួនាទីរបស់នាង។ ផ្ទុយទៅនឹងអ្វីដែលអះអាងដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុងកថាខណ្ឌ២៤ សហចៅក្រមស៊ើបអង្កេតមិនបានសន្និដ្ឋានថា អ្នកស្រី អ៊ឹម ចែម សុំដកស្រង់៖ "បានដឹកនាំ និងចូលរួម" និងអ្វីដែលសហចៅក្រមស៊ើបអង្កេតបានរៀបរាប់ថា គឺជាការងារសម្របសម្រួលដ៏ចម្បងដែលជាការបោសសម្អាតភូមិភាគពាយ័ព្យនោះទេ។ នៅកម្រិតខ្ពស់បំផុត សហចៅក្រមស៊ើបអង្កេតបានរកឃើញថា គាត់បានដឹកនាំការបញ្ជូនកម្មាភិបាលនិរតីទៅភូមិភាគពាយ័ព្យ។

ក្នុងករណីណាក៏ដោយ ដែលបានវាយតម្លៃ កថាខណ្ឌ១៥៨ ដល់១៦០ នៃដីកាដំណោះស្រាយ គឺ អ៊ឹម ចែម បានកាន់តំណែងតូចជាងនេះឆ្ងាយណាស់ ដែលជា -- គឺដូចជាលេខាស្រុកព្រះនេត្រព្រះ នៅក្នុងភាគច្រើននៃសម័យកាល មិនមែនជាតួនាទីដឹកនាំនៅភូមិភាគពាយ័ព្យទេ។ ភស្តុតាងមិនបានបង្ហាញពីការចូលរួមទៅនឹងបទឧក្រិដ្ឋទាំងអស់នោះទេ។ ដោយសារថា តួនាទីរបស់គាត់មានកម្រិតដែលរកឃើញនោះ គឺមិនមាន -- ចៅក្រមពិចារណាអង្គហេតុណាអាចនឹងថាគាត់បានចូលរួមបទឧក្រិដ្ឋនៅក្នុងតំបន់ដែលនាំឲ្យគាត់មានយុត្តាធិការបុគ្គលនោះទេ។ អាស្រ័យហេតុនេះ សេចក្តីទាមទាររបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះ ថាសហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាបទឧក្រិដ្ឋ ហើយក៏មានកំហុសឆ្គងមិនបានបង្ហាញអំពីសេចក្តីសន្និដ្ឋានដ៏គួរឲ្យសមហេតុផលនោះ។

[១៣:៥៣:៣២]

ឥឡូវនេះ ខ្ញុំចូលទៅដល់អាពាហ៍ពិពាហ៍ដោយបង្ខំ គឺថានៅក្នុងតំបន់១៣ ភូមិភាគនិរតី។ គួរកត់សម្គាល់ក្នុងការពិនិត្យថា ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានពិចារណាភស្តុតាងដែលថា ការទទួលខុសត្រូវរបស់ អ៊ឹម ចែម ចំពោះការរៀបការដោយបង្ខំនៅតំបន់១៣ ភូមិភាគនិរតី។ ការពិត គឺករណីទាំងមូលរបស់សហព្រះរាជអាជ្ញា គឺមិនពាក់ព័ន្ធទៅនឹងការពាក់ព័ន្ធរបស់ អ៊ឹម ចែម ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំភូមិភាគនិរតីនេះ គឺស្ថិតនៅក្នុងអ្វីមួយដែលខ្ញុំដកស្រង់ថា គឺបង្ខំឲ្យនារីក្មេងៗនៅក្នុងតំបន់១៣ រៀបការជាមួយយោធាពិការ។ ហើយក្នុងករណីហ្នឹង ក្នុងឱកាសមួយចំនួន គឺមានការរៀបការដោយបង្ខំកើតឡើង ប៉ុន្តែមិនបាននិយាយនៅក្នុងអត្ថន័យដែលមានន័យដែលថា អ៊ឹម ចែម នោះ មានការពាក់ព័ន្ធនៅក្នុងរឿងនេះទេ។ ដូចដែលអ្វីមានការ

ពាក់ព័ន្ធ ការចោទប្រកាន់មួយដែលគ្មានភស្តុតាងគាំទ្រ ទី១ គឺមិនពាក់ព័ន្ធទៅនឹងអ្វីដែលកើតឡើងនៅក្នុងតំបន់ភូមិភាគនិរតីទេ ប៉ុន្តែអ្វីកើតឡើងនៅស្វាយនៅក្នុងភូមិភាគពាយ័ព្យ។

ភស្តុតាងគឺមិនអាចបង្ហាញថា អាចនឹងមានតម្លៃជាភស្តុតាងគ្រប់គ្រាន់ត្រឹមត្រូវទេ ហើយក៏មិនមានភាពស៊ីសង្វាក់ ហើយជាភស្តុតាងដែលជាពាក្យចចាមអារ៉ាមគ្មានប្រភព។ នៅក្នុងកថាខណ្ឌ២៨នៃបណ្តឹងឧទ្ធរណ៍ ថាសហចៅក្រមស៊ើបអង្កេតត្រូវតែពិចារណាទំនាក់ទំនងភស្តុតាងដែលថា អ៊ឹម ចែម ដឹកនាំយុទ្ធនាការអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់១៣ ហើយការណ៍នេះ ត្រូវតែពិចារណាដើម្បីវាយតម្លៃថាតើ អ៊ឹម ចែម ស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃតុលាការនេះដែរឬអត់។ នេះគឺមិនមែនជាការសន្និដ្ឋានត្រឹមត្រូវនោះទេ។ នៅទីបំផុត ផ្ទុយពីអ្វីដែលអះអាងម្សិលមិញថា សុខ រុំ គឺត្រូវបានពឹងផ្អែកពីរដងនៅក្នុងដីកាដំណោះស្រាយ ដែលចោទជាបញ្ហានោះ។ ការណ៍នេះ គឺមិនអាចប៉ះពាល់ដល់វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតនោះទេ។ ដូចដែលអ្វីកំណត់ឡើងដោយស្តង់ដារអន្តរជាតិ។ សហចៅក្រមស៊ើបអង្កេតមិនចងកាតព្វកិច្ចថា ត្រូវទទួលយកការ ឬក៏បដិសេធទៅលើអ្វីដែលជាចម្លើយតែមួយនោះទេ។

[១៣:៥៦:៣៦]

ទាក់ទងទៅនឹងការរៀបការដោយបង្ខំ នៅតំបន់៥ ភូមិភាគពាយ័ព្យ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតបានខកខានមិនបានពិចារណាភស្តុតាងទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ អ៊ឹម ចែម លើអាពាហ៍ពិពាហ៍ដោយបង្ខំនៅទីតាំងឧក្រិដ្ឋកម្ម ហើយនិងអំណាចរបស់គាត់ ដូចជានៅការដ្ឋានទំនប់ស្ពានស្រែង ហើយការដ្ឋានទំនប់ត្រពាំងថ្ម នៅភូមិភាគពាយ័ព្យ។ នេះគឺជាផ្នែកដែលសហចៅក្រមស៊ើបអង្កេតបានពិចារណាអស់ហើយ។ សហព្រះរាជអាជ្ញាអន្តរជាតិបានលឿនពេក ហើយមិនទទួលជោគជ័យក្នុងការប្រើភស្តុតាងនៅក្នុងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតទេ។ ដូច្នេះ នៅក្នុងកថាខណ្ឌ៣៥ នៅក្នុងការឆ្លើយតប ដែលថាសហចៅក្រមស៊ើបអង្កេតមិនបានរកឃើញជាក់លាក់អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ។ នៅក្នុងកាលៈទេសៈមួយចំនួន គឺជាការខកខានដ៏ត្រឹមត្រូវ ដែលអាចនឹងមានផលប៉ះពាល់ទៅលើការសម្រេចជាចុងក្រោយ។

ទី១ សហចៅក្រមស៊ើបអង្កេតបានពិនិត្យមើលភស្តុតាងដែលទាក់ទងទៅនឹងការពាក់ព័ន្ធរបស់ អ៊ឹម ចែម នៅក្នុងភូមិភាគនិរតី ភូមិភាគពាយ័ព្យ យ៉ាងល្អិតល្អន់។ នេះគឺជាស្ថានភាពបញ្ហាដ៏ពិសេស។ បញ្ហាទី២ ទោះបីទុកចោលបញ្ហាដ៏សំខាន់នេះក្តី ភស្តុតាងដែលភ្ជាប់ អ៊ឹម ចែម ទៅនឹងអាពាហ៍ពិពាហ៍

ដោយបង្ខំនៅភូមិភាគពាយ័ព្យ គឺស្តើងណាស់ តិចតួចណាស់។ ទី១ គឺទាក់ទងទៅនឹងការដ្ឋានទំនប់ស្ពានស្រែងនោះ សហព្រះរាជអាជ្ញាបានលើកឡើងនៅក្នុងកថាខណ្ឌ២៦៩ នៅក្នុងដីកាសន្និដ្ឋានចុងក្រោយរបស់ខ្លួនដោយបញ្ជាក់ទៅលើចម្លើយរបស់ សែន សុផុន ដែលគាំទ្រការអះអាងថា ការរៀបការដោយបង្ខំកើតឡើងនៅក្នុងការដ្ឋាននេះ។ ដូចដែលកើតឡើងនៅក្នុងកថាខណ្ឌ៥៨ នៃការឆ្លើយតប ដើមបណ្តឹងរដ្ឋប្បវេណី អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនបានឆ្លើយដាក់ អ៊ឹម ចែម អំពីអាពាហ៍ពិពាហ៍ដោយបង្ខំនេះទេ។

ជាថ្មីម្តងទៀត គឺថា គីម្សិលមិញ ការអះអាង សែន សុផុន ត្រូវបានពឹងផ្អែកលើប្លូនឱកាសនៅក្នុងដីកាដំណោះស្រាយទាក់ទងទៅនឹងបញ្ហាដែលមិនទាក់ទង មិនអាចធ្វើឲ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតលើភស្តុតាងទេ។ សហចៅក្រមស៊ើបអង្កេតមានសិទ្ធិទាំងស្រុងទទួលយក ឬក៏ច្រានចោលទាំងស្រុង បើខ្លួនធ្វើដូច្នោះ តាមវិធីដ៏សមស្រប។ បញ្ហាទី២ ទាក់ទងទៅនឹងត្រពាំងថ្ម ភស្តុតាងអំពីការរៀបការដោយបង្ខំ គឺមិនពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតលើយុត្តាធិការបុគ្គលទេ។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ដោយសារតែ អ៊ឹម ចែម បានធ្វើទស្សនកិច្ចទៅទីតាំងនោះ គឺវិសាលភាពនៃការពាក់ព័ន្ធអំណាចរបស់គាត់លើបញ្ហានោះ គឺមិនច្បាស់ទេ។ ចប់សេចក្តីដកស្រង់។

[១៤:០០:០៨]

នេះគឺជាការរកឃើញ គឺសហព្រះរាជអាជ្ញាមិនបានតទល់នឹងការរកឃើញនេះទេ។ ភស្តុតាងតែងមួយអំពីភាពទាក់ទង ហើយនិងតម្លៃជាភស្តុតាងដែលពាក់ព័ន្ធទៅនឹងការចូលរួមរបស់ អ៊ឹម ចែម គឺដំណើរការនៃប្រព្រឹត្តទៅអំពីការអាពាហ៍ពិពាហ៍នោះគឺថា ថង ធឿយ បាននិយាយថា គាត់បានឃើញ អ៊ឹម ចែម បានធ្វើជាអធិបតីភាពនៅក្នុងការរៀបការនៅភូមិភាគពាយ័ព្យ ហើយនិងអ្នកក្រោមអំណាចដើម្បីតាមដានអ្នកដែលរៀបការរួចហើយ ដើម្បីឲ្យរួមដំណេកជាដើមនោះ។

តាមនិយមន័យ យើងទទួលស្គាល់ថា ចៅក្រមដែលអ្នកវិនិច្ឆ័យអង្គហេតុ គឺថាសាក្សីបែបនេះ តែមួយមិនអាចផ្តល់ភស្តុតាងគ្រប់គ្រាន់ រឹងមាំស៊ីសង្វាក់ ឬក៏ភស្តុតាងស៊ីសង្វាក់ ដើម្បីអ្វីដែលច្បាស់ជាងការអះអាងតែមួយអំពីតម្លៃភស្តុតាង អំពីអំពើដែលចោទប្រកាន់។ ដំណើរការនៃអំពើដែលបន្តពេញមួយរបបនោះ នៅភូមិភាគផ្សេងៗ ដែលថាការរៀបការ អាពាហ៍ពិពាហ៍ឲ្យមនុស្សពីរគូ ឬក៏១០០គូនោះ មិនជាការសមស្របទេ គឺវាជាការសម្រេចលើឆន្ទានុសិទ្ធិ គឺអ្វីដែលខ្លួនបានពឹងផ្អែកទៅលើភស្តុតាង ប៉ុន្តែ

ករណីនេះ គឺភស្តុតាងតែមួយតូចគត់។ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញអំពីកំហុសឆ្គង ឬក៏ការបំពានឆន្ទានុសិទ្ធិនោះឡើយ។

អាស្រ័យដូច្នេះ គឺថាមូលដ្ឋានទី២នោះ គឺដាក់មិនត្រឹមត្រូវទៅតាមមូលដ្ឋាននោះទេ។ ហើយយើងសន្និដ្ឋាន ដែលសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតគឺពិនិត្យភស្តុតាងគ្រប់ផ្នែកទាំងអស់ ហើយធ្វើសេចក្តីសម្រេចគ្រប់គ្រាន់ ឬក៏ម្យ៉ាងទៀត គឺបញ្ហានៃការវាយតម្លៃលើភស្តុតាងអំពីបទឧក្រិដ្ឋ។ កាលៈទេសៈនានា នៅពេលដែលសហចៅក្រមស៊ើបអង្កេតវាយតម្លៃអំពីអំណាច ហើយបានរកឃើញច្បាស់លាស់ ហើយគាត់មិនមានកាតព្វកិច្ចដើម្បីពិចារណាលើបទឧក្រិដ្ឋទាំងមូលនោះទេ។ វិសាលភាព ហើយនិងស្ថានទម្ងន់ មិនទុកជាបញ្ហាសំខាន់ទេ ទោះបីវាមានភាពធ្ងន់ធ្ងរធំយ៉ាងណាក្តី។ កាលៈទេសៈ ទាក់ទងទៅនឹងអំពើឧក្រិដ្ឋរបស់ អ៊ឹម ចែម នោះ គឺថាមិនគួរឲ្យជឿជាក់បាន។ សហចៅក្រមស៊ើបអង្កេតក៏មិនមានកាតព្វកិច្ចត្រូវផ្តល់មូលដ្ឋានសម្រាប់ការច្រានចោល។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិមានកាតព្វកិច្ចក្នុងការធ្វើច្រើនជាងអ្វីដែលការលើកឡើងពីភស្តុតាងមួយចំនួនតូច ហើយបង្ហាញឲ្យច្បាស់ថា ដើម្បីឲ្យចៅក្រមសម្រេចខុសពីហ្នឹងទៅបាន។ អ្វីដែលជាវិធីសាស្ត្រនោះ ដែលអាចនាំទៅរកការបំពានទៅលើឆន្ទានុសិទ្ធិ។ ហើយមូលដ្ឋានទី២ គប្បីត្រូវបានច្រានចោល ពីព្រោះគ្មានមូលដ្ឋានគ្រប់គ្រាន់នោះទេ។

[១៤:០៤:០៦]

ទាក់ទងទៅនឹងមូលដ្ឋានទី៣ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា នៅក្នុងកថាខណ្ឌ ៣៨ ទៅ៤០ នៅក្នុងបណ្តឹងឧទ្ធរណ៍ហ្នឹងថា សហចៅក្រមស៊ើបអង្កេតបានមានកំហុសឆ្គងពីរ។ មួយ គឺកំហុសឆ្គងអង្គច្បាប់ ដែលសហចៅក្រមស៊ើបអង្កេតរកឃើញថា ចេតនាបទឧក្រិដ្ឋនៃការសម្លាប់រង្គាលនោះ គឺថាគឺជាកំហុសឆ្គងអង្គហេតុ ដែលថាមិនរកឃើញថា អ៊ឹម ចែម មិនមានចេតនាដើម្បីសម្លាប់រង្គាលនោះ។

ការអះអាងរបស់មេធាវីការពារក្តីនៅក្នុងមូលដ្ឋានទី៣នេះ គឺយើងបាននិយាយនៅក្នុងការចម្លើយតបរបស់យើង។ ហើយមូលដ្ឋានទី២ ក៏ត្រូវបដិសេធចោលដែរ តាមមតិរបស់មេធាវីការពារក្តី។ សហចៅក្រមស៊ើបអង្កេតមិនបានខុសឆ្គងទេ ក្នុងការស្វែងរកចេតនា។ ទី៣ មេធាវីការពារលើកឡើងថា បញ្ហានេះសំខាន់បំផុតនៃការឆ្លើយតបឡើង ទោះបីជាមានកំហុសឆ្គងអង្គហេតុច្បាស់នៅក្នុងក៏ដោយ ក៏សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញភស្តុតាងថា អាចនឹងមានលក្ខណៈធ្ងន់ធ្ងរដែលអាចច្រាន

ចោលសេចក្ដីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែរ។ ដូច្នេះមេធាវីការពារក្ដី សូមជម្រាបថា បើសិនជាបទឧក្រិដ្ឋនៃការសម្លាប់រង្គាលនោះ ត្រូវបានកំណត់និយមន័យតាមរបៀបមួយដែលមេធាវីការពារលើកឡើងថា ទោះបីជាមានកំហុសឆ្គងនៅក្នុងការកំណត់និយមន័យការសម្លាប់រង្គាល ក៏មិនអាចនឹងធ្វើឲ្យដីកាដំណោះស្រាយត្រូវមានសំអាងហេតុលើសនេះដែរ។ ដូច្នេះខ្ញុំ យើងនិយាយពីបញ្ហាទី២ និងទី៣ អំពីនិយមន័យនៃចេតនាឧក្រិដ្ឋ ថាតើមានកំហុសឆ្គងដែលវាមានលក្ខណៈធ្ងន់ធ្ងរដែលអាចធ្វើឲ្យផ្លាស់ប្ដូរសេចក្ដីសម្រេចហ្នឹងដែរឬទេ? ទី១ យើងលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនមានកំហុសឆ្គងក្នុងការកំណត់ពីចេតនាឧក្រិដ្ឋអំពីការសម្លាប់រង្គាលនោះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិនោះ អះអាងថាគឺផ្អែកទៅលើទស្សនៈមិនច្បាស់លាស់មួយចំនួន ដែលគាត់ចុចយកមកពីដីកាដំណោះស្រាយ។ នៅក្នុងកថាខណ្ឌ៧៩ នៃចម្លើយតបរបស់យើង គឺថាសហចៅក្រមស៊ើបអង្កេតបានយោងទៅរកសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីចេតនាឧក្រិដ្ឋ គឺការបង្កនូវការឈឺចាប់ដ៏ធ្ងន់ធ្ងរ ឬក៏បង្កើតនូវស្ថានភាពរស់នៅដែលនាំឲ្យមានការឈឺចាប់ទៅលើប្រជាជនក្នុងកម្រិតធំ។

[១៤:០៧:៣១]

ឥឡូវនេះ យើងមើលការអានទៅលើដីកាដំណោះស្រាយដែលនិយាយថាសហចៅក្រមស៊ើបអង្កេតមានចេតនា គឺបានធ្វើការវាយតម្លៃអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម អំពីករណីត្រពាំងថ្ម នោះ។ ជាពិសេស គឺការវាយតម្លៃទៅលើសេចក្ដីសម្រេចរបស់តុលាការកំពូលដែលសម្រេចថា បង្ហាញថា ការសម្លាប់សមាជិករបស់ក្រុម គឺអ្វីដែលជាចេតនារបស់ចារីនោះ គឺមិនពាក់ព័ន្ធទៅនឹង ថាតើគាត់ប្រាកដជាមានចេតនាចង់ឲ្យមានបែបនោះទេ។ ចង់សេចក្ដីស្រង់។ ហើយការគ្រាន់តែដឹងថា ដឹងបែបនេះ គឺដឹងពីការស្លាប់បែបនេះ គឺមិនគ្រប់គ្រាន់ទេ គឺនៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ៦៨។

ក្រៅពីការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលផ្ទុយពីកថាខណ្ឌ៤៥នៃបណ្ដឹងឧទ្ធរណ៍ គឺធាតុចេតនាពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល គឺជាបញ្ហាពាក់ព័ន្ធទៅនឹងការដឹងថា ការសម្លាប់ហ្នឹងគឺវាកើតមានឡើង ហើយបានបន្តចូលរួមនៅក្នុងការសម្លាប់នោះ។ បញ្ចប់ការដកស្រង់។ ដូចដែលបានលើកឡើងនៅក្នុងជើងទំព័រនៃបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ កថាខណ្ឌ៤៥ ដែលថាធាតុចេតនា សុំដកស្រង់៖ “អាចវាខុសពីការចូលរួមផ្ទាល់របស់ជនជាប់ចោទ” ប៉ុន្តែជនជាប់ចោទ សុំដកស្រង់៖ ត្រូវតែដឹងយ៉ាងច្បាស់ថា ការចូលរួមនេះ នឹងនាំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មណាមួយ” បញ្ចប់ដកស្រង់។

ដូចដែលបានកត់សម្គាល់ដោយតុលាការកំពូលនៃតុលាការ អាយ.ស៊ី.ធី.អ័រ នៅក្នុងរឿងក្តី កាហ្សីសេម៉ា និង អារ៉ប៊ែតស៊ីនណាដា។ បញ្ហាថាតើចេតនានេះ អាចយកមកសំអាងនៅក្នុងសេចក្តីសម្រេចនៃឆន្ទានុសិទ្ធិរបស់តុលាការបានដែរឬទេ? ហើយថាតើត្រូវអនុវត្តឆន្ទានុសិទ្ធិនេះដោយរបៀបណា ពាក់ព័ន្ធទៅនឹងភស្តុតាងដែលអាចមាននោះ? ហើយការដឹងពីកាលៈទេសៈផ្សេងៗដែលបានបង្ហាញដោយភស្តុតាងពាក់ព័ន្ធទៅនឹងការដ្ឋានទំនប់ត្រពាំងថ្ម ហើយនិងភាពធ្ងន់ធ្ងរនៃបញ្ហាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រឈមមុខនោះ។ មេធាវីការពារក្តីសូមលើកឡើងថា បញ្ហានេះ អាចត្រូវបានសង្ខេបដូចខាងក្រោមនេះ។ នៅក្នុងកាលៈទេសៈដែលមានការសម្លាប់គឺថា ព្រឹត្តការណ៍សម្លាប់ជាក់ស្តែងមែនទែនបានកើតមានឡើង ហើយត្រូវបានរៀបចំឡើងដោយចារីដែលបានចោទប្រកាន់នេះ។

ដូច្នេះ គេតម្រូវថា គ្មានការសម្លាប់ហ្នឹង គឺជាទ្រង់ទ្រាយធំ ហើយវាត្រូវខុសពីព្រឹត្តិការណ៍សម្រាប់បុគ្គលណាម្នាក់ដែលមានលក្ខណៈជាទ្រង់ទ្រាយតូចបែបនេះ។ បញ្ហា ថាតើជនត្រូវចោទបានដឹងនិងមានបំណង ហើយអាចត្រូវបានលាក់លៀម ឬក៏បង្កឧបសគ្គដែរឬយ៉ាងណា។ ដូច្នេះ វាទាមទារឲ្យមានចេតនាជាមុន។ ដូចដែលសហចៅក្រមស៊ើបអង្កេតបានធានាទៅលើការវាយតម្រូវ ថាតើត្រូវតែមានចេតនាជាចុងក្រោយ។ នេះគឺអ្វីដែលសហចៅក្រមស៊ើបអង្កេតបានសម្រេច ហើយដែលថាបុគ្គលណាដែលចូលរួម ឬក៏មានបំណងសម្លាប់ក្នុងទ្រង់ទ្រាយ ឬក៏បង្កព្យសនកម្មអន្តរាយធ្ងន់ធ្ងរទៅដល់រូបរាងកាយ អាចចាត់ទុកថា ជាការបំផ្លិចផ្លាញយ៉ាងធ្ងន់ធ្ងរទៅលើចំនួនប្រជាពលរដ្ឋនោះ។

[១៤:១២:២៩]

សហចៅក្រមស៊ើបអង្កេត គឺថាបានប្រើប្រាស់នូវលក្ខខណ្ឌតម្រូវឲ្យបានដឹងជាមុន ដើម្បីដោះស្រាយបញ្ហានេះ។ ការសម្លាប់នៅទីតាំងនេះ គឺថាបានអនុវត្តជាយូរមកហើយ ហើយប្រហែលជាអាចត្រូវបានសម្លាប់ដោយចារីដទៃៗទៀត ដូចដែលមាននៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ២៨៨។ ការរកថា អ៊ឹម ចែម មានអំណាចផ្លូវការទៅលើការដ្ឋានទំនប់ត្រពាំងថ្ម នេះបង្កើតទៅជាវិមតិសង្ស័យពាក់ព័ន្ធទៅនឹងលក្ខណៈនៃការសម្លាប់។ ការកំណត់អត្តសញ្ញាណចារី ហើយជាចុងក្រោយទំនាក់ទំនងរបស់លោកស្រី អ៊ឹម ចែម ទាក់ទងទៅនឹងការព្រឹត្តិការណ៍សម្លាប់ផ្សេងៗ ក៏ដូចជាគោលបំណងទូទៅរបស់គាត់ ហើយនិងអ្វីដែលគាត់បានផ្តោតការយកចិត្តទុកដាក់នេះ។

ហេតុដូច្នេះ ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ៨ នៃចម្លើយតប សុំដកស្រង់៖ “សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត គឺថាមិនមែនមានបំណងបង្ហាញនូវធាតុផ្សំថ្មីនៃច្បាប់នោះទេ។

ការពិត វាជាវិធីសាស្ត្រមួយសមស្របនៅក្នុងកាលៈទេសៈដែលបានរកឃើញជាក់ស្តែងនៅក្នុងទីតាំងនេះតែម្តង នៅភ្នំត្រយ៉ូងនេះតែម្តង។” ទាក់ទងទៅនឹងគោលការណ៍មានពិរុទ្ធភាពនេះ គឺវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត គឺការដឹងឮប្រកបដោយហេតុផល ថានៅការដ្ឋានទំនប់ត្រពាំងថ្មតែប៉ុណ្ណោះ។ ធាតុចេតនាសម្លាប់ការរង្គាលនេះ គឺថាមិនអាចបំពេញលក្ខខណ្ឌ ដោយមិនមានភស្តុតាងចេតនាជាមុននោះបានទេ។

នៅក្នុងកថាខណ្ឌ៤៧ ដូចដែលសហព្រះរាជអាជ្ញាបានជំទាស់តវ៉ា ពាក់ព័ន្ធទៅនឹងការប្រើប្រាស់របស់សហចៅក្រមស៊ើបអង្កេតនូវចេតនាជាមុន ដែលលើកឡើងថា វាខុសទៅនឹងផ្លូវច្បាប់ ហើយនិងអង្គហេតុផងដែរ។ ទាក់ទងទៅនឹងចំណុចនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ផ្ទុយទៅនឹងការរៀបរាប់នៃការសម្លាប់នៅការដ្ឋានត្រពាំងថ្មរបស់ អ៊ឹម ចែម នៅភ្នំត្រយ៉ូង។ នេះគឺជាព្រឹត្តិការណ៍មួយដាច់ដោយឡែក។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា នេះវាខុសពីការរកឃើញផ្នែកអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតនៅភ្នំត្រយ៉ូង – មន្ទីរសន្តិសុខភ្នំត្រយ៉ូង ដែលថាសិទ្ធិអំណាចរបស់ អ៊ឹម ចែម គឺថាមាននៅទូទៅតែម្តង។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ការចូលរួមពាក់ព័ន្ធរបស់ អ៊ឹម ចែម ហើយនិងធាតុចេតនារបស់ អ៊ឹម ចែម គឺបានបង្ហាញយ៉ាងច្បាស់នៅក្នុងអង្គហេតុដែលបានរកឃើញនៅក្នុងដីកាដំណោះស្រាយ។ ក៏ប៉ុន្តែដូចដែល -- គឺថាតាមពិត អ៊ឹម ចែម គឺថាសហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា មានសិទ្ធិអំណាចទូទៅនៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង។

[១៤:១៦:០៧]

ហើយបញ្ហាពាក់ព័ន្ធទៅនឹងចេតនារបស់គាត់នេះ គឺជារឿងមួយសំខាន់ណាស់។ ក៏ប៉ុន្តែនៅក្នុងការស្វែងយល់យ៉ាងនេះ មានការពាក់ព័ន្ធជាក់ស្តែងតែម្តងទៅនឹងបញ្ហាដ៏ទូលំទូលាយនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង រួមទាំងបញ្ហាធាតុចេតនាពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល។ សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានពន្យល់ពាក់ព័ន្ធទៅនឹងកាលៈទេសៈដែលសហចៅក្រមស៊ើបអង្កេតបានរកឃើញ ដែលរកឃើញថាការសម្លាប់នេះ គឺថាកើតមានឡើងយូរមកហើយ អាចសម្លាប់ដោយមនុស្សខុសៗគ្នាប្រាំបីនាក់ឯណោះ។

សហព្រះរាជអាជ្ញាអន្តរជាតិហ្នឹង ខ្លួនគាត់ហ្នឹងបានលើកឡើងយ៉ាងវែងឆ្ងាយអំពីពេលវេលានៃការកាប់សម្លាប់នៅទីកន្លែងនេះ។ បើសិនណាជាយើងមើលទៅលើកាលៈទេសៈជាក់លាក់មួយចំនួន គឺថាសកម្មភាព និងអំពើរបស់ អ៊ឹម ចែម នេះ ត្រូវបានអនុញ្ញាតឲ្យមានការជះឥទ្ធិពលដែលតម្រូវឲ្យមាន

ធាតុចេតនា។ ដូចដែលបានលើកឡើងនៅក្នុងសាលដីកាសំណុំរឿង០០២/០១ ឯកសារ F36 កថាខណ្ឌ ៥២១ ការសម្លាប់រង្គាលតម្រូវឲ្យមានការរាប់ជាចំនួន តម្រូវឲ្យមានការរៀបចំយ៉ាងសំខាន់អំពីចេតនានៃលទ្ធផលបណ្តាលមកពីការបំផ្លិចបំផ្លាញនោះ ពីតាមរយៈចារី។ អ៊ីចឹងថា -- ចំណុចសំខាន់នោះ ថាតើចេតនាដឹងជាមុនហ្នឹង ហេតុអ្វីបានជាវាជាចំណុចមួយសំខាន់ចំពោះកាលៈទេសៈនៅចំពោះមុខនេះ។

ពាក់ព័ន្ធនឹងការរកឃើញថា អ៊ឹម ចែម បានបញ្ជាឲ្យសម្លាប់អ្នកទោសនៅមន្ទីរសន្តិសុខភ្នំត្រយូងចំនួនមួយលើក ក៏ប៉ុន្តែសហចៅក្រមស៊ើបអង្កេតមិនបានរកឃើញថាបញ្ជានេះ ថាជាបញ្ជាមួយជាទម្លាប់ទេ។ ផ្ទុយទៅវិញ សំអាងទាំងពីរ ទាំងនៅក្នុងដីកាដំណោះស្រាយក្តី គឺថាមានការលើកឡើងថា មានកាលៈទេសៈមួយបញ្ជាឲ្យសម្លាប់អ្នកទោសចំនួនបួននាក់។ នៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ២០១, ២១២ គឺថាមានការកាប់សម្លាប់ជាទូទៅបានកើតមានឡើងជាងជិត២ឆ្នាំ ដោយ --។ ដូច្នេះត្រូវតែមានការរកឲ្យឃើញថា គាត់មានការបញ្ជាជាទូទៅ មានចេតនាជាមុន។ ដូចគ្នានេះដែរ ចរិតលក្ខណៈនៃការកាប់សម្លាប់ដោយត្រួសៗនេះ វាមានការជាប់ពាក់ព័ន្ធ ប៉ុន្តែវាក៏វាតម្រូវឲ្យមានធាតុចេតនាជាមួយផងដែរ។ ទាំងសហចៅក្រមស៊ើបអង្កេត ទាំងមេធាវីការពារក្តី មិនបានរកឃើញថាការសម្លាប់នៅមន្ទីរសន្តិសុខត្រយូង គឺធ្វើឡើងដោយអន្លើនោះទេ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបបានពិចារណាថា កាលៈទេសៈអង្គហេតុជាក់ស្តែងនេះ ជាពិសេស គឺបានអូសបន្លាយពេលវេលាយ៉ាងវែង។

[១៤:១៩:៥១]

ទាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានលើកឡើងនៅក្នុងកថាខណ្ឌ៨២ នៃចម្លើយតប គឺថាការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិហ្នឹង គឺជាការយល់ច្រឡំទេ ក៏ប៉ុន្តែ ហើយម្យ៉ាងទៀតគឺថាចំណុចនេះមិនត្រឹមត្រូវទេ។ សហចៅក្រមស៊ើបអង្កេតក្នុងករណីនេះ មិនមែនតែម្នាក់ឯងទេ ពាក់ព័ន្ធទៅនឹងច្បាប់អន្តរជាតិនោះ។ បញ្ហាថាតើធាតុចេតនានៅក្នុងកាលៈទេសៈមួយចំនួន វាមានទំហំប៉ុន្មាន ពាក់ព័ន្ធទៅនឹងការសម្លាប់នេះ ដោយសារតែរយៈពេលវេលាយូរ ក៏ដូចជាចារីអាចមានច្រើននាក់។ តាមពិតទៅភាពដាច់ដោយឡែក ឬក៏ទាំងនៅ ជាពិសេសគឺនៅតុលាការ អាយ.ស៊ី.ធី.អ័រ បានសម្រេចទៅលើបញ្ហានេះ។ ឯកសារ D308/3/1/11.1.18 ត្រង់កថាខណ្ឌ៣៩៦ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ គឺនៅត្រង់កថាខណ្ឌ៨០៥។ កត្តាពាក់ព័ន្ធមួយចំនួន គឺត្រូវរកឲ្យឃើញពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល រួមទាំងពេលវេលានៃការកាប់សម្លាប់នោះផងដែរ។ ហើយជាពិសេស គឺយុត្តាធិការនៃពេលវេលា គឺថាវាជាបញ្ហាមួយសំខាន់ដែលបង្ហាញអំពីធាតុចេតនានេះផងដែរ។

ទី២ ហើយខ្ញុំគិតថា ករណីទាំងអស់នេះ ខ្ញុំលើកឡើងមកពីតុលាការ អាយ.ស៊ី.ធី.វ៉ាយ។ ចំណុចទី២ នៃការលើកឡើងមានករណីមួយទៀត មានព្រឹត្តិការណ៍មួយដាច់ដោយឡែក ហើយពេលវេលាក៏ខុសគ្នា ចារីក៏ខុសៗគ្នា ថាតើគេស្វែងរកធាតុចេតនាដោយរបៀបណា? នៅតុលាការ អាយ.ស៊ី.ធី.អ័រ ឯកសារ 308/3/1/11.1.5 នៅត្រង់កថាខណ្ឌ៥៧៦ អង្គជំនុំជម្រះតុលាការកំពូលហ្នឹង បានសម្រេចថា សាលាដំបូងក្នុងរឿងក្តីប៉ៃលដាំនេះ គឺមិនបានរកឃើញថា ការសម្លាប់នោះធ្វើឡើងដោយចារីផ្សេងៗគ្នា ហើយមានរយៈពេលយូរនោះទេ។ ស្រដៀងគ្នានេះផងដែរ នៅក្នុងករណីរបស់ ប៉ែតស្ព័រ គឺឯកសារ នៅត្រង់កថាខណ្ឌ៣៨៦ អង្គជំនុំជម្រះតុលាការកំពូលរកឃើញថា ការសម្លាប់រង្គាលនោះ គឺមិនត្រូវបានរកឃើញទេ គឺមិនបានរកឃើញ នៅក្នុងរយៈពេល២ខែ រកមិនឃើញអំពីរយៈពេលនៃការសម្លាប់នោះទេ។

សហចៅក្រមស៊ើបអង្កេត មិនមែនមានសិទ្ធិសម្រេចទៅលើអង្គហេតុទាំងអស់នេះតែប៉ុណ្ណោះទេ នៅពេលដែលសម្រេចទៅលើនៅភ្នំត្រយូងនោះ។ ក្នុងករណីនេះ សហចៅក្រមស៊ើបអង្កេត លក្ខខណ្ឌដែលត្រូវទាមទារឲ្យបង្ហាញនោះ គឺត្រូវបង្ហាញអំពីធាតុចេតនា ប៉ុន្តែមានការបង្ហាញ -- នៅក្នុងកថាខណ្ឌ ៤៨ នៃការឆ្លើយតប ពាក់ព័ន្ធទៅនឹងការសម្លាប់រង្គាល។

[១៤:២៤:២៧]

តាមពិតទៅ គឺថាវាមានដំណោះស្រាយមួយពាក់ព័ន្ធទៅនឹងយុត្តាធិការ ដែលខ្សែសង្វាក់នៃយុត្តាធិការមាននៅក្នុងរឿងក្តីស្តាហ្កិច ហើយនិងចូហ្កិច នៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ ដែលនៅក្នុងសារណារបស់យើងគឺថាបានគាំទ្រទៅដល់វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត។ ឧទាហរណ៍ នៅតុលាការ អាយ.ស៊ី.ធី.វ៉ាយ "គឺនៅឆ្នាំ១៩៩៩ កថាខណ្ឌ បានសម្រេចគាំទ្រទៅលើវិធីសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល។ ដោយបានប្រើប្រាស់នូវការបង្ហាញឲ្យឃើញនូវការសម្លាប់ទ្រង់ទ្រាយធំ" បញ្ចប់ការដកស្រង់។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានលើកឡើង អង្គជំនុំជម្រះដំបូងច្បាស់ហើយថា មីស៊ីឡឺវិក គឺបានដឹងអំពីសហឧក្រិដ្ឋកម្មរួមដែលប្រព្រឹត្តការសម្លាប់ដែលមានទ្រង់ទ្រាយដ៏ធំបែបនេះ។ ប្រសិនជាវាអាចបង្ហាញទៅបាន គឺថាយើង -- ប៉ុន្តែនេះគឺជាការវាយប្រហារជាទូទៅមួយ ប៉ុន្តែមិនហួសពីព្រំដែននេះទេ។

នៅក្នុងសាលក្រមរបស់ប្លែកហ្សូន អែន ចូហ្កិច គឺ IT 0260T ឯកសារ D308/3/1/11.1.5 ត្រង់កថាខណ្ឌ៥៧៦។ គាំទ្រវិធីសាស្ត្រនៅក្នុងរឿងក្តីវ៉ាស៊ីតចូវិក សូមដកស្រង់៖ "សាលាដំបូងនៃនៅក្នុងរឿងក្តីប្រេិតមីននេះ បានរកឃើញថា មីឡូស្សូវិក នេះបានដឹងអំពីសកម្មភាពរបស់ជនជាប់ចោទ ហើយវា

តម្រូវថា ជនជាប់ចោទនេះ ត្រូវតែមានធាតុចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។" មានន័យថា អង្គជំនុំជម្រះសាលាដំបូងនៃតុលាការនេះ គឺថាបានប្រើប្រាស់វិធីសាស្ត្រប្រហាក់ប្រហែលគ្នាទៅនឹងវិធីសាស្ត្រដែលប្រើប្រាស់នៅចំពោះមុខតុលាការយើងនេះ។ ពីព្រោះឧក្រិដ្ឋកម្មនេះ អាចត្រូវបានយកមកវាយតម្លៃឡើងវិញបាន ដើម្បីឲ្យវាស្របគ្នាទៅនឹងគោលការណ៍នៃការសម្រេចថា មានពិរុទ្ធភាព។

ខ្ញុំសូមចូលទៅផ្នែកទី២នៃសំអាងហេតុទី៣។ បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិមិនពាក់ព័ន្ធទៅនឹងលទ្ធផលទូទៅនៃការសម្រេចនៅក្នុងដីកាដំណោះស្រាយនោះទេ។ ទោះបីជាមានកំហុសអង្គច្បាប់ក្តី សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានជំទាស់តវ៉ា ឬក៏បង្ហាញឲ្យឃើញថា វាឈានទៅដល់ការរំលោភលើឆន្ទានុសិទ្ធិពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរងការជំទាស់នេះទេ។ បញ្ចប់ការដកស្រង់។ សំខាន់បំផុតនោះ ដូចដែលបានលើកឡើងនៅក្នុងចម្លើយតបរបស់មេធាវីការពារក្តី កថាខណ្ឌ៨៧ គឺដូចតទៅនេះ ការសម្លាប់នៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង ដែលសហព្រះរាជអាជ្ញាបាននិយាយថា វាស្មើនឹងការសម្លាប់រង្គាល គឺត្រូវបានសហចៅក្រមស៊ើបអង្កេតយកទីតាំងឧក្រិដ្ឋកម្មនេះ យកមកពិចារណាហើយវាយតម្លៃថា វាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាតនោះ។

[១៤:២៨:៤៣]

ចំណុចនេះ មានសរសេរនៅក្នុងដីកាដំណោះស្រាយ កថាខណ្ឌ២៨៥ ដល់២៨៨។ សហចៅក្រមស៊ើបអង្កេតបានពិចារណាអំពីការសម្លាប់ទាំងអស់ ក៏ដូចជាការស្លាប់ដែលបណ្តាលមកពីភាពអត់ឃ្លាននៅមន្ទីរសន្តិសុខភ្នំត្រយ៉ូង គឺស្មើនឹងការសម្លាប់ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិហើយ។ ក្នុងន័យនេះ គឺថាវាជាចំណុចមួយសំខាន់ដែលសហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងយកមកបញ្ជាចំពោះការសម្រេចរបស់សហចៅក្រមស៊ើបអង្កេត នៅកថាខណ្ឌ៣២៣ នៃដីកាដំណោះស្រាយ។ សូមដកស្រង់៖ "វាអាចមានចរិតលក្ខណៈផ្លូវច្បាប់ច្រើនផ្នែកទៅលើអង្គហេតុដូចគ្នា ហើយអនុញ្ញាតឲ្យមានការចោទប្រកាន់ច្រើនបទល្មើស ហើយក៏អាចមានឈានទៅដល់ការផ្តន្ទាទោសជនជាប់ចោទច្រើននាក់ដែរ ហើយដែលសំខាន់នោះ គឺវាពាក់ព័ន្ធទៅនឹងភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់ -- វាមិនមានអ្វីពាក់ព័ន្ធទៅនឹងសកម្មភាពធ្ងន់ធ្ងរៗរបស់ អ៊ឹម ចែម នោះទេ។ ថាតើបើសិនណា វាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តើវាអាចបង្ហាញនូវធាតុផ្សំផ្លូវច្បាប់ថ្មីដែរ ឬក៏យ៉ាងណា? ហើយចំណុចនេះ វាអាចមានស្ថានទម្ងន់ទៅលើឧក្រិដ្ឋកម្មនេះដែរ ឬក៏យ៉ាងណា?"

កត្តាសំខាន់បំផុតដែលសហចៅក្រមស៊ើបអង្កេតបានយកមកពិចារណា ពាក់ព័ន្ធទៅនឹងការវាយតម្លៃទៅលើយុត្តាធិការបុគ្គល គឺចំនួនជនរងគ្រោះ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងថា មានចំនួនអ្នកស្លាប់ប្រហែលជា២.០០០នាក់ នៅមន្ទីរសន្តិសុខភ្នំត្រយូង។ ហ្នឹងនៅពេលដែលឈានទៅដល់ការសម្រេចទៅលើយុត្តាធិការបុគ្គលហ្នឹង រកឃើញថា មានការសម្លាប់ប្រមាណជា ជនរងគ្រោះប្រមាណជា២.០០០នាក់។ អាចនិយាយម្យ៉ាងទៀត ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំឲ្យអង្គបុរេជំនុំជម្រះនោះ គឺថាមិនអាចពន្លាតការចោទប្រកាន់ទៅលើ អ៊ឹម ចែម ឬក៏ថាងាកចេញមិនចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ណាមួយរបស់ខ្មែរក្រហមនោះទេ។ ប្រសិនណាជាមានកំហុសអង្គច្បាប់ ថាចំណុចត្រង់នេះ គឺថាគឺជាចំណុចមួយដែលត្រូវធ្វើការវាយតម្លៃជាចុងក្រោយហើយ។

ឥឡូវ ខ្ញុំសូមចូលទៅដល់មូលដ្ឋានអង្គហេតុទី៤។ នៅក្នុងសំណើសុំរបស់យើង សហចៅក្រមស៊ើបអង្កេតគឺថាមិនបានប្រព្រឹត្តកំហុសអង្គច្បាប់ទេ នៅពេលដែលកំណត់អំពីបទល្មើសនេះ។ ហើយទី២ ទោះបីជាមានកំហុសអង្គ -- ទោះបីកំហុសអង្គច្បាប់ត្រូវបានរកឃើញក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានបង្ហាញឲ្យឃើញ ឬក៏បង្ហាញកំហុសអង្គច្បាប់ណាមួយដែលពាក់ព័ន្ធទៅនឹងការសម្រេចជារួមនេះដែរ។

[១៤:៣២:៤៥]

ពាក់ព័ន្ធទៅនឹងចំណុចទី១ នៅក្នុងសំណើសុំរបស់យើង សហព្រះរាជអាជ្ញាអន្តរជាតិបានបកស្រាយមិនត្រឹមត្រូវចំពោះវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត ចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល និងការបាត់ខ្លួន។ ទី១ សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយវិធីសាស្ត្រនៃនិយមន័យនៃឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំហ្នឹង មិនបានត្រឹមត្រូវទេ។ ដូចយើងឃើញ គឺថាមានការគាំទ្រតិចតួចណាស់សម្រាប់ការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំនេះ។ ក៏ប៉ុន្តែនៅពេលដែលយើងពិចារណា គឺថាទៅការគាំទ្រនេះ គឺថាវាមានលក្ខណៈជាអប្បបរមា ហើយមិនកែប្រែទៅដោយលទ្ធផលនៃសេចក្តីសម្រេចនេះទេ ទី១។ កថាខណ្ឌ៧៤ ក.ស.ច.សនេះ គឺថាបានលើកឡើងអំពីច្បាប់នេះយ៉ាងត្រឹមត្រូវ ហើយនិងបានសម្រេចថា និយមន័យនៃអំពើអមនុស្សធម៌ដែល -- និយមន័យនៃអំពើអមនុស្សធម៌របស់អង្គជំនុំជម្រះតុលាការកំពូលដែលវាស្ថិតនៅក្រោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយដែលបានរកឃើញថា ការបាត់ខ្លួនហ្នឹង ដែលគ្រាន់តែរកឃើញការបាត់ខ្លួនហ្នឹង អាចឲ្យស្មើនឹងអំពើអមនុស្សធម៌ហើយ។ នៅក្នុងសំណើសុំរបស់យើង គេមិន

អាចជំទាស់តវ៉ាបានទេ កាលណាលើកឡើងអំពីបញ្ហាច្បាប់យកមកនិយាយ គឺវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតលើកឡើងអំពីបញ្ហាកំហុសអង្គច្បាប់នេះ គឺមិនត្រឹមត្រូវទេ។

ទី២ នៅក្នុងកាលៈទេសៈមួយចំនួនចំពោះមុខនេះ សហចៅក្រមស៊ើបអង្កេតមិនអាចត្រូវរងការរិះគន់ ដែលថាមិន -- ថាតើបានពិចារណាទៅលើភស្តុតាងចំពោះគ្រួសាររបស់ជនដែលបានបាត់ខ្លួន ឬក៏ត្រូវគេសួរចម្លើយ ឬក៏អាចសួរអំពីជោគវាសនា ឬក៏ទីកន្លែងរបស់អ្នកបាត់ខ្លួននោះបានដែរឬទេ? នៅក្នុងសំណុំរឿងទី២ គឺ F36 ការសម្រេចថាតើមានអំពើបង្កើតឡើងជាអំពើអមនុស្សធម៌ដែរទេ តម្រូវរឿងក្តីនោះមានការវិភាគទៅលើផលប៉ះពាល់អំពើទៅលើជនរងគ្រោះ ដែលថាអំពើខ្លួនឯងនេះគឺទាក់ទងទៅនឹងជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែរឬទេ? យើងមិនអាចអះអាងដោយសមស្របថា គឺបញ្ហាថាតើមានភស្តុតាង ថាតើក្រុមគ្រួសារបានសួរអំពីអ្នកបាត់ខ្លួនដែរនោះឬទេនោះ? គឺមិនមែនជាបញ្ហាពាក់ព័ន្ធទេ ហើយក៏មិនមែនមានតម្លៃជាភស្តុតាង ថាតើអង្គហេតុនោះមានការបញ្ជាក់ច្បាស់លាស់អំពីមានចេតនាសត្យានុម័ត ឬអត្តនោម័តរបស់អំពើនោះដែរឬទេ?

[១៤:៣៥:៥៧]

ទាក់ទងទៅនឹងមូលដ្ឋានទី៣ គឺកាលណាយើងពិនិត្យអំពីចេតនាឧក្រិដ្ឋ គឺជាការងារលំបាកហើយនិងវែងឆ្ងាយ ដែលយើងសហព្រះរាជអាជ្ញាមិនគប្បីត្រូវបានអនុញ្ញាតឱ្យអាចដឹកដៃចៅក្រមស៊ើបអង្កេតឱ្យសម្រេចបែបម៉េច ដែលតាមអ្វីដែលខ្លួនចង់បាននោះទេ គឺទាក់ទងទៅនឹងការវាយតម្លៃលើឆន្ទានុសិទ្ធិរបស់ពួកគាត់។ ដូច្នេះគឺយើងគ្មានចម្ងល់អ្វីទេ គឺសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ដោយខ្លួនឯង យ៉ាងច្បាស់លាស់លើបញ្ហានេះ។ យើងអាចថានៅក្នុងកថាខណ្ឌ២៩៤ នៃដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា សុំដកស្រង់៖ “ការបដិសេធសំណើក្នុងការបង្ហាញភស្តុតាងអំពីទីកន្លែង ហើយនិងជោគវាសនារបស់ជនរងគ្រោះនោះ គឺជាធាតុផ្សំសំខាន់នៃបទឧក្រិដ្ឋ។ ទោះជាយ៉ាងណាក្តី វិធីពិនិត្យនេះគឺទាំងស្រុង គឺបង្ហាញអំពីអង្គហេតុនេះ គឺមិនអាចបំពេញទៅតាមការបាត់ខ្លួនដោយបង្ខំជានិយមន័យទំនើបនោះទេ។ នេះជា មិនមែនជាធាតុផ្សំដែលថា បុគ្គលគប្បីតែរកព័ត៌មានអំពីអ្នកបាត់ខ្លួននោះថាជាធាតុផ្សំទេ។ សហចៅក្រមស៊ើបអង្កេតចាត់ទុកភស្តុតាងនេះនៅក្នុងកាលៈទេសៈដែលទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋ ថាជាបញ្ហាដ៏សំខាន់ក្នុងការបង្ហាញអំពីការបំពេញនូវធាតុផ្សំនៃអំពើអមនុស្សផ្សេងទៀត។ ហើយជាពិសេសទៅទៀត គឺថាការពិចារណាឱ្យពួកគាត់បែងចែកហើយការបាត់ខ្លួនដោយបង្ខំ ដាច់ចេញពីឧក្រិដ្ឋកម្មផ្សេងទៀត ដូចជាការដាក់ពន្ធនាគារ ហើយនិង

មនុស្សឃាតជាដើម។

ដូចដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងកថាខណ្ឌ៩៨ របស់ខ្លួន ទោះបីនិយមន័យដ៏មិនច្បាស់លាស់ទាក់ទងទៅនឹងបទឧក្រិដ្ឋតាមនិយមន័យចាស់នោះ គឺថាក៏អាចមិនបើកលទ្ធភាពឲ្យសហចៅក្រមស៊ើបអង្កេតហ្នឹង គឺសន្និដ្ឋានថា អ្វីដូចដែលសហព្រះរាជអាជ្ញាលើកឡើងថា ថាការបាត់ខ្លួនហ្នឹង គឺបំពេញទៅតាមធាតុផ្សំនៃបទឧក្រិដ្ឋនោះទេ។ សហចៅក្រមស៊ើបអង្កេតត្រូវតែជឿជាក់ថា អំពើដោយចេតនា ឬក៏ការខកខានណាមួយដែលនាំឲ្យមានការបាត់ខ្លួន បណ្តាលឲ្យមានការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរ រាងកាយធ្ងន់ធ្ងរ ឬការរងរបួសដែលជាការបំពានទៅលើសិទ្ធិជាមូលដ្ឋានដែលបង្កឲ្យមានការឈឺចាប់ ឬរងរបួសរាងកាយផ្លូវចិត្តធ្ងន់ធ្ងរ ដែលស្ថិតនៅក្នុងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលបានចែងនិយមន័យនោះ។ នៅក្នុងន័យនេះ ខ្ញុំសូមបញ្ជាក់ថា ការអនុវត្តនូវគោលការណ៍វិធីសាស្ត្រភស្តុតាងដែលចោទជាបញ្ហាថាតើបុគ្គលមួយចំនួនត្រូវស្វះរកទីកន្លែងអ្នកដែលបាត់ខ្លួនមួយៗនោះ សហចៅក្រមស៊ើបអង្កេតបានពិចារណា ហើយនិងគោរពទៅតាមគោលការណ៍ដែលមានចែងនៅក្នុងនីតិវិធីដ៏ត្រឹមត្រូវរួចហើយ។

ក្រៅពីលើកឡើងនូវបញ្ហានេះ សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយខុសអំពីការអះអាងរបស់មេធាវីការពារក្តី ហើយនិងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត។ មេធាវីការពារក្តីមិនបានអះអាងដូចដែលអះអាងនៅក្នុងកថាខណ្ឌ៥២នៃការឆ្លើយតប សូមដកស្រង់៖ "គេមិនអាចសន្និដ្ឋានថា ការបាត់ខ្លួនអាចបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរលើផ្លូវចិត្ត ឬរូបរាយនោះទេ។" សហព្រះរាជអាជ្ញាបានលើកឡើងវិធីសាស្ត្រ គឺសហចៅក្រមស៊ើបអង្កេត អ្វីដែលរកឃើញនោះគឺ ហើយនិងថាជាមើលរំលងពីភាពសាមញ្ញដែលមេធាវីការពារលើកឡើងពីគោលជំហររបស់យើង។

[១៤:៤០:២៩]

អ្វីដែលលើកឡើងនៅថ្ងៃនេះ គឺថាលើកឡើងពីការវិភាគមួយចំនួនច្រើននូវអង្គហេតុដែលត្រូវការ ហើយយើងពិនិត្យមើលអ្វីដែលសហចៅក្រមស៊ើបអង្កេតបានសម្រេច។ ការវាយតម្លៃអំពីចេតនាឧក្រិដ្ឋ និងអំពើឧក្រិដ្ឋដែលជាធាតុផ្សំនៃការបាត់ខ្លួនដោយបង្ខំហ្នឹង គឺវាពាក់ព័ន្ធអ្វីខ្លាំងជាងការចាប់ខ្លួន ហើយនិងការបាត់ខ្លួនរបស់កម្មករ ជាពិសេសនៅស្ពានស្រែង ការដ្ឋានទំនប់ស្ពានស្រែងជាដើម។

គេមិនអាចសន្និដ្ឋានថា ការចាប់ខ្លួន ហើយនិងការបាត់ខ្លួន អាចបំពេញធាតុផ្សំនៃបទឧក្រិដ្ឋដោយស្វ័យប្រវត្តិទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ គឺមិនបានពិចារណាត្រឹមត្រូវទៅលើការឆ្លើយតបកថាខណ្ឌ៥២របស់យើង គឺថាអះអាងតែមួយគត់ ដែលថាការសន្និដ្ឋាន ការបាត់ខ្លួននោះ គឺបង្កនូវការ

ឈឺចាប់ខ្លួនរាងកាយ ផ្លូវចិត្តធ្ងន់។ ប៉ុន្តែអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី០២/១នោះ គឺថា អំពើអមនុស្សធម៌ផ្សេងទៀតដូចជា បានសម្រេចលើការជម្លៀសទីក្រុងភ្នំពេញ គឺការបំពានទៅលើសិទ្ធិសេរីភាព សិទ្ធិសន្តិសុខបុគ្គល ហើយនិងសេរីភាពធ្វើដំណើរនិងរស់នៅ គឺវាបានប៉ះពាល់ទៅលើសិទ្ធិរួចផុតពីអំពើឃោរឃៅ អមនុស្សធម៌ និងបន្ទាបបន្ថោក។ ដូច្នេះគឺវាអាចបង្កឲ្យប៉ះពាល់ដល់ផ្លូវចិត្ត និងផ្លូវកាយ ហើយក៏មិនអាច ដែលបង្កើតបានជាការវាយប្រហារលើសេចក្តីថ្លៃថ្នូរមនុស្ស គឺរឿងក្តី០០២/១ F36 កថាខណ្ឌ៦៥៦។ នៅក្នុងរឿងក្តី គឺអាចបញ្ជាក់ថា គឺមិនមានចៅក្រមសមហេតុផលណាមួយអាចសម្រេចផ្សេងពីនេះទេ។ គឺថាការជម្លៀសទីក្រុងភ្នំពេញ អាចនឹងជាការបំពានលើសិទ្ធិនោះទេ ប៉ុន្តែមិនអាចនឹងគួរឲ្យភ្ញាក់ផ្អើលនោះទេ គឺភស្តុតាងបង្ហាញថា ការជម្លៀសខ្លួន ការបាត់ខ្លួន ការចាប់ខ្លួន និងការឃុំខ្លួន គឺវាអាចនឹងប្រៀបធៀបបានទៅនឹងការបាត់ខ្លួនដោយបង្ខំនោះដែរ។

[១៤:៤៣:១៤]

សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងនៅក្នុងកថាខណ្ឌ៥១ របស់បណ្តឹងឧទ្ធរណ៍ សុំដកស្រង់៖ “ការឈឺចាប់ផ្លូវចិត្តចំពោះជនរងគ្រោះនៅស្ពានស្រែង គឺមិនខុសគ្នាពីអ្វីនៅក្នុងវិសាលភាពរឿងក្តី០០២/០១ទេ”។ នេះគឺជាការអះអាងមិនមានមូលដ្ឋានគ្រប់គ្រាន់នោះទេ ក្នុងការបង្ហាញពីការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ហើយក៏មិនអាចគ្រប់គ្រាន់ដើម្បីរិះគន់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងករណីនេះដែរ។ ដើម្បីស្វែងរកការអះអាងនេះ គឺថាសហព្រះរាជអាជ្ញាមិនបានបង្ហាញ គឺថាអង្គហេតុទាក់ទងទៅនឹងការចាប់ខ្លួន ហើយនិងការបាត់ខ្លួននៅស្ពានស្រែងនោះ គឺថាវាមានភាពធ្ងន់ធ្ងរ ឬក៏បង្កនូវការឈឺចាប់ផ្លូវចិត្តដូចម្តេចនោះ។ ដូច្នេះវា យើងនឹងរាយនូវអង្គហេតុមួយចំនួននៅក្នុងការលើកឡើងរបស់យើង។ នៅក្នុងករណីអង្គហេតុនៅក្នុងរឿងក្តីនេះ គឺយើងអះអាងទៅ យើងរកឃើញថា ដូចគ្នានឹងសហចៅក្រមស៊ើបអង្កេតនៅក្នុងអង្គជំនុំជម្រះសាលាដំបូង រឿងក្តី០០២ គឺថារកឃើញថាយ៉ាងហោចណាស់មនុស្ស២លាននាក់ ត្រូវបានជម្លៀសដោយបង្ខំចេញពីភ្នំពេញ ហើយនិងមានកាលៈទេសៈបំភិតបំភ័យឃោរឃៅ ហើយដោយមិនមានការប្រាប់ដំណឹងជាមុន ហើយនៅក្នុងរដូវក្តៅខ្លាំង មិនមានទឹក មិនមានស្បៀងអាហារ មិនមានទីជម្រក មិនមានការថែទាំសុខភាព ដែលរកឃើញនៅក្នុងសាលដីកា F36 កថាខណ្ឌ៦៥៥។

ដូចគ្នានេះដែរ សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងកថាខណ្ឌ៩៥, ៩៦ របស់ខ្លួន ដូចដែលយើងបាននិយាយនៅក្នុងការឆ្លើយតបរបស់យើង គាត់ត្រូវតែធ្វើឲ្យបានច្រើនជាងអ្វីដែលអះអាងថា សហ

ចៅក្រមស៊ើបអង្កេតបានខុសឆ្គងអំពីថាសមាជិកក្រុមគ្រួសារ មិនបានសួរអំពីជោគវាសនា ឬក៏ទីកន្លែងរបស់អ្នកបាត់ខ្លួននោះ ថាជាធាតុផ្សំ។ ពួកគាត់ត្រូវតែធ្វើឲ្យបានច្រើនជាងនេះ ដែលថានៅក្នុងកាលៈទេសៈដ៏ច្រើនរបស់របបខ្មែរក្រហម ការតម្រូវឲ្យបុគ្គលម្នាក់ៗសួរព័ត៌មានពីអង្គការ គឺមិនសមស្របនោះទេ។ ការសន្និដ្ឋានបែបនេះ គឺផ្អែកលើការសន្មតខ្លួនឯង។ អនុលោមទៅតាមសហព្រះរាជអាជ្ញា គឺថាមិនអាចនឹងយកជាបង្អែកបាននោះទេ។

ដូចដែលបានពន្យល់ដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងរឿងក្តី០០២/០១ សាលដីកា F36 កថាខណ្ឌ៥៨៦ បានសម្រេចថាតើអំពើជាក់លាក់បង្កើតបានជាអំពើអមនុស្សធម៌ផ្សេងទៀតដែរឬទេ តម្រូវឲ្យមានការវិភាគករណីពិសេសនីមួយៗ ជាពិសេស គឺផលប៉ះពាល់នៃអំពើទៅលើជនរងគ្រោះ ហើយនិងថាតើអំពើខ្លួនឯងនោះ គឺអាចនឹងបង្កើតបានជាបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែរឬទេ។ សំខាន់ជាងនេះទៅទៀត និយាយអំពីផ្នែកទី២ នៃការឆ្លើយតបទៅនឹងមូលដ្ឋានទី៤ ដូចដែលអះអាងទៅក្នុងកថាខណ្ឌ៩៩របស់ ទោះបីជាកំហុសអង្គច្បាប់កើតឡើង ដូចដែលលើកឡើងនៅក្នុងមូលដ្ឋានទី៣ សហព្រះរាជអាជ្ញាអះអាងពីភស្តុតាងថា វានាំឲ្យមានការបំពានទៅលើឆន្ទានុសិទ្ធិ ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរងការជំទាស់នោះទេ។

[១៤:៤៧:២៦]

ដូចគ្នានឹងមូលហេតុទី៣ដែរ ការកំណត់បទចោទនៅលើអង្គហេតុដែល គឺមិនបានបង្ហាញពីស្ថានទម្ងន់នៃអំពើរបស់ អ៊ឹម ចែម ទេ គឺនិយាយអំពីបញ្ហានេះនៅក្នុងកថាខណ្ឌ៣០២នៃដីកាដំណោះស្រាយ គឺមិនអាចនឹងរងការជំទាស់ដោយសហព្រះរាជអាជ្ញាបាននោះទេ ទោះបីជាសហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងក្នុងការសួររកធាតុផ្សំបន្ថែមក៏ដោយ សហព្រះរាជអាជ្ញាក៏បានខកខានមិនបានលើកឡើងថាតើដោយរបៀបដូចម្តេច ទាក់ទងទៅនឹងភាពទាំងមូលនៃបទឧក្រិដ្ឋដែលត្រូវយកមកពិចារណានោះ។ ជាពិសេស គឺភាពទាំងស្រុងនៃបទឧក្រិដ្ឋនៃអំពើប្រឆាំងមនុស្សជាតិ ហើយនិងមនុស្សឃាតដែលត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុងកថាខណ្ឌ៦៧ និង៧០នៃដីកាដំណោះស្រាយរួចហើយ។ ហើយការកំណត់បទចោទនូវការបាត់ខ្លួនដោយបង្ខំហ្នឹង គឺមិនបានមានផលប៉ះពាល់តិចតួចទៅលើការកំណត់ពីយុត្តាធិការបុគ្គលតែប៉ុណ្ណោះ។ នេះគឺជាការព្រួយបារម្ភខាងទ្រឹស្តី និយមន័យនៃការបាត់ខ្លួនដោយបង្ខំ គឺជាអំពើអមនុស្សធម៌ផ្សេងទៀត។ នោះគឺថាអំពើចេតនា ឬក៏ការខកខានដែលបណ្តាលឲ្យមានការឈឺចាប់ផ្លូវកាយ ផ្លូវចិត្តធ្ងន់ធ្ងរ ឬក៏រងរបួស គឺថាបង្កើត ឬក៏វាជាន់គ្នា សំខាន់ទៅលើបទឧក្រិដ្ឋ

ដូចជាការសម្លាប់ ជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ តាមពិតដូចជាមានចែងនៅក្នុងដីកាដំណោះស្រាយរួចហើយ។ នេះគឺជាគោលការណ៍ដ៏សំខាន់ ជាមូលដ្ឋានដ៏សំខាន់ដែលសហចៅក្រមស៊ើបអង្កេតបានផ្តោតអារម្មណ៍ខ្លាំង ថាមានការស៊ើបអង្កេតទាក់ទងទៅនឹងការបាត់ខ្លួន។ ដូចដែលបានកត់សម្គាល់ដោយសហចៅក្រមស៊ើបអង្កេតនៅកថាខណ្ឌ២០៣ សុំដកស្រង់៖ “មានភស្តុតាងដ៏ច្រើនថា ពលករត្រូវបានចាប់ខ្លួន គឺយកទៅបាត់ ហើយនិងបាត់ខ្លួនចេញពីមន្ទីរនោះ ហើយអ្នកទាំងអស់នោះដែលបាត់ខ្លួនពីការដ្ឋានអាចត្រូវបានគេសម្លាប់។” ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតបានដោះស្រាយពីអំពើនេះគឺអង្គហេតុនេះជាករណីដែលថាទាក់ទងទៅនឹងការដាក់ឃុំនេះ គឺជាអំពើឧក្រិដ្ឋ។ កំហុសឆ្គងអង្គច្បាប់គឺជាកំហុសឆ្គងនៃការកំណត់អង្គហេតុនោះ គឺមិនប៉ះពាល់ជាសំខាន់ទៅលើសេចក្តីសម្រេច ហើយក៏មិនអាចធ្វើឲ្យសេចក្តីវាយតម្លៃចុងក្រោយនោះទៅជាគ្មានសុពលភាពនោះដែរ។

[១៤:៥០:៤៨]

ឥឡូវនេះចូលទៅដល់មូលដ្ឋានទី៥ និងទី៦។ មូលដ្ឋានទាំងអស់នេះ និយាយអំពីការអះអាងថាសហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងអង្គហេតុ និងអង្គច្បាប់ ដែល អ៊ឹម ចែម គាត់បានប្រព្រឹត្តនៅភូមិភាគនិរតី ដើម្បីសង្ខេបសេចក្តីសន្និដ្ឋានចំពោះមុខអង្គបុរេជំនុំជម្រះរបស់ខ្លួនក៏ដោយ ហើយនិងអ្វីដែលព្រះរាជអាជ្ញាលើកពីម្សិលមិញនោះក៏ដោយ ទាំងពីរ គាត់បានអះអាងថា ផ្អែកលើការពិចារណាដ៏ត្រឹមត្រូវគឺមិនមានតុលាការដ៏សមហេតុផលណាមួយ។ ដើម្បីសង្ខេប ទាំងសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរចំពោះមុខអង្គបុរេជំនុំជម្រះ ហើយនិងការសន្និដ្ឋានផ្ទាល់មាត់លើបញ្ហានេះកាលពីម្សិលមិញ ដែលសហព្រះរាជអាជ្ញាអះអាងថា គឺការពិនិត្យត្រឹមត្រូវលើភស្តុតាង គឺគ្មានតុលាការណាអាចនឹងរកឃើញថា អ៊ឹម ចែម បានកាន់តំណែងដែលមានកម្រិតនៅភូមិភាគនិរតី គឺគ្រាន់តែជាប្រធានសមាគមនារីតំបន់១៣។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថាមួយ គឺមិនមានចៅក្រមសមហេតុសមផលណាមួយដែលអាចនឹងខកខាន មិនបានរកឃើញថា អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែតនោះទេ។ ហើយសហចៅក្រមស៊ើបអង្កេតបានខកខានមិនបានវាយតម្លៃត្រឹមត្រូវលើភស្តុតាងនៅក្នុងដីកាដំណោះស្រាយដែលមានសំអាងហេតុ។ ទី២ សហព្រះរាជអាជ្ញាបានអះអាងថា មិនមានចៅក្រមស៊ើបអង្កេតសមហេតុផលណាមួយដែលអាចនឹងខកខានមិនបានរកឃើញថា អ៊ឹម ចែម មិនមែនជាសមាជិកគណៈកម្មាធិការនៅតំបន់១៣នោះទេ។ ហើយខកខានមិនបានយោងទៅរកភស្តុតាងដែលពាក់ព័ន្ធនោះ។

ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងពីបញ្ហាអង្គហេតុខុសជាប់ពីរ។ ទី១ គឺ

អះអាងថា បទសម្ភាសន៍ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា គឺមិនត្រូវបានវាយតម្លៃត្រឹមត្រូវ។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា ភស្តុតាងបង្ហាញថា អ៊ឹម ចែម គាត់បានទទួលស្គាល់ដោយគ្មានលក្ខខណ្ឌថាគាត់បានកាន់តួនាទីជាលេខាស្រុកកោះអណ្តែត ហើយសមាជិកនៃគណៈតំបន់១៣។ ទី២ គាត់អះអាងថា ចម្លើយរបស់សាក្សីដែលស៊ីសង្វាក់គ្នាច្រើន ហើយអាចនឹងធ្វើឱ្យយល់ច្រឡំ ហើយមិនបង្ហាញត្រឹមត្រូវអំពីការពិចារណារបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងដីកាដំណោះស្រាយ។ អនុលោមតាមសហព្រះរាជអាជ្ញាអន្តរជាតិ ចម្លើយទាំងអស់នេះ គឺគ្រប់គ្រាន់ ស៊ីសង្វាក់ដែលថា អ៊ឹម ចែម បានច្បាស់ណាស់ដោយគ្មានចម្ងល់ថា អ៊ឹម ចែម គឺជាលេខាស្រុកកោះអណ្តែត ហើយនិងសមាជិកនៃគណៈតំបន់១៣។

ផ្អែកតាមមូលដ្ឋានកំហុសឆ្គងអង្គហេតុពីរនេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើថា នៅកថាខណ្ឌដដែលនេះ សុំដកស្រង់៖ "គឺជាការវាយតម្លៃជាថ្មីអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម សាជាថ្មី តាមទម្រង់សហកម្មឧក្រិដ្ឋកម្មរួម ទាក់ទងនឹងឧក្រិដ្ឋកម្មនៅភូមិភាគនិរតី" ចប់សេចក្តីដកស្រង់។ នៅក្នុងយើងនឹងបំភ្លឺនូវចំណុចពីរ ទាក់ទងទៅនឹងមូលដ្ឋានទី៥នេះ និងទី៦ ដែលបង្ហាញថាការអះអាងរបស់សហព្រះរាជអាជ្ញា ហើយនិងសំណើជាបន្តបន្ទាប់ សុំឱ្យមានការវាយតម្លៃជាថ្មីអំពីការទទួលខុសត្រូវរបស់ អ៊ឹម ចែម តាមសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងភូមិភាគនិរតី ដើម្បីច្រានចោលនូវអង្គសេចក្តីនោះ។ ទី១ គឺថាសហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានលើកឡើងអំពីស្តង់ដារបណ្តឹងឧទ្ធរណ៍ត្រឹមត្រូវដែលលើកឡើងនៅក្នុងមូលដ្ឋាន៥ និង៦។ ការខកខាននេះ គឺធ្វើឱ្យទឡ្ហីករណ៍របស់គាត់មិនអាចធ្វើឱ្យមានផលប៉ះពាល់ទៅលើសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតលើយុត្តាធិការបុគ្គលបានទេ។ បញ្ហាទី២ យើងសូមជម្រាបថា សហចៅក្រមស៊ើបអង្កេតបានអនុម័តដោយប្រុងប្រយ័ត្ននៅពេលដែលគាត់ពឹងផ្អែកទៅលើចម្លើយរបស់ អ៊ឹម ចែម ពី ឌី.ស៊ី.ខេម នោះគឺបានពិនិត្យមើលភស្តុតាងទាំងមូលនៅក្នុងសំណុំរឿង មុននឹងដល់សេចក្តីវាយការណ៍ទាក់ទងទៅនឹងការចោទប្រកាន់របស់សហព្រះរាជអាជ្ញានោះ។

[១៤:៥៦:៤៤]

ការវាយតម្លៃទៅលើចម្លើយមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយនិងចម្លើយរបស់សាក្សីនានាដែលថាមានភាពស៊ីសង្វាក់នោះ គឺជាវិធីសាស្ត្រសមហេតុផលទាំងស្រុងមួយសម្រាប់ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត។ និយាយដោយសរុប សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងអំពីការ

អះអាងដែលមានវិការៈក្នុងទម្រង់ ហើយនិងមានកំហុសឆ្គងនៅក្នុងសារធាតុ ដោយថាខ្លួនខកខានមិនបានបញ្ជាក់អំពីថាដូចម្តេចដែលសហចៅក្រមស៊ើបអង្កេត ការរកឃើញរបស់គាត់នោះពាក់ព័ន្ធទៅនឹងមុខតំណែងរបស់ អ៊ឹម ចែម--

**ប្រធានអង្គបុរេ៖**

សូមស្នើសម្រាកមួយ ឬពីរនាទី ដើម្បីប្តូរ ឌី.វី.ឌី។

*(សម្រាករយៈពេលខ្លី)*

សូមអញ្ជើញបន្តទៀតបាទ!

**លោក វេញ ហ្សកដាហ្ស៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះខ្ញុំត្រឡប់ទៅចំណុចទី១ របស់ខ្ញុំវិញ។ សហព្រះរាជអាជ្ញាបានខកខានមិនបានអះអាងអំពីស្តង់ដារដ៏ត្រឹមត្រូវនៃការពិនិត្យឡើងវិញ។ នៅក្នុងមូលដ្ឋាន៥ និង៦ សហព្រះរាជអាជ្ញាបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានមានកំហុសឆ្គងអង្គហេតុ ហើយគាត់អះអាងថាខ្ញុំ គឺនៅកថាខណ្ឌ៥៨នៃបណ្តឹងឧទ្ធរណ៍៖ “គឺថាមិនមានចៅក្រមសមហេតុផលណាដែលថាមិនយល់ថា អ៊ឹម ចែម ជាលេខាស្រុកកោះអណ្តែត។ ហើយនៅកថាខណ្ឌមួយទៀត គឺថាមិនមានចៅក្រមសមហេតុផលណាដែលមិនអាចរកឃើញថា គាត់ជាសមាជិកនៃគណៈតំបន់១៣នោះទេ” ចប់សេចក្តីដកស្រង់។ ទោះយ៉ាងណាក្តី សហព្រះរាជអាជ្ញាអន្តរជាតិមិនបានអះអាងថាតើស្តង់ដារដែលតម្រូវឱ្យមានការពិនិត្យឡើង ថាតើត្រូវរកឱ្យឃើញ ឱ្យច្បាស់ថាទាក់ទងទៅនឹងមូលដ្ឋានទាំងអស់នេះ ដើម្បីនឹងចោទលទោសជនសង្ស័យនៃបណ្តឹងឧទ្ធរណ៍នេះ។ ការខកខានមិនបានពិនិត្យមើលនៃសេចក្តីសម្រេចទាក់ទងនេះ គឺពួកគាត់មិនអាចបង្ហាញពីភាពពាក់ព័ន្ធទៅនឹងការវាយតម្លៃជាទូទៅរបស់សហចៅក្រមស៊ើបអង្កេត។ ហើយក៏មិនអាចឱ្យអង្គបុរេជំនុំជម្រះកំណត់ថាតើកំហុសឆ្គងហ្នឹងដូចម្តេច ប្រសិនបើមាន តើអ្វីខ្លះ? តើវាមានការប៉ះពាល់ដល់សេចក្តីសម្រេចទូទៅដូចម្តេច? ទាំងមូលហ្នឹងទេ?

[១៥:00:១0]

គឺសហព្រះរាជអាជ្ញាខ្លួនឯង ក្នុងការពន្យល់ថាតើផលប៉ះពាល់លើសេចក្តីសម្រេចរួមនោះដូចម្តេច? ឬក៏សូមឱ្យ -- អត់ឱ្យអង្គបុរេជំនុំជម្រះហ្នឹងចោលទោសសេចក្តីសម្រេចនោះ ហើយធ្វើការវាយតម្លៃទាំងស្រុងទាំងឡើងវិញ ទាក់ទងទៅនឹងការលើកឡើងពីកំហុសនេះ។ អង្គហេតុដែលថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានលើកឡើងនេះ គឺថាអាចបង្ហាញអំពីទំហំដែលថាខ្លួនមិនបានលើកឡើងឱ្យ

ច្បាស់អំពីកំហុសឆ្គងដែលនាំឲ្យមានវិការៈ សេចក្ដីវាយតម្លៃ។ អ្វីដែលគាត់ធ្វើនៅទីបញ្ចប់នោះ កាលនោះគឺដោយមិនមាន ដែលគាត់មិនបានកំណត់អំពីស្តង់ដារបណ្ដឹងឧទ្ធរណ៍នោះ គឺមិនបង្កើតអ្វីច្រើនជាងសំណើទៅអង្គបុរេជំនុំជម្រះ ដើម្បីពិនិត្យមើលបណ្ដឹងនេះឲ្យបានទាន់ពេល។ ហើយចង់ឲ្យអង្គបុរេហ្នឹងដាក់ជំនួសសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយទស្សនៈរបស់ខ្លួន។ នៅក្នុងរឿងក្តី០២ គឺ D1/61/1.136។

ឥឡូវនេះខ្ញុំត្រឡប់ទៅចំណុចទី២ ចុងក្រោយរបស់ខ្ញុំ។ វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការប្រមូលភស្តុតាង។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតក្នុងការស្វែងរកភស្តុតាងនេះ គឺចោទជាបញ្ហា ហើយមិនមានអ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផលណាមួយអាចសម្រេចបែបនេះដែរ។ ទោះជាយ៉ាងណា ដូចដែលបានលើកឡើងនៅក្នុងកថាខណ្ឌ១០៧ ដល់១០៧ នៃចម្លើយតប នៅពេលដែល -- បាទគឺកថាខណ្ឌ១០៧ ដល់១០៩ ដែលសហចៅក្រមស៊ើបអង្កេតគឺបានអនុវត្តយកវិធីសាស្ត្រមួយដែលសមស្រប និងប្រកបដោយការប្រុងប្រយ័ត្ន នៅពេលដែលយោងទៅលើចម្លើយដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានវាយតម្លៃប្រកបទៅដោយហេតុផលទៅលើការសម្ភាសជាមួយ អ៊ឹម ចែម ពីសំណាក់មជ្ឈមណ្ឌលឯកសារកម្ពុជា។

[១៥:០៣:០០]

ហើយពាក់ព័ន្ធទៅនឹងការមិនមានការកាត់ទោស គឺថាពាក់ព័ន្ធទៅនឹងវិមតិសង្ស័យ បានជាគោលការណ៍នៃវិមតិសង្ស័យ បានជាប្រយោជន៍នៃជនជាប់ចោទនេះ ក៏បានសម្រេចយ៉ាងត្រឹមត្រូវដែរ។ ដូច្នេះទី១ យើងខ្ញុំសូមបញ្ជាក់ថា ការពិចារណារបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធទៅនឹងភស្តុតាងដ៏ច្រើនដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈច្បាប់ស្តីពីការបង្កើតអ.វ.ត.ក។ កថាខណ្ឌ១០៣ ដល់១០៨ នៃដីកាដំណោះស្រាយ ក.ស.ច.ស បានវិភាគតម្លៃភស្តុតាងទៅលើចម្លើយទាំងអស់នោះ។ ក្រៅពីកំណត់ហេតុស្តាប់ចម្លើយសាក្សី ជាពិសេសពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយដែលបានបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតនេះតែម្តង។ ចម្លើយដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាកិច្ចសម្ភាសន៍ដែលធ្វើឡើងសហព្រះរាជអាជ្ញា និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។ ទាក់ទងទៅនឹងចម្លើយពីមជ្ឈមណ្ឌលឯកសារកម្ពុជា សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា កថាខណ្ឌ១០៤នៃដីកាដំណោះស្រាយ ថាចម្លើយដែលមជ្ឈមណ្ឌលឯកសារកម្ពុជា

ទទួលបាន សុំដកស្រង់៖ "គឺថាវាមានការពាក់ព័ន្ធជាបឋមដែលអាចឲ្យជំទាស់តវ៉ា ហើយក៏អាចជឿជាក់បាន" បញ្ចប់ការដកស្រង់។ ក៏ប៉ុន្តែពួកគេបានទទួលស្គាល់ សូមដកស្រង់៖ "ចម្លើយទាំងអស់នេះ គឺបង្កើតឡើងដោយមិនមានការធានាតាមផ្លូវតុលាការ និងជាផ្លូវការដែលចរិតលក្ខណៈនៃកំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះ" បញ្ចប់ការដកស្រង់។

[១៥:០៥:៤៨]

កថាខណ្ឌ១០៨ នៃដីកាដំណោះស្រាយសន្និដ្ឋានទៅលើការវិភាគទៅលើភស្តុតាង តម្លៃនៃភស្តុតាងនៃចម្លើយទាំងអស់នេះតែម្តង។ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា សុំដកស្រង់៖ "សរុបមក និងការថ្លឹងថ្លែងទៅលើការពិចារណាទាំងអស់នេះ កំណត់ហេតុស្តាប់ចម្លើយដែលបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ក៏ដូចជាប្រតិចារឹកសវនាការ គឺថាវាមានតម្លៃជាភស្តុតាងខ្ពស់ជាងចម្លើយដែលរៀបចំឡើងដោយស្ថាប័នដទៃទៀត។" ពាក់ព័ន្ធទៅនឹងចំណុចចុងក្រោយនេះ វិធីសាស្ត្រប្រកបដោយការប្រយ័ត្ននេះត្រូវបានសម្រេចឡើងសម្រាប់ធ្វើការវាយតម្លៃ ហើយព័ត៌មានដែលមាននៅក្នុងនោះ ក៏ត្រូវបានយកមកយោងនោះ គឺថាមានស៊ីសង្វាក់គ្នាជាមួយនឹងប្រភពភស្តុតាងដទៃទៀត។ នៅក្នុងសារណារបស់យើងខ្ញុំ គឺថាវិធីសាស្ត្រទាំងអស់នេះគឺថាមិនមានកំហុសអីទេ។

កថាខណ្ឌ១០៧ ដល់១២០ នៃចម្លើយតបរបស់យើង យើងបានលើកឡើងលម្អិត ថាតើសហចៅក្រមស៊ើបអង្កេតលើកឡើងច្បាស់ប៉ុនណាដែរ ដែលថាកំណត់ហេតុនៃការស្តាប់ចម្លើយដែលបង្កើតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ គឺថាវាមានភាព មានសច្ចធារណ៍នៃភាពគួរឲ្យជឿជាក់បានយ៉ាងខ្ពស់។ ហើយចម្លើយដទៃទៀត ដូចជាចម្លើយមកមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានយកមកប្រើប្រាស់យ៉ាងប្រុងប្រយ័ត្ន ត្រូវបានយកមកសំអាងយ៉ាងប្រុងប្រយ័ត្ន ហើយវាក៏ស៊ីសង្វាក់គ្នាជាមួយនឹងប្រភពដទៃទៀតដែរ។

[១៥:០៦:៣៨]

ក៏ប៉ុន្តែនៅកថាខណ្ឌ៥៩ នៃការឆ្លើយតបរបស់គាត់ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការជំទាស់តវ៉ាថា មេធាវីការពារក្តីហ្នឹងបកស្រាយដីកាដំណោះស្រាយនេះខុស នៅពេលដែលលើកឡើងថាសហចៅក្រមស៊ើបអង្កេតបានសម្រេចថា ចម្លើយដែលបានពីមជ្ឈមណ្ឌលឯកសារអាចយោងបាន យកមកសំអាងបានតែក្នុងករណីដែលវាស៊ីសង្វាក់គ្នាទៅនឹងប្រភពភស្តុតាងដៃទៀត។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងនៅក្នុងដីកាដំណោះស្រាយ សុំដកស្រង់៖ "គឺមិនមានការសម្រេចណាមួយឲ្យបាន

ច្បាស់លាស់នោះទេ” បញ្ចប់ការដកស្រង់។ សហចៅក្រមស៊ើបអង្កេតមិនបានយោងឲ្យបានច្បាស់លាស់ទៅលើចម្លើយដែលមជ្ឈមណ្ឌលឯកសារបានប្រមូលមក នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើង ហើយនិងសហចៅក្រមស៊ើបអង្កេតលើកយកមកសំអាងតែក្នុងករណីណាដែលវាស៊ីសង្វាក់គ្នាទៅនឹងប្រភពដទៃទៀតតែប៉ុណ្ណោះ។

ដូចដែលខ្ញុំបានបញ្ជាក់ហើយ យើងបានបញ្ជាក់យ៉ាងច្បាស់លាស់ហើយ តាមរយៈការវិភាគទៅលើការសម្ភាសដោយអ្នកសម្ភាសពីរនាក់ដែលបានសម្ភាសអ្នកស្រី អ៊ឹម ចែម នោះ។ សហចៅក្រមស៊ើបអង្កេតនៅក្នុងកថាខណ្ឌ១៣៩ នៃដីកាដំណោះស្រាយ ដកស្រង់៖ “គឺថាមានចម្លើយពីរដែល អ៊ឹម ចែម បានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ ចម្លើយមួយ គឺនិយាយអំពីយុវសន្តិភាព។ ទីមួយទៀតយើងហៅថា *ស្នាយលើងថូតប្រូដាកសិន*” ដែលត្រូវបានយកមកពិចារណានៅក្នុងដីកាដំណោះស្រាយប្រកបដោយហេតុផលនេះ។

[១៥:០៨:៣០]

ភាពស៊ីសង្វាក់គ្នាទៅនឹងវិធីសាស្ត្រដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង០០២ និងវិធានទូទៅនៃការវាយតម្លៃភស្តុតាងបានពន្យល់នៅក្នុងផ្នែកនេះ ហើយចម្លើយទាំងអស់នេះ គឺថាមានតម្លៃភស្តុតាងទាបជាងកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយភាពឲ្យជឿជាក់បាននៃចម្លើយទាំងអស់នេះ ក៏ដូចជាតម្លៃនៃភស្តុតាងនេះ គឺត្រូវបានយកមកវាយតម្លៃដោយយោងទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង។ សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតទៅលើតម្លៃនៃភស្តុតាងនេះ គឺដែលក្នុងនោះរួមមានទាំងចម្លើយពីមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈករណីយុត្តិសាស្ត្ររបស់ អ.វ.ត.ក នៅក្នុងសំណុំរឿង០០២។

មជ្ឈមណ្ឌលឯកសារកម្ពុជា មិនមែនប្រមូលឯកសារនេះដើម្បីយកមកប្រើប្រាស់ក្នុងតុលាការព្រហ្មទណ្ឌនោះទេ។ នៅក្នុងឆ្នាំ២០០៧ និងឆ្នាំ២០០៨ ខ្ញុំយោងឯកសារ D123/1/5.1a ដែលពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យចន្លោះពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ ហើយនៅក្នុងឆ្នាំ២០១២ គឺឯកសារ D123/5/1/5.1 “គ” ដែលបានរៀបចំ និងរៀបចំឡើងនៅក្នុងសៀវភៅមគ្គុទេសក៍ទេសចរណ៍អំពីអន្លង់វែង។ បញ្ចប់ការដកស្រង់។

[១៥:១០:២៦]

ជំនួសឲ្យការប្រឈមមុខដូចគ្នាទៅនឹងករណីយុត្តិសាស្ត្រដែលបានរកឃើញនេះ ហើយនិងហេតុ

ផលថាហេតុអ្វីបានជាចម្លើយដែលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលចាត់ទុកថាមានតម្លៃភស្តុ-តាងខ្ពស់ទៅបាននោះ គឺបញ្ហា គឺនេះគឺត្រូវបានជៀសវាងហើយ។ សរុបមកតុលាការប្រកបទៅដោយហេតុផលណាមួយដែលបានបង្ហាញអំពីច្បាប់ ក៏ដូចជាអំពីអង្គហេតុហ្នឹង គឺថាមានកាតព្វកិច្ចសម្រេចតាមវិធីសាស្ត្រនេះ ហើយធានាថា ចម្លើយរបស់ អ៊ឹម ចែម ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ។

តាមសំណើសុំរបស់ខ្ញុំ ការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងការកត់សម្គាល់ទៅលើភស្តុតាង មិនមែនជាការរិះគន់បែបនេះទេ។ នៅក្នុងកថាខណ្ឌ១៤៤នៃដីកាដំណោះស្រាយ ក.ស.ច.ស បានសម្រេចថា ភស្តុតាងនៅក្នុងសំណុំរឿង គឺថាបានគាំទ្រទៅដល់ការយល់ស្របដែលថា អ៊ឹម ចែម នេះគឺជាលេខានៅស្រុកកោះអណ្តែត និងជាសមាជិកនៃគណៈកម្មការ និងជាសមាជិកគណៈតំបន់១៣នៅភូមិភាគនិរតី ដែលនៅក្នុងភូមិភាគនិរតីនេះ គាត់គ្រាន់តែជាប្រធានសមាគមនារីក្នុងតំបន់១៣តែប៉ុណ្ណោះ។ ដូច្នេះតាមសំណើរបស់យើងខ្ញុំ វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត គឺមិនមែនគ្រាន់តែសមហេតុផលនោះប៉ុណ្ណោះទេ ក៏ប៉ុន្តែវាជាឧទាហរណ៍មួយដ៏ល្អ ថាតើតុលាការនេះគួរតែប្រើប្រាស់វិធីសាស្ត្រនេះដោយរបៀបណាដើម្បីឲ្យវាស៊ីសង្វាក់គ្នាទៅនឹងភស្តុតាងណាមួយ។ ហើយជាពិសេសដោយសារភស្តុតាងមួយចំនួននៅក្នុងសំណុំរឿង គឺថាវាមានភាពមិនច្បាស់លាស់ អ៊ីចឹងៗត្រូវតែមានបំពេញលក្ខខណ្ឌនៃភស្តុតាង មុននឹងឈានទៅដល់ការសន្និដ្ឋានអំពីតួនាទីណាមួយរបស់ អ៊ឹម ចែម នៅក្នុងភូមិភាគនិរតីនោះ។

[១៥:១២:៥៧]

ទី១ ចម្លើយរបស់ អ៊ឹម ចែម ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា បានផ្តល់ភស្តុតាងយ៉ាងច្បាស់លាស់ ដូចដែលបានលើកឡើងកាលពីម្សិលមិញនោះ គឺជាភស្តុតាងមួយជាក់ច្បាស់តែម្តង។ ទាក់ទងទៅនឹងតួនាទីរបស់ អ៊ឹម ចែម ថាជាលេខាស្រុកកោះអណ្តែត សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថាសហព្រះរាជអាជ្ញាអន្តរជាតិបានសំអាងការចោទប្រកាន់របស់ខ្លួន សុំដកស្រង់៖ “ចម្លើយរបស់ អ៊ឹម ចែម មួយ និងភស្តុតាងរបស់សាក្សីម្នាក់ អាចរកបាននៅក្នុងឯកសារ D308/3 ត្រង់កថាខណ្ឌ១៤៥នៃដីកាដំណោះស្រាយ និងបន្ទាប់ពីការវិភាគទៅលើចំណុចទាំងពីរ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានទៅលើភស្តុតាងថា ភស្តុតាងនេះគឺមិនបានគាំទ្រទៅដល់ការលើកឡើងនេះទេ។”

សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា កថាខណ្ឌ៥៩នៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហ

ចៅក្រមស៊ើបអង្កេត សុំដកស្រង់៖ "ខកខានមិនបានវាយតម្លៃឲ្យបានត្រឹមត្រូវចំពោះកិច្ចសម្ភាសន៍របស់ អ៊ឹម ចែម ដែលបានលើកឡើងថា គាត់ជាលេខាស្រុកកោះអណ្ដែត" បញ្ចប់ការដកស្រង់។ ហើយនិងបានលើកឡើងថា ចម្លើយរបស់គាត់ សុំដកស្រង់៖ "ច្បាស់លាស់ណាស់" បញ្ចប់ការដកស្រង់។ សហព្រះរាជអាជ្ញាអន្តរជាតិចង្អុលបង្ហាញកិច្ចសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីគាំទ្រដល់ការអះអាងថាសហចៅក្រមស៊ើបអង្កេតមានកំហុស។ ទី១ គឺថាគាត់ត្រូវបានចាត់តាំងដោយអាជ្ញាធរខេត្តឲ្យទទួលខុសត្រូវរៀបចំប្រជាជននៅស្រុកកោះអណ្ដែត។ ទី២ គាត់គឺ អ៊ឹម ចែម ហ្នឹង សុំដកស្រង់៖ "បានដឹកនាំប្រជាជនធ្វើការនៅតាមស្រែ" បញ្ចប់ការដកស្រង់ "និងកន្លែងដទៃទៀតដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ជារួមតែម្ដង" បញ្ចប់ការដកស្រង់ ហើយនិងបានជួយប្រជាជនកោះអណ្ដែតជាទូទៅ។ ចំណុចទី៣ "គាត់ត្រូវបានបញ្ជូនទៅស្រុកកោះអណ្ដែត ដោយសារតែគាត់បំពេញផែនការបាន" បញ្ចប់ការដកស្រង់។ ចំណុចទី៤ គាត់ចូលរួមពាក់ព័ន្ធនៅក្នុងការបង្កើតគោលនយោបាយនៅក្នុងស្រុកកោះអណ្ដែត។

[១៥:១៥:៣៤]

ការពិនិត្យប្រកបទៅហេតុផលនេះ គឺវាគាំទ្រទៅដល់ចំណុចមួយចំនួនពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់នេះ។ មិនមានតុលាការប្រកបទៅដោយហេតុផលណាមួយ អាចរកឃើញថា អ៊ឹម ចែម នេះកាន់កាប់គ្រប់គ្រងតួនាទីជាលេខាស្រុកកោះអណ្ដែតនោះទេ។ ខណ:ដែលសហព្រះរាជអាជ្ញាអន្តរជាតិក្នុងកថាខណ្ឌ៦០នៃបណ្ដឹងឧទ្ធរណ៍របស់ខ្លួននោះ គឺថា លោកស្រី អ៊ឹម ចែម ត្រូវបានយោងទៅលើគណ:កម្មការហ្នឹង គឺថាគាត់ទទួលខុសត្រូវ សូមដកស្រង់៖ "គាត់ទទួលខុសត្រូវស្រុកកោះអណ្ដែត"។ គឺថាសហព្រះរាជអាជ្ញាបានលុបចោលនូវអង្គហេតុដែលថា អ៊ឹម ចែម គាត់បានបញ្ជាក់យ៉ាងច្បាស់ពីខាងដើម ថាគាត់មិនមែនជាលេខា សុំដកស្រង់៖ "គាត់មិនមែនជាលេខាស្រុកទេ" បញ្ចប់ការស្រង់។ តាមពិត សុំដកស្រង់៖ "គាត់ទទួលបន្ទុកទៅនារី" (បញ្ចប់ការដកស្រង់) ចំណុចនេះគឺគាត់បង្ហាញមួយផ្នែកជូននៅក្នុងកិច្ចសម្ភាសន៍របស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារ។ នេះគឺវាអាចឆ្លើយតបទៅនឹងចំណុចនៃតួនាទីរបស់គាត់នេះមួយហើយ។

ដូចដែលលោកចៅក្រមបានឃើញហើយ គឺកិច្ចសម្ភាសន៍នេះបានសួរថា តើតួនាទីរបស់លោកស្រី -- តើលោកស្រីជាលេខាស្រុក ឬនៅពេលគេបញ្ជូនទៅហ្នឹង? គណ:កម្មការនេះគឺអត់ទេ គណ:កម្មការនេះគឺមានមនុស្សបីនាក់ បុរសពីរនាក់ ស្ត្រីម្នាក់។ សួរ៖ តើគេហៅថាគណ:ស្រុកឬអត់ទេ? ចាស

ហើយខ្ញុំទទួលបន្ទុកស្ត្រីទេ ខាងស្រី។ ចាស អ៊ីចឹងលោកស្រីទទួលបន្ទុកស្ត្រីឬ? អ៊ឹម ចែម ឆ្លើយ៖ ចាស ខ្ញុំទទួលបន្ទុកស្ត្រី ទៅលើស្ត្រីទាំងអស់។

[១៥:១៧:៥៧]

ដូចដែលបានឃើញយ៉ាងច្បាស់ហើយ លោកស្រី អ៊ឹម ចែម ហ្នឹងគឺថាបានជំទាស់តវ៉ាយ៉ាងច្បាស់ ថាគាត់មិនមែនជាលេខាស្រុកកោះអណ្តែតនោះទេ។ ហើយចំណុចនេះ គឺការលើកឡើងរបស់សហព្រះរាជអាជ្ញាអន្តរជាតិថា សហចៅក្រមស៊ើបអង្កេតមានកំហុសក្នុងការវាយតម្លៃទៅលើចម្លើយរបស់ អ៊ឹម ចែម ជាមួយមជ្ឈមណ្ឌលឯកសារ ដែលថាគាត់គឺជាសមាជិកនៃគណៈតំបន់១៣។ ជាពិសេសសហព្រះរាជអាជ្ញាអន្តរជាតិអះអាងក្នុងកថាខណ្ឌ៧១ ដល់៧៣ នៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនថាក្រៅពីការទទួលស្គាល់របស់ អ៊ឹម ចែម ថាត្រូវបានគេដំឡើងឋានៈឲ្យក្លាយទៅជាសមាជិកគណៈតំបន់១៣ អស់រយៈពេលមួយឆ្នាំ សហចៅក្រមស៊ើបអង្កេតមិនបានចាត់ទុកភស្តុតាង មិនបានពិចារណាទៅលើភស្តុតាងនេះបន្ថែមទៅទៀតនោះទេ។ ដូច្នេះខ្ញុំចង់បង្ហាញថា ផ្នែកមួយនៃកិច្ចសម្ភាសន៍របស់ អ៊ឹម ចែម នៅក្នុងឆ្នាំ២០១២។ សួរ៖ ដូច្នេះសូម្បីតែពេលដែលលោកស្រីទៅតាកែវ លោកស្រីនៅតែធ្វើការនៅស្រុកកោះអណ្តែតដដែល អ៊ីចឹងមែនទេ? លោកស្រី អ៊ឹម ចែម៖ ចាស ខ្ញុំនៅតែធ្វើការឲ្យស្រុកនោះដដែល។ សួរ៖ លោកស្រីមិនបានធ្វើការនៅថ្នាក់តំបន់ទេឬ? អ៊ឹម ចែម ឆ្លើយ៖ អត់ទេ។ អ្នកសម្ភាស៖ នៅពេលនោះតើតំបន់ណា? តំបន់១៣ឬ? អ៊ឹម ចែម ឆ្លើយថា៖ តំបន់១៣។ ដូចដែលបានឃើញច្បាស់ហើយ ចម្លើយរបស់ អ៊ឹម ចែម គឺថាវាច្បាស់ជាងអ្វីដែលបានលើកឡើងកាលពីម្សិលមិញដោយសហព្រះរាជអាជ្ញាអន្តរជាតិ។ កាលដែលសហព្រះរាជអាជ្ញាអន្តរជាតិ គឺថាមិនបានជំទាស់តវ៉ាទៅនឹងដំណើររឿងនេះទេ ដោយសហព្រះរាជអាជ្ញាគ្រាន់តែច្បិចយកចំណុចដែលខ្លួនចង់បានតែប៉ុណ្ណោះ ហើយជាពិសេសច្បិចយកតែវិធីសាស្ត្រណាមួយដែលខ្លួនចង់បាន ពាក់ព័ន្ធដល់វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត។ តាមការពិតសហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីសម្ភាសនោះគឺថាមានការប្រុងប្រយ័ត្នមែនទែន។

[១៥:២០:៤៥]

លើសពីនេះទៅទៀត ទាំងនៅក្នុងមូលដ្ឋានសំអាងទី៥ និង ៦ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានវាយតម្លៃភស្តុតាងរបស់សាក្សីឲ្យបានត្រឹមត្រូវ ដែលថាភស្តុតាងទាំងនោះគឺអាចឲ្យជឿជាក់បាន ថាវាស៊ីសង្វាក់គ្នាទៅនឹងកិច្ចសម្ភាសន៍របស់ អ៊ឹម ចែម

ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ក៏ប៉ុន្តែដូចដែលយើងខ្ញុំបានជំទាស់តវ៉ានៅក្នុងចម្លើយតបរបស់យើង ត្រង់កថាខណ្ឌ១១០ ដល់១១៨ ពាក់ព័ន្ធទៅនឹងមូលដ្ឋានអង្គហេតុទី៥ និងកថាខណ្ឌ១២១ ដល់១២៩ នៅក្នុងសំអាងហេតុទី៦។ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងអំពី ថាមានវិធីសាស្ត្រប្រកបដោយការជ្រើសរើស ក្នុងការបង្ហាញទៅលើភស្តុតាង ពាក់ព័ន្ធទៅនឹងភាពសមហេតុផលរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការវាយតម្លៃទៅលើភស្តុតាងក្នុងសំណុំរឿងទាំងមូល។ ពីម្សិលមិញសហព្រះរាជអាជ្ញាអន្តរជាតិបានអានឲ្យយើងស្ដាប់នូវបញ្ជីសាក្សី ដែលគាត់អះអាងថា វាស៊ីសង្វាក់គ្នាដោយមិនមានអ្វីគួរឲ្យសង្ស័យថា អ៊ឹម ចែម ហ្នឹងគឺជាលេខាស្រុកកោះអណ្ដែត និងជាសមាជិកគណៈតំបន់១៣ហើយ។ អ៊ីចឹងខ្ញុំសូមលើកយកឧទាហរណ៍ទាំងពីរមកបង្ហាញអំពីកង្វះអង្គសេចក្ដីនៅក្នុងការលើកឡើងនេះ។

[១៥:២២:២១]

សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា មិនមានការបញ្ជាក់ថា ហេតុអ្វីបានជាដីកាដំណោះស្រាយមិនបានពិចារណា សូមដកស្រង់យកភស្តុតាងដែលមានទម្ងន់ធ្ងន់របស់ សុខ រុំ មកពិចារណា។ យោងទៅតាមសហព្រះរាជអាជ្ញាអន្តរជាតិ សុខ រុំ នោះក្នុងកិច្ចសម្ភាសន៍របស់គាត់ គឺឯកសារ D119/108 ត្រង់ចម្លើយ១០៥ បានបញ្ជាក់ថា អ៊ឹម ចែម នោះគឺជាលេខាស្រុកកោះអណ្ដែត។ ក៏ប៉ុន្តែខ្ញុំសូមយកចម្លើយនេះមកឆ្លើយឲ្យត្រូវនឹងបរិបទវាតែម្ដង។ ទី១ សុខ រុំ ហ្នឹងបានលើកឡើងហើយ ខ្ញុំបានដកស្រង់ពីចម្លើយដដែលដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងមក គឺចម្លើយ១០៥នៃឯកសារ D119/108 សុំដកស្រង់៖ "ខ្ញុំបានដឹងពីចំណុចនេះថា លោកស្រី អ៊ឹម ចែម គឺជាលេខាស្រុកកោះអណ្ដែតពីបងស្រីៗរបស់គាត់ជាប្រធាននារីដែរ។" គឺថាដូចបានឃើញច្បាស់ហើយ រឿងរ៉ាវរបស់ សុខ រុំ នេះគឺមិនអ្វីក្រៅពីជាភស្តុតាងចចាមអារ៉ាមប៉ុណ្ណោះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិចង់សំអាង និងលើកយកមកបង្ហាញជូនអង្គបុរេជំនុំជម្រះ ជាពិសេសភស្តុតាងដែលពាក់ព័ន្ធ ដែលវាស៊ីសង្វាក់គ្នា ត្រូវយកភស្តុតាងណាដែលស៊ីសង្វាក់គ្នាទៅនឹងមជ្ឈមណ្ឌលឯកសារ មិនត្រូវយកភស្តុតាងណាដែលភស្តុតាងចចាមអារ៉ាមនោះទេ។

ទី២ ពាក់ព័ន្ធទៅនឹងការលើកឡើងរបស់ សុខ រុំ អំពីតួនាទីរបស់ អ៊ឹម ចែម។ បាទក៏ត្រូវឲ្យមានការបញ្ជាក់ផងដែរ សុខ រុំ បានលើកឡើងជូនសហចៅក្រមស៊ើបអង្កេត ខ្ញុំសូមដកស្រង់ត្រង់ចម្លើយ៧៨៖ "នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា មានអ្នកជិតខាងពីរបីនាក់របស់ខ្ញុំមកចូល

រួមដែរជាមួយខ្ញុំដែរ។ ហើយពេលខ្លះគេសួរសំណួរហ្នឹងមកខ្ញុំផ្ទាល់តែម្តង។ ហើយខ្ញុំមិនដឹងផ្តល់ចម្លើយយ៉ាងណាទេនៅក្នុងកិច្ចសម្ភាសន៍នេះ។ សាក្សីហ្នឹងក៏បានលើកឡើងថា ត្រង់ចម្លើយ១២នៅក្នុងអំឡុងពេលនុ៎ង គឺគាត់នៅក្មេងណាស់ គឺមិនអាចចងចាំអំពីឈ្មោះអ្នកដែលធ្វើការនៅក្នុងគណៈតំបន់១៣នោះទេ។ នៅក្នុងបរិបទនេះ គឺដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងអំពីរឿងរ៉ាវរបស់ សុខ រុំ នោះគឺថាជាភស្តុតាងមួយមានការជាប់ពាក់ព័ន្ធយ៉ាងខ្ពស់បំផុត។" បញ្ចប់ការដកស្រង់។

[១៥:២៥:៣៥]

ឧទាហរណ៍មួយផ្សេងទៀត ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានវាយតម្លៃឱ្យបានត្រឹមត្រូវនោះទេ ជាពិសេសឯកសារ D118/274 ត្រង់ចម្លើយ២៩។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាអន្តរជាតិគ្រាន់តែលើកយកចំណុចដែលខ្លួនចង់បាន ពីចម្លើយពេញលេញមួយរបស់សាក្សីរូបនេះ នៅត្រង់ចម្លើយលេខ២៤ គាត់ឆ្លើយថា សុំដកស្រង់៖ "ខ្ញុំមិនចាំច្បាស់ថាតើ អ៊ឹម ចែម ហ្នឹងមានតួនាទីណាមួយផ្សេងទៀត ក្រៅតែពីប្រធានសមាគមនារីទេ ដោយសារតែនៅក្នុងអំឡុងពេលហ្នឹង អ្វីៗទាំងអស់គឺថាជាការលាក់ការណ៍សម្ងាត់។ ខ្ញុំគ្រាន់តែឮសួរថា ឮដោយសារគេដក តាសោម ហើយ យាយចែម ហ្នឹងប្រហែលជាគាត់ក៏ក្លាយទៅជាសមាជិកតំបន់១៤" យើងយល់ស្របថា ប៊ុន ធឿន ហ្នឹងនិយាយនេះគឺថាសំដៅទៅលើតំបន់១៣ហើយ មិនមែនតំបន់១៤នោះទេ។

ដូច្នេះដើម្បីសរុបទៅលើចម្លើយតបរបស់យើងខ្ញុំ គឺថាមានភស្តុតាងជាច្រើនទៀតដែលសហចៅក្រមស៊ើបអង្កេតបានយកមកប្រើប្រាស់។ ខុសពីសហព្រះរាជអាជ្ញាអន្តរជាតិ នេះមិនមែនជាអំណោយរបស់សហចៅក្រមស៊ើបអង្កេត ដែលត្រូវយកបំបែកណាមួយនៃភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតពេញចិត្ត ទើបយកនោះទេ។ តួនាទីរបស់គាត់ គឺថាត្រូវពិនិត្យមើលភស្តុតាងទាំងស្រុងតែម្តង។ សហចៅក្រមស៊ើបអង្កេតក៏មិនអាចឆ្លើយតបទៅនឹងគ្រប់បំណែកទាំងអស់នៃចម្លើយរបស់សាក្សីគ្រប់ចម្លើយទាំងអស់បាន។ តែការខកខានមិនបានធ្វើបែបនេះ ក៏មិនបានធ្វើឱ្យប៉ះពាល់ដល់សេចក្តីសម្រេចនេះដែរ។

[១៥:២៨:១០]

សរុបមក នៅក្នុងមូលដ្ឋានអង្គហេតុ៥ និង៦ គ្មានអ្វីគ្រាន់តែជាការប្តឹងតែប៉ុណ្ណោះ គឺថាបានលើកឡើងនូវចំណុចមួយចំនួនដែលសហព្រះរាជអាជ្ញាអន្តរជាតិ គឺថាចង់ប្តឹងឧទ្ធរណ៍តែប៉ុណ្ណឹង មិនបានលើក

ឡើងចំណុចលម្អិតណាមួយនោះទេ។ អ៊ីចឹងលើកឡើងតែចំណុចណាមួយច្បោលៗដែលខ្លួនពេញចិត្ត និងចង់លើកឡើងតែប៉ុណ្ណោះ។ ហើយមិនបានបង្ហាញថាតើសហចៅក្រមស៊ើបអង្កេត ធ្វើការវិភាគទៅលើអង្គហេតុ អង្គច្បាប់ហ្នឹង ខុសជាក់ស្ដែងហ្នឹងដោយរបៀបណា។ ហ្នឹងមិនទាន់គិតទៅលើភស្តុតាងទាំងមូលនៃសេចក្ដីសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយ ដែលមិនស្ថិតនៅក្នុងយុត្តាធិការរបស់អ.វ.ត.ក ផង។

សហព្រះរាជអាជ្ញាអន្តរជាតិ គឺថាខកខានមិនបានជំទាស់តវ៉ាទៅលើសំអាងហេតុដែលមានសុពលភាពពី១ទៅ៦ មិនបានលើកយកមកជំទាស់ទេ។ ដូច្នេះ អ៊ីចឹងសហព្រះរាជអាជ្ញាអន្តរជាតិនៅពេលនេះ គឺថាស្នើសុំ គឺថាអំពាវនាវ សុំឲ្យមានអន្តរាគមន៍ពីអង្គបុរេជំនុំជម្រះទៅលើដីកាដំណោះស្រាយនេះ។ សហភាតារបស់ខ្ញុំ ក៏សូមឲ្យមានអន្តរាគមន៍ផងដែរ។

**លោក ប៊ិត ស៊ាងលីម៖**

ឯកឧត្តមប្រធាន អំពីសេចក្ដីសន្និដ្ឋានទាក់ទងនឹងការសម្ងាត់។ យើងខ្ញុំកត់សម្គាល់ឃើញថាកាលពីម្សិលមិញ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំដាក់ប្រតិចារឹកនៃសវនាការនៅចំពោះមុខអង្គបុរេជំនុំជម្រះជាសាធារណ:--

[១៥:៣០:៣៧]

**ប្រធានអង្គបុរេ៖**

លោកមេធាវី លោកមានសិទ្ធិតែនិយាយពីសេចក្ដីសន្និដ្ឋានរបស់លោកតែប៉ុណ្ណោះ លោកមិនអាចលើកពីអ្វីក្រៅពីសេចក្ដីសន្និដ្ឋានរបស់លោកទេ។

**លោក ប៊ិត ស៊ាងលីម៖**

ខ្ញុំសូម -- ឯកឧត្តមប្រធានសូមអនុញ្ញាត ត្រឡប់ទៅជូនសហមេធាវីអន្តរជាតិ ជូនសេចក្ដីសន្និដ្ឋាននេះអ៊ីចឹង។

**លោក វេញ ហ្សកដាហ្ស៖**

បាទ ខ្ញុំសូមបញ្ជាក់ដោយសង្ខេប ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានលើកសំណើឡើងសុំប្រតិចារឹកនៃសវនាការនេះជាសាធារណ:នោះ ហើយយើងសូមស្នើថា សវនាការចំពោះមុខអង្គជំនុំជម្រះធ្វើឡើងជាអសាធារណ: ដែលទាក់ទងទៅនឹងទឡ្ហីករណ៍ដែលយើងបានលើកឡើងគឺថាត្រូវរក្សាការសម្ងាត់គឺវាអាចប្រឈមនឹងគ្រោះថ្នាក់មួយចំនួន ហើយបើការផ្ទេរទៅសាធារណ:ហ្នឹង ទាក់ទងទៅនឹងឈ្មោះសាក្សី ហើយនិងចម្លើយរបស់ពួកគាត់ គឺថាវាស្ថិតនៅក្នុងកិច្ចស៊ើបសួរដែល

ជាការសម្ងាត់នៅឡើយ។ លើសពីនេះទៅទៀត ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិនោះ ជាពិសេសគឺអ្វីៗដែលយើងយល់ថា គឺជាលក្ខណៈពិសេសដែលមានសក្តានុពលសម្រាប់ការពារសន្តិសុខរបស់សាក្សីនានា ហើយមានសក្តានុពលដែលអាចនឹងធ្វើឲ្យសាធារណជនយល់ច្រឡំ ដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់ការសន្តិសុខរបស់កូនក្តីរបស់ខ្ញុំក្នុងការគ្រប់គ្រងនូវយុត្តិធម៌ ដែលអាចរាំងដល់ការស្វែងរកយុត្តិធម៌។ ដូច្នេះគឺថា ដើម្បីធានាសន្តិសុខផ្ទាល់ខ្លួនរបស់ អ៊ឹម ចែម ហើយនិងការគ្រប់គ្រងវិស័យយុត្តិធម៌ដោយត្រឹមត្រូវ ហើយការមិនជូនដំណឹងទៅសាធារណជននោះ គឺមិនជាចាំបាច់ទេ។ ហេតុដូច្នេះហើយ យើងមិនគាំទ្រសំណើដែលសុំឲ្យដាក់ប្រតិចារឹកសវនាការនេះជាសាធារណៈទេ។ ផ្ទុយទៅវិញ ប្រសិនបើអង្គបុរេជំនុំជម្រះឆ្លើយតបគាំទ្រសំណើរបស់សហព្រះរាជអាជ្ញាវិញ យើងខ្ញុំស្នើដោយគោរពថា យើងឲ្យមានការប្រុងប្រយ័ត្ន ហើយនិងដែលបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាដំណោះស្រាយរបស់គាត់ ដោយសុំឲ្យមានការកោសលុបផ្នែកមួយចំនួន ដែលបញ្ហាសំខាន់ៗដែលពាក់ព័ន្ធទៅនឹងការសម្ងាត់ដែលរក្សានូវអត្ថប្រយោជន៍ករណីរបស់យើងខ្ញុំ។ សូមអរគុណ។

[១៥:៣៣:៣៤]

**លោក នីកូឡាស គូមជែន៖**

ហើយមិនមានចម្លើយនៅក្នុងបណ្តឹងឧទ្ធរណ៍ នេះជាបញ្ហាថ្មីដែលមេធាវីការពារលើកឡើងក្រៅពីទឡ្ហីករណ៍បណ្តឹងឧទ្ធរណ៍។ នេះជាបញ្ហាថ្មីមួយទៀតទេ។

**ប្រធានអង្គបុរេ៖**

ការលើក យើងខ្ញុំបានជូនដំណឹងរួចហើយនៅក្នុងដីកាកំណត់កាលបរិច្ឆេទកាលចុះថ្ងៃទី១៤ ខែវិច្ឆិកា ១៧ ថាមិនអនុញ្ញាតឲ្យឆ្លើយតបទេ។ ដូច្នេះលោកភាគីទាំងអស់មានសិទ្ធិតែធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនតែប៉ុណ្ណោះ ហើយចប់តែប៉ុណ្ណោះ។

សវនាការរបស់យើងនៅថ្ងៃនេះ ឈានដល់ទីបញ្ចប់ ហើយសវនាការដែលយើងបានកំណត់រយៈពេលពីរថ្ងៃបានឈានដល់ទីបញ្ចប់ជាបូរិបូរណ៍ ដូច្នេះខ្ញុំប្រកាសបិទសវនាការ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៣៤ នាទី)*